ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
នាយកដ្ឋានបុគ្គលិក

# ប្រវត្តិ ក្រសួងអប់រំ យុវជន និង កីឡា

ផ្នែកទី ១

សីហា ១៩៩៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
នាយកដ្ឋានបុគ្គលិក

# ប្រវត្តិ ក្រសួងអប់រំ យុវជន និង កីឡា

ផ្នែកទី ១

សីហា ១៩៩៨

# ប្រវត្តិក្រសួងអប់រំ យុវជន និង កីឡា

## មាតិកា


ទំព័រ

អារម្ភកថា ១

សេចក្តីផ្តើម ២

ផ្នែកទី ១

ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

ថ្នាក់កណ្តាល

I- ការបំបែក និង បញ្ចូលក្រសួង ៥

II- ការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ៧

1- ក្រឹត្យច្បាប់លេខ ០៤ ក្រច_ប្រក ៧

2- ការបង្កើតអង្គភាពផ្សេងៗទៀតរបស់ក្រសួង ៩

3- ការអនុវត្តក្នុងដំណាក់កាល ១៩៩៣_៩៨ ( មុនចេញអនុក្រឹត្យលេខ ២១ អនក្រ_បក ) ៩

ក_ អង្គភាពបញ្ចូលថ្មី

ខ_ អង្គភាពបញ្ចូលភារកិច្ចជាមួយអង្គភាពផ្សេង

គ_ អង្គភាពថ្មី

ឃ_ ប្រធានអង្គភាព

4- គ្រឹះស្ថានសិក្សា ១៩

ក_ គ្រឹះស្ថានសិក្សាក្រោមឱវាទទីស្តីការ

ខ_ នាយកគ្រឹះស្ថានសិក្សា

III- ការអនុវត្តអនុក្រឹត្យលេខ ២១ អនក្រ_បក ៣៣

1- រចនាសម្ព័ន្ធថ្មីរបស់ក្រសួងអប់រំ យុវជន និង កីឡា ៣៤

2- ការរៀបចំនានាជាដំបូង ៣៦

ក_ ការរៀបចំថ្នាក់ដឹកនាំ

ខ_ ការរៀបចំការិយាល័យរបស់អង្គភាព

គ_ ការផ្ទេរមន្ត្រីរាជការ

ឃ_ ការតែងតាំងមន្ត្រីគ្រប់គ្រង

ង_ ការរៀបចំទីតាំងនិងបែងចែកសំភារៈបរិក្ខារ

ច_ ការកសាងលិខិតបទដ្ឋាននានា

**ថ្នាក់ខេត្តក្រុង**


I- រចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡា ខេត្តក្រុង ៣៨

1- ទំនាក់ទំនងរវាងរចនាសម្ព័ន្ធថ្នាក់កណ្តាល និង ថ្នាក់ខេត្តក្រុង ៣៩

ក_ និន្នាការបំបែកមន្ទីរ

ខ_ ការអនុវត្តដំណាក់កាល ១៩៧៩_៩៨

2- ការបង្កើតមន្ទីរអប់រំ យុវជន និង កីឡាថ្មី ៤២

3- ការអនុវត្តសារាចរលេខ ០៣ អយក_សរណន ៤៣

ក_ រចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡា ខេត្តក្រុង

ខ_ រចនាសម្ព័ន្ធការិយាល័យអប់រំ យុវជន និង កីឡា ស្រុកខេត្ត

គ_ ការដឹកនាំមន្ទីរ

ឃ_ ភារកិច្ចថ្មីរបស់មន្ទីរ

II- ពីការគ្រប់គ្រងខ្សែរយៈទទឹងមកជាការគ្រប់គ្រងខ្សែរយៈបណ្តោយ ៤៧

1- ការងារជំនាញ ៤៧

2- ការងារបុគ្គលិក ៤៨

3- ការងារហិរញ្ញវត្ថុ ៥០

III- ប្រធានមន្ទីរ ៥១


**ផ្នែកទី ២**

ការងារបុគ្គលិក ក្រសួងអប់រំ យុវជន និង កីឡា


ការងារក្របខ័ណ្ឌនិងបៀវត្ស ៥២

I- កំណើនចំនួនមន្ត្រីរាជការ ៥២

1- ប្រភពក្របខ័ណ្ឌពី ១៩៧៩ ដល់ ១៩៩៨ ៥២

ក_ ការបណ្តុះបណ្តាលដោយក្រសួងអប់រំ យុវជន និង កីឡា

ខ_ ក្របខ័ណ្ឌសមាហរណកម្ម

គ_ ក្របខ័ណ្ឌផ្ទេរចូល

ឃ_ ក្របខ័ណ្ឌបែងចែកពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ង_ ភ្នាក់ងារសាធារណៈ

2- គោលការណ៍ជ្រើសរើស និង បែងចែក ៦២

II- ប្រព័ន្ធបណ្តុះបណ្តាលគ្រូ ៦៤

1- កាលៈទេសៈ ៦៤

2- ការបង្កើនសមត្ថភាពគ្រូ ៦៥

3- ប្រភពបណ្តុះបណ្តាល ៦៦

4- កត្តាសង្គមសេដ្ឋកិច្ច ៦៦

5- កក្តានយោបាយ ៦៧
III- ក្របខ័ណ្ឌមន្ត្រីរាជការ ៦៩
IV- បៀវត្សមន្ត្រីរាជការ ៧២
1- ប្រាក់បៀវត្ស ៧៣
2- ប្រាក់ឧបត្ថម្ភ ៧៣
3- ប្រាក់កំរៃគុរុកោសល្យ ៧៤
4- ប្រាក់ប្រពន្ធកូន ៧៤
5- ប្រាក់តំបន់ ៧៥

## ការងារគ្រប់គ្រងបុគ្គលិក

I- អនុវត្តការគ្រប់គ្រងខ្សែបណ្តោយ
1- ការតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌ ៨២
2- ការតំឡើងថ្នាក់ ៨៣
ក_ គោលការណ៍ផ្សេងៗ
ខ_ ការអនុវត្ត
3- ការសុំច្បាប់ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស និង ការលុបឈ្មោះ ៨៦
ក_ អនុក្រឹត្យលេខ ១៦៦ អនក្រ
ខ_ ការលុបឈ្មោះ
4- ការចូលនិវត្ត និង បាត់បង់សម្បទាវិជ្ជាជីវៈ ៩២
ក_ អនុក្រឹត្យលេខ ៥៩ អនក្រ_បក
ខ_ ការដាក់អោយចូលនិវត្តន៍ និង បញ្ហាចោទ
5- ការដាក់វិន័យចំពោះមន្ត្រីរាជការ និង ការចោទប្រកាន់តាមផ្លូវតុលាការ
ក_ ការដាក់វិន័យចំពោះមន្ត្រីរាជការ
ខ_ ការចោទប្រកាន់តាមផ្លូវតុលាការ
II- លក្ខខណ្ឌនៃការគ្រប់គ្រងបុគ្គលិកដោយប្រសិទ្ធភាព ៩៨
1- ការងារបច្ចេកទេសគ្រប់គ្រង ៩៨
2- ដំណោះស្រាយជីវភាព ៩៨
3- ការរៀបចំឡើងវិញការងារគ្រប់គ្រង ៩៨

## នាយកដ្ឋានបុគ្គលិក

I- រចនាសម្ព័ន្ធ និង ការគ្រប់គ្រង ១០០
១_ រចនាសម្ព័ន្ធនាយកដ្ឋាន ១០០
២_ ការគ្រប់គ្រង ១០១
II- ការបែងចែកភារកិច្ច ១០៣
១_ ការបែងចែកភារកិច្ចមន្ត្រីរាជការ ១០៣

២_ ភារកិច្ចការិយាល័យនីមួយៗ ១០៤

ក_ ការិយាល័យបុគ្គលិក

ខ_ ការិយាល័យក្របខណ្ឌនិងបៀវត្ស

គ_ ការិយាល័យរដ្ឋបាល

ឃ_ ការិយាល័យនីតិកម្ម

៣_ ការអនុវត្តការងារ ១០៦

ក_ ការងារសំខាន់ៗ

ខ_ ទំនាក់ទំនងការងារនិងមធ្យោបាយបំពេញការងារ


## ទិដ្ឋាជីវៈគ្រូបង្រៀន


I- របបការងារប្រ ចាំថ្ងៃ ១០៩

១_ ការងារក្នុងការិយាល័យ ១០៩

២_ ការងារនៅគ្រឹះស្ថានសិក្សាសាធារណៈ ១០៩

II- របបជីវភាព ១១០

១_ ដំណាក់កាលមកដល់ឆ្នាំ ១៩៧៥ ១១១

២_ ដំណាក់កាលពី ១៩៧៩ ដល់ ១៩៩៨ ១១២

ក_ ការប្រែប្រួលនៃតំលៃទំនិញ

ខ_ បៀវត្សគ្រូបង្រៀន

III- ដំណោះស្រាយនិងប្រតិយាតផ្សេងៗ ១១៧

១_ ចំពោះខ្លួនឯងផ្ទាល់ និង ប្រពន្ធកូន ១១៧

ក_ គ្រូចេញថ្មី

ខ_ គ្រូកំពុងបំពេញការ

២_ ចំពោះការងាររដ្ឋ និង សង្គម ១១៩

ក_ គ្រូនៅក្នុងការិយាល័យ និង សាលារៀន

ខ_ គ្រូនៅក្នុងសង្គម

# អារម្ភកថា

ឯកសារនេះត្រូវបានចងក្រងឡើងជាលើកដំបូង ដោយប្រមូលផ្តុំពត៌មានជាច្រើនផ្អែកលើលិខិតបទដ្ឋាន និងការសាកសួរពត៌មាន ។

ឯកសារនេះជាកំណត់ត្រានៃការវិវត្តការងារគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា ចាប់ពីឆ្នាំ ១៩៧៩ ដល់ បច្ចុប្បន្ន ។ ដំណាក់កាលមុននេះ យើងមានឯកសារតិចតួច ។ រយៈពេលកន្លងមក ដំបូង ក្រសួងមានឈ្មោះថា " ក្រសួងអប់រំ " ហើយសព្វថ្ងៃឈ្មោះថា " ក្រសួងអប់រំ យុវជន និង កីឡា " ។ អ្វីខ្លះដែលមានការវិវត្ត យើងកត់ត្រាចំណុចសំខាន់ៗនៃការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួង ការងារបុគ្គលិកដែលជាការងាររបស់នាយកដ្ឋានបុគ្គលិក ដោយលើកឡើងនូវទស្សនៈខ្លះសំរាប់ពិចារណា ។ ឯកសារនេះមិនចូលជ្រៅទៅតាមជំនាញផ្នែកមត្តេយ្យសិក្សា បឋមសិក្សា អប់រំក្រៅប្រព័ន្ធទេ ... ព្រោះផ្នែកទាំងនេះមានរបាយការណ៍ រឺ ឯកសារដោយឡែកហើយ ។

ការចងក្រងនេះមានសារៈសំខាន់សំរាប់អ្នកគ្រប់គ្រងបន្ត ហើយដែលអ្នកគ្រប់គ្រងគ្រប់អង្គភាពបច្ចុប្បន្នម្នាក់ៗមានភារកិច្ចចងក្រងដែរ ដើម្បីទុកជាឯកសារនិងពិចារណាសំរាប់អ្នកជំនាន់ក្រោយ ។

ការរៀបចំឯកសារនេះត្រូវបានចាប់ផ្តើមពី ខែមេសា ឆ្នាំ ១៩៩៨ ហើយត្រូវបានបញ្ចប់នៅដំណាច់ខែ សីហា គឺបញ្ចប់មុនការរៀបចំរដ្ឋាភិបាលថ្មី អាណត្តិទី២ ដែលកើតឡើងពីការបោះឆ្នោតថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ព្រោះថា ក្រសួងអប់រំ យុវជន និង កីឡា នឹងមានការប្រែប្រួលថ្មីទៀតក្រោយនេះ ។

ឯកសារនេះប្រាកដជានៅមានការខ្វះខាត ។ ខ្ញុំរង់ចាំទទួលការកែលំអពីគ្រប់មជ្ឈដ្ឋាន ។

សូមថ្លែងអំណរគុណចំពោះ អស់លោក លោកស្រីទាំងអស់ ដែលបានផ្តល់ឯកសារ និងពត៌មានដល់ការចងក្រងនេះ ។

សូមថ្លែងអំណរគុណចំពោះសហគមន៍អឺរ៉ុបដែលជួយក្រសួងយើងខ្ញុំ ហើយបានបំពាក់សំភារៈទំនើបលើកដំបូងបង្អស់ដល់នាយកដ្ឋានបុគ្គលិក សំរាប់ជួយពង្រឹងការងារគ្រប់គ្រង ។

សូមឧទ្ទិសស្នាដៃនេះចំពោះមន្ត្រីគ្រប់គ្រង និង បុគ្គលិកសិក្សារួមវិជ្ជាជីវៈទាំងអស់ នៃក្រសួងអប់រំ យុវជន និង កីឡា ។

ភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៨



បណ្ឌិត ឆយ អ៊ួន

អគ្គនាយករង

# សេចក្តីផ្តើម

វិស័យអប់រំ យុវជននិងកីឡា មាន ២ ផ្នែក សំខាន់ គឺផ្នែកជំនាញនិងផ្នែកទ្រទ្រង់ ។ ផ្នែកជំនាញមាន មត្តេយ្យ បឋមសិក្សា អប់រំក្រៅប្រព័ន្ធ ឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស បណ្តុះបណ្តាលវិជ្ជាជីវៈ យុវជន និង កីឡា ។ ផ្នែកទ្រទ្រង់មានការងារផែនការ បុគ្គលិក និង បណ្តុះបណ្តាលគ្រូ ហិរញ្ញវត្ថុ និង សំភារៈ អនាម័យសិក្សា រដ្ឋបាល ទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍ ... ។ ផ្នែក ទី៣ ដែល សំខាន់ គឺ អគ្គាធិការកិច្ច ។

ឯកសារយើងយកតែចំណែកមួយនៃផ្នែកទ្រទ្រង់ ដែលពាក់ព័ន្ធដល់ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួង អប់រំយុវជននិងកីឡា ដល់ការងារបុគ្គលិកយកមកកត់ត្រា ព្រោះចំណែកនេះមានការប្រែប្រួលជាលំដាប់ ហើយ ពាក់ព័ន្ធនឹងដំណាក់កាលនយោបាយនីមួយៗផង ។ បើយើងមិនបានកត់ត្រាទុក អ្វីៗនឹង បាត់ពតិមានជាប្រាកដ ដោយគ្មានបានចងក្រង ដោយបាត់បង់ឯកសារ និង ជាពិសេសទៅជាមួយអ្នកចូល និវត្ត ។

យើងអាចកត់ត្រាការអភិវឌ្ឍវិស័យអប់រំតាមដំណាក់កាលដូចខាងក្រោម :

-ដំណាក់កាល " ព្រះរាជាណាចក្រកម្ពុជា " មកដល់ឆ្នាំ ១៩៧០ : ការអប់រំមានការរីកចំរើនគួរ អោយកត់សំគាល់ មានបឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សា ។ ការសិក្សាមានគុណភាព ។ ការរីកចំរើន នេះជាដំណាក់កាលដំបូង ពុំទាន់រីកទូលំទូលាយទេ ។ សាលារៀនច្រើនតាំងនៅទីប្រជុំជននៅឡើយ ។ ការប្រមូល កុមារអោយចូលរៀននៅមានកំរិត ។ ជាមួយនឹងការរីកចំរើនជំហានដំបូងនេះ ជីវភាពបុគ្គលិកសិក្សាត្រូវបាន ដោះស្រាយយ៉ាងល្អ ។ បៀវត្សគ្រូបង្រៀនម្នាក់អាចចិញ្ចឹមគ្រួសារប្តី-ប្រពន្ធ-កូនខ្លួនយ៉ាងស្រួល ហើយអាចរំលែក ចិញ្ចឹមឪពុក-ម្តាយ បង-ប្អូន បានខ្លះទៀតផង គួបផ្សំនឹងតំលៃជីវភាពពេលនោះនៅទាប ។ គ្រូបង្រៀនចេញថ្មី អាចទៅបំរើការងារនៅខេត្តណាក៏បាន ព្រោះគេមានបៀវត្សអាចរស់ដោយខ្លួនគេ ។

-ដំណាក់កាល " សាធារណរដ្ឋខ្មែរ " ( ខែមីនា ១៩៩៧០ ដល់ ខែ មេសា ១៩៧៥ ) - ការអភិវឌ្ឍ ស្ថិតក្នុងដំណាក់កាលទ្រឹង ដោយសារសង្គ្រាម ។ អ្វីៗបន្តពីមុនគ្មានបានកែលំអ ហើយត្រូវសង្គ្រាមបំផ្លេចបំផ្លាញ ថែមទៀតនៅច្រើនកន្លែង ។ បទបញ្ញត្តិជាគ្រឹះធំៗនៃរបបនេះមាន " ការពាររបបសាធារណរដ្ឋ ប្រឆាំងនឹងការ ប៉ុនប៉ងអោយមានរាជានិយមឡើងវិញ ហើយប្រឆាំងនឹងការបង្កើតអោយមានរបបបុគ្គលនិយមគ្រប់បែបយ៉ាង ។ ប្រទេសកម្ពុជា ជា សាធារណរដ្ឋឯករាជ្យ ប្រជាធិបតេយ្យ ហើយដែលនិយម ប្រយោជន៍សង្គម " ។

-ដំណាក់កាល "កម្ពុជាប្រជាធិបតេយ្យ " ប្រល័យពូជសាសន៍នៃរបបប៉ុលពត (មេសា១៩៧៥-៧មករា ១៩៧៩ ) - ប្រជាជនត្រូវគេជំលៀសទៅជនបទទាំងអស់ ។ សាលារៀនដែលមានពីមុនទាំងប៉ុន្មាន គ្រប់កំរិតសិក្សា ត្រូវបិទទ្វារ ។ គេប្រមូលផ្តុំមនុស្សរស់នៅជាសហករណ៍ ធ្វើស្រែចំការនៅជនបទ ធ្វើកម្មករនៅតាមរោងចក្រមួយ

ចំនួន ។ អ្វី ១ របស់សង្គមមុន " ជារបស់ចក្រពត្តិ " ត្រូវកំទេចចោល ។ បញ្ញវន្តគ្រប់កំរិត រួមទាំងសិស្សនិស្សិតត្រូវគេ សម្លាប់ រង្គាលដោយរូបភាពជាច្រើន ។ គេបង្កើតសាលារៀនសំរាប់ក្មេងតូច១នៅតាម ភូមិ នៅតាមរោងបាយ... រៀនតាម សៀវភៅរបស់គេ បង្រៀនដោយគ្រូរបស់គេ ដែលមានកំរិតជំនាញ ត្រឹមតែ " អ្នកចេះអក្សរ " ។ គ្មានសាលារៀន គ្មានគ្រូ ។ គ្មានការចាយលុយទេ ។

- ដំណាក់កាល " សាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា " ( ៧មករា ១៩៧៩ -ឧសភា ១៩៩៣ ) សាលារៀន ត្រូវបានបើកទ្វារឡើងវិញនៅឆ្នាំ ១៩៧៩ តាមទីតាំងចាស់ដែលគេបានបិទទ្វារកាលពីសម័យប៉ុលពត ។ គ្រូបង្រៀន ត្រូវបានជ្រើសរើស និង បណ្តុះបណ្តាលជាបន្តបន្ទាប់ ។ ចំនួនសិស្ស ចំនួនគ្រូ កើនឡើងជាលំដាប់ នៅគ្រប់កំរិតសិក្សា ដែលរបបមុន១មិនទាន់មាន ។ ពិសេសសាលារៀនបានបើកទូលាយដល់ជនបទ ក្រៅពីទីប្រជុំជន ។ ការប្រមូល កុមារអោយចូលរៀនមានការរីកចំរើន ទាំងចំណេះទូទៅ ទាំងអក្ខរកម្ម ( នៅដំណាក់កាលដំបូង ) ។

ការដឹកនាំប្រទេសស្ថិតក្រោមឯកបក្ស ។ បទបញ្ញត្តិជាគ្រឹះធំ ១ មាន : " ក្រសួងអប់រំជាអង្គការមួយរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត មានភារកិច្ចគ្រប់គ្រងការអប់រំ និង សិក្សាគ្រប់វិស័យ តាមក្រឹត្យមាគ៌ាបដិវត្ត គោលនយោបាយ របស់បក្ស និង ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ បំរើសេចក្តីត្រូវការ ដើម្បីការពារ និង កសាង សាធារណរដ្ឋប្រជាមានិតកម្ពុជា ឈានឡើងសង្គមនិយម " ( ក្រឹត្យច្បាប់លេខ ០៤ ក្រច-ក្រប្រ ) ។

បទបញ្ញត្តិជាគ្រឹះទាំងអស់ត្រូវបានកែលំអជាច្រើននៅក្នុងដំណាក់កាលនៃរដ្ឋកម្ពុជាឈានទៅរកការបោះឆ្នោត ឆ្នាំ ១៩៩៣ ។

ជារួម ការសិក្សាត្រូវបានដោះស្រាយយ៉ាងធំផ្នែកបរិមាណដែលពីមុនមិនធ្លាប់មាន ។ ផ្នែកគុណភាពនៅមានកំរិតជាទូទៅ ។ ជីវភាពគ្រូបង្រៀននៅជួបការលំបាក ព្រោះមិនទាន់អាចចិញ្ចឹមខ្លួនឯងម្នាក់រស់បានស្រួលក្នុងការបំពេញវិជ្ជាជីវៈរបស់ខ្លួន ត្បិតតែមានការកែលំអជាបន្តបន្ទាប់ក៏ដោយ ។

- ដំណាក់កាល " ព្រះរាជាណាចក្រ " លើកទី ២ (ចាប់ពី ខែ ឧសភា ឆ្នាំ ១៩៩៣ ដល់ ខែ កក្កដា ឆ្នាំ ១៩៩៨ ) - ដំណាក់ការនេះមានការប្រែប្រួលថ្មីច្រើន ទាំងបរិមាណ ទាំងគុណភាពដោយសារលទ្ធភាពជំនួយបរទេសមួយភាគធំគួបផ្សំនឹងការខិតខំក្នុងប្រទេស ។ ទីផ្សារសេរីបានបើកឡើង ។ ជីវភាពបុគ្គលិកសិក្សាមួយចំនួនមានការធូរស្រាល ដូចជាសុំច្បាប់ស្ថិតក្នុងភាពទំនេរគ្មានបៀវត្សទៅបំរើការឯកជន ការឧបត្ថម្ភពីអង្គការដែលជួយអង្គភាពជំនាញនីមួយ១ ការឧបត្ថម្ភតាមរយៈការបណ្តុះបណ្តាលពីចំងាយ ( ដោយ PASEC ).... គួបផ្សំនឹងការខិតខំកែលំអប្រាក់បៀវត្សសុទ្ធសាធ និង ប្រាក់កំរៃគរុកោសល្យរបស់រាជរដ្ឋាភិបាល ។ បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ ជាតិ សាសនា ព្រះមហាក្សត្រ ។ ការដឹកនាំប្រទេសស្ថិតក្រោមពហុបក្ស ។ ក្រសួងអប់រំ

យុវជននិងកីឡា ត្រូវបានរាជ រដ្ឋាភិបាលប្រគល់ " បេសកកម្ម អោយដឹកនាំ និង គ្រប់គ្រង វិស័យអប់រំ យុវជន និង កីឡា នៃព្រះរាជា ណាចក្រកម្ពុជា " ។ ក្រសួងមានមុខងារ និង ភារកិច្ចជាច្រើន ក្នុងនោះកំណត់នយោបាយអប់រំ យុវជន និង កីឡា ដោយផ្អែកលើមូលដ្ឋានកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅអភិវឌ្ឍធនធានមនុស្ស " ។

ឯកសារដែលចងក្រងឡើងនេះសង្ខេបឡើងវិញនូវអ្វី ៗ ដែលបានវិវត្តក្នុងប្រវត្តិក្រសួងអប់រំ ពិសេស ចាប់ពីឆ្នាំ ១៩៧៩ ដែលយើងមានឯកសារមួយចំនួនធំសំរាប់សិក្សា ។ ដោយឡែកឯកសារនេះលើកឡើងអំពីប្រវត្តិ ក្រសួងអប់រំ យុវជន និង កីឡា យកត្រង់ផ្នែកទ្រទ្រង់ដោយសង្កត់ធ្ងន់លើការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួង ការងារបុគ្គលិក ។

ឯកសារប្រវត្តិក្រសួងអប់រំ យុវជន និង កីឡា ចែកចេញជា ២ ផ្នែកគឺ :

-ផ្នែកទី ១ : ការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា - ផ្នែកនេះលើកឡើង ការងាររៀបចំនៅ ថ្នាក់កណ្តាល និង ថ្នាក់ខេត្ត-ក្រុង រហូតដល់ពេលចេញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ និង ការអនុវត្តខ្លះ ៗ នៅដំណាក់ដំបូង ។

-ផ្នែកទី ២ : ការងារបុគ្គលិកក្រសួងអប់រំ យុវជន និង កីឡា - ផ្នែកនេះលើកឡើងអំពីការងារក្របខណ្ឌ និង បៀវត្ស ការងារគ្រប់គ្រងបុគ្គលិក នាយកដ្ឋានបុគ្គលិក និង វិជ្ជាជីវៈ គ្រូបង្រៀន ។

ផ្នែកនីមួយ ៗ មានភ្ជាប់ដោយតារាង រឺ ស្ថិតិ ដើម្បីបំពេញអោយខ្លឹមសារ ។

ឯកសារនេះជាការចងក្រងកត់ត្រា ដោយមានភ្ជាប់នូវទស្សនៈខ្លះ ៗ ផ្ទាល់ខ្លួនដែលយល់ឃើញតាមរយៈការ ឆ្លងកាត់ក្រោមការងារគ្រប់គ្រងរបស់គេ និង កាន់ការគ្រប់គ្រងខ្លួនឯង និង ឆ្លងកាត់ដំណាក់កាលប្រវត្តិសាស្ត្រទាំងអស់ ដែល ខ្លួនធ្លាប់ទទួល ចាប់ ពីទសវត្ស ៦០ មក ។

នៅខាងចុងនៃឯកសារមានតារាងឧបសម្ព័ន្ធនិយាយអំពីកាលបរិច្ឆេទនានានៃការងារអប់រំ យុវជន និង កីឡា និង កាលបរិច្ឆេទការងារពាក់ពន្ធ័ពី ឆ្នាំ ១៩៧៩ ដល់ ១៩៩៨ ។

ឯកសារនេះអមដោយឯកសារឧបសម្ព័ន្ធ ៥ ផ្នែកទៀត ដែលចងក្រងឯកសារ និង លិខិតបទដ្ឋានផ្សេង ៗ ពាក់ពន្ធ័នឹងផ្នែកទាំងពីរនៃឯកសារ ។

ប្រវត្តិទាំងអស់ក្នុងឯកសារនេះត្រូវបញ្ចប់ត្រឹម ខែ សីហា ឆ្នាំ ១៩៩៨ មុនអ្វី ៗ ដែលនឹងត្រូវរៀបចំថ្មីទៀត ពេលដែល រាជរដ្ឋាភិបាល អាណត្តិទី ២ នឹងត្រូវបានបង្កើតឡើង ។

# ផ្នែកទី ១

# ផ្នែកទី ១

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង

# ថ្នាក់កណ្តាល

I- ការបំបែកនិងការបញ្ចូលក្រសួង

ការរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបានដំណើរការតាំងពី ឆ្នាំ១៩៩៣ ពេលដែលក្រសួងអប់រំ ( ទីតាំងនៅខាងត្បូងវិមានឯករាជ្យ ដែល ជាទីតាំងអតីតក្រសួងអប់រំ មុនបោះឆ្នោតឆ្នាំ១៩៩៣ ) និង ក្រសួងឧត្តមសិក្សា និង បច្ចេកទេស ( ទីតាំងសព្វថ្ងៃរបស់ក្រសួងអប់រំ យុវជន និង កីឡា ស្ថិតខាងត្បូងអនុវិទ្យាល័យចតុមុខ ខាងក្រោយព្រះបរមរាជវាំង ) ត្រូវបានបញ្ចូលគ្នាជា << ក្រសួងអប់រំ យុវជន និង កីឡា >> ចាប់ពីរាជរដ្ឋាភិបាលកម្ពុជាត្រូវបានបង្កើតឡើង ( ព្រះរាជក្រឹត្យតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ) ។

ក្នុងសម័យរដ្ឋាភិបាលបណ្តោះអាសន្ន ដែលដឹកនាំប្រទេសរយៈពេលខ្លី ( ក្រោយបោះឆ្នោតរហូត ដល់ ៣១ ខែ តុលា ឆ្នាំ១៩៩៣ ។ ក្រឹត្យតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្នចេញថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ១៩៩៣ ) ក្រោយពេលបោះឆ្នោតសកលដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិតាមស្មារតីកិច្ច ព្រមព្រៀងប៉ារីស ឆ្នាំ១៩៩១ មានក្រសួង ៣ ដែលមានការពាក់ព័ន្ធនឹងក្រសួងអប់រំ យុវជន និង កីឡា បច្ចុប្បន្ន ៖

- ក្រសួងអប់រំ
- ក្រសួងឧត្តមសិក្សានិងបច្ចេកទេស - ត្រូវបានបង្កើតឡើងជាលើដំបូង
- ក្រសួងកិច្ចការនារី យុវជន និង កីឡា - ត្រូវបានបង្កើតឡើងជាលើកដំបូង

កំណត់សំគាល់ទី១:

មុនការបោះឆ្នោត <<ក្រសួងអប់រំ >> ជាឈ្មោះខ្លី តែដឹកនាំគ្រប់គ្រង ការងារអប់រំផង ( ទាំងអប់រំ ក្រៅប្រព័ន្ធ ) ការងារឧត្តមសិក្សា និងបច្ចេកទេសផង ( មានទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈដែរ ) ។ ក្រោយពេលបោះឆ្នោត ឆ្នាំ១៩៩៣ ក្នុងរដ្ឋាភិបាលជាតិបណ្តោះ អាសន្ន ក្រសួងអប់រំនេះត្រូវចែកជា២គឺ៖

- ក្រសួងអប់រំ ដឹកនាំគ្រប់គ្រងតែការងារអប់រំសុទ្ធសាធ
- ក្រសួងឧត្តមសិក្សានិងបច្ចេកទេស

ពេលនោះ ក្រសួងអប់រំបានធ្វើពង្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង តែពុំទាន់ចេញជាការសំរេចអ្វីពីរដ្ឋាភិបាលនៅឡើយទេ ( ១៩៩៣ ) ។

ពេលមានក្រសួងអប់រំនិងក្រសួងឧត្តមសិក្សានិងបច្ចេកទេសដោយឡែកពីគ្នា ក្រសួងទី២ នេះមានបំណងយកភារកិច្ចបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន មន្ត្រីគ្រប់គ្រង ទីប្រឹក្សាគរុកោសល្យ អធិការសំរាប់ភូមិសិក្សា ដែលមានកំរិតឧត្តមសិក្សា រឺ កំរិតមធ្យមបច្ចេកទេស អោយស្ថិតក្រោមការ គ្រប់គ្រងរបស់ខ្លួន ។ ក្រសួងអប់រំ សំណូមពរសូមទុកភារកិច្ចនេះដែលធ្លាប់មានកន្លងមក ដោយមូលហេតុថា ការងារបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន..... ជាកត្តាក្នុងប្រព័ន្ធអប់រំ គួបផ្សំជាមួយកត្តាក្រៅប្រព័ន្ធអប់រំ ដែលមានទិសដៅបំរើអោយការអភិវឌ្ឍវិស័យអប់រំទាំងមូល ។

<u>កំណត់សំគាល់ទី២</u> :

ក្នុងពេលដែលមានតែក្រសួងអប់រំតែមួយ ក្រសួងអប់រំគ្រប់គ្រងសាលាឧត្តមសិក្សានិងបច្ចេកទេសនៅក្រោមឱវាទក្រសួង និង សហការងារបច្ចេកទេសជាមួយក្រសួងនានា ដែលមានគ្រឹះស្ថានឧត្តមសិក្សា និងបច្ចេកទេស ដូចជាក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងវប្បធម៌ ។ ការងាររដ្ឋបាល និងហិរញ្ញវត្ថុសាមីក្រសួងទាំងនេះជាអ្នកដឹកនាំគ្រប់គ្រង ។

ក្រោយមកឆ្នាំ១៩៩៤ ក្រសួងពាណិជ្ជកម្ម បានផ្ទេរសាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម ( ខាង លិចវត្តភ្នំ ) ក្រសួងឧស្សាហកម្ម បានផ្ទេរសាលាមធ្យមសិក្សាឯកទេសឧស្សាហកម្ម ឫស្សីកែវ (គ.ម លេខ៦) អោយស្ថិតក្រោមក្រសួងអប់រំ ( ០៤ ឧសភា ១៩៩៤ ) ។ ឆ្នាំ១៩៩២ សាលាកម្មាភិបាលនិងនីតិសាស្ត្ររបស់ក្រសួងយុត្តិធម៌ ត្រូវបានរៀបចំផ្ទេរអោយក្រសួងអប់រំ ។

សូមគូសបញ្ជាក់ថា ការបង្កើតក្រសួងឧត្តមសិក្សានិងបច្ចេកទេសគឺការដឹកនាំគ្រប់គ្រងការងារឧត្តមសិក្សានិងបច្ចេកទេស ស្ថិតក្រោមដំបូលក្រសួងតែមួយ ។ ពេលនោះ ក្រសួងឧត្តមសិក្សានិងបច្ចេកទេស បានធ្វើពង្រាងក្រឹត្យស្តីពីការបង្កើតក្រសួងឧត្តមសិក្សានិងបច្ចេកទេស តែមិនទាន់ចេញជាលទ្ធផលអ្វីនៅឡើយ ។

<u>កំណត់សំគាល់ទី៣:</u>

មុន១៩៩៣ សម័យរដ្ឋកម្ពុជា ការងារយុវជន មានរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួននៅថ្នាក់កណ្តាល (គណៈកម្មាធិការមមជ្ឈិមសម្ព័ន្ធយុវជន) រហូតដល់ខេត្តក្រុង (គណៈកម្មការសម្ព័ន្ធយុវជនខេត្ត)។ ការងារនារីក៏ដូចគ្នាដែរ ( សមាគមនារីមជ្ឈិម-សមាគមនារីខេត្ត-ក្រុង ) ។
ការងារកីឡាក៏មានខ្សែរយៈគ្រប់គ្រងរបស់ខ្លួននៅ ថ្នាក់កណ្តាលដល់ខេត្តក្រុង នៅក្នុងក្រសួងវប្បធម៌ ។ ការងារយុវជន ត្រូវបានផ្ទេរចូលក្រសួងអប់រំតាំងពី មុនពេលបោះឆ្នោត១៩៩៣ ។ នៅថ្នាក់កណ្តាលមន្ត្រីរាជការចំនួន ៣៤ នាក់បានផ្ទេរចូលមកក្រសួងថ្មី ។ ការិយាល័យមួយឈ្មោះថា ការិយាល័យយុវជន ត្រូវបានបង្កើតឡើង នៅចំណុះមន្ទីរនៃទីស្តីការក្រសួង ( តុលា ឆ្នាំ១៩៩២ ) ។ រដ្ឋាភិបាលបណ្តោះអាសន្នបានប្រមូល ផ្តុំការងារជាក្រសួងតែមួយ ឈ្មោះថា" ក្រសួងកិច្ចការនារី យុវជន និង កីឡា " ។

កំណត់សំគាល់ទី៤:

ការបង្កើតក្រសួងមួយ ដែលបញ្ចូលក្រសួងនិងផ្នែកនានានៃក្រសួងមួយចំនួន បានជាក្រសួងអប់រំ យុវជន និង កីឡា គឺ យកការងារក្រសួងឧត្តមសិក្សានិងបច្ចេកទេសអោយមកក្រសួងដើមវិញ ដូច នៅក្នុងកំណត់ សំគាល់ទី១ ដែលមានភារកិច្ចដឹកនាំគ្រប់គ្រងការងារអប់រំផង ការងារឧត្តមសិក្សា និងបច្ចេកទេសផង ។ យើងគូសបញ្ជាក់ថាការងារឧត្តមសិក្សានិងបច្ចេកទេស ក្នុងនេះមានភារកិច្ច មិនដូច អ្វីដែលជាទិសដៅក្នុងការបង្កើតក្រសួងឧត្តមសិក្សានិងបច្ចេកទេសទេ ។

ផ្នែកទី២ គឺផ្ទេរការងារយុវជន ពីក្រសួងកិច្ចការនារី យុវជន និង កីឡាមកបញ្ចូលក្នុងក្រសួងថ្មី មានឈ្មោះថា " ក្រសួងអប់រំ យុវជន និង កីឡា " ។ ការងារកីឡា ត្រូវបានផ្ទេរពីក្រសួងវប្បធម៌ មកក្រសួងអប់រំ យុវជន និង កីឡា តែម្តង មិនតាមរយៈក្រសួងកិច្ចការនារី យុវជន និង កីឡាទេ ( កីឡាក្នុងអតីតក្រសួងកិច្ចការនារី យុវជន និង កីឡាមិនទាន់មានការងារអ្វីគួរកត់សំគាល់ ហើយត្រូវផ្ទេរទេ ) ។

ទីតាំងក្រសួងអប់រំ យុវជន និង កីឡា ដែលបានរៀបចំជាថ្មីក្នុងរាជរដ្ឋាភិបាលកម្ពុជា បានយកទីតាំងអតីតក្រសួងឧត្តសិក្សានិងបច្ចេកទេស (ខាងត្បូងអនុវិទ្យាល័យចតុមុខ ខាងក្រោយព្រះបរមរាជវាំង អាគារលេខ ៨០ តាមបណ្តោយផ្លូវព្រះនរោត្តម ) ជាទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡារហូតមក ។

ទីតាំងក្រសួងអប់រំ ខាងត្បូងវិមានឯករាជ្យ ក៏រើមកទីតាំងក្រសួងថ្មី នៅចុងខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

## II- ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

១- ក្រឹត្យច្បាប់លេខ ៤ក្រច.ក្រប្រ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្ត នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

ក្រឹត្យច្បាប់នេះបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ ។ ព្រមជាមួយនេះ ក្រឹត្យច្បាប់ បានកំណត់ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រសួង ហើយមានភ្ជាប់រចនាសម្ព័ន្ធក្រសួង ដូចខាងក្រោម ÷

- លេខាធិការដ្ឋាន
- នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

- នាយកដ្ឋាន អប់រំមនុស្សចាស់
- នាយកដ្ឋានចាត់តាំងកម្មាភិបាល
- មជ្ឈមណ្ឌលនិពន្ធកម្មវិធី និងសៀវភៅសិក្សា
- នាយកដ្ឋានហិរញ្ញវត្ថុ និងសុក្រឹតការ
- នាយកដ្ឋានឧត្តមសិក្សា និងមុខជំនាញ

អង្គភាពទាំង៧នេះមានឋានៈស្មើនាយកដ្ឋាន ។

ក្នុងការអនុវត្ត មន្ត្រីរាជការហៅតាមលេខរៀង សំរាប់សំគាល់អង្គភាពទាំងនេះ គឺ ÷

ក្រុម១ សំគាល់ លេខាធិការដ្ឋាន ( ក្រោយមកហៅថា មន្ទីរ )

ក្រុម២ - នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា

ក្រុម៣ - នាយកដ្ឋានអប់រំមនុស្សចាស់(បច្ចុប្បន្ន ជានាយកដ្ឋានអប់រំក្រៅប្រព័ន្ធ)

ក្រុម៤ - នាយកដ្ឋានចាត់តាំងកម្មាភិបាល ( ក្រោយមក ហៅនាយកដ្ឋានចាត់តាំងបច្ចុប្បន្ន ជានាយកដ្ឋានបុគ្គលិក )

ក្រុម៥ សំគាល់ មជ្ឈមណ្ឌលនិពន្ធកម្មវិធី និងសៀវភៅសិក្សា

ក្រុម៦ - នាយកដ្ឋានហិរញ្ញវត្ថុ និងសុក្រឹតការ ( បច្ចុប្បន្ន នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ )

ក្រុម៧ សំគាល់ នាយកដ្ឋានឧត្តមសិក្សា និងមុខជំនាញ

ក្នុងដំណាក់កាលស្តារ និងកសាងប្រទេសក្រោយពេលឆ្លងកាត់ សម័យកាលវិនាសកម្ម ១៩៧៥-៧៩ ពិសេសការបើកសាលារៀននៅខែ កុម្ភៈ ឆ្នាំ១៩៧៩ មជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា ( ក្រុម៥ ) មានភារកិច្ចធំធេងណាស់ ព្រោះនៅពេលនោះ គ្មាននៅសេសសល់ឯកសារអ្វីសំរាប់រៀនទេ ។ សាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិ សាស្ត្រាចារ្យបរិញ្ញា សាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ អធិការបឋមសិក្សា...... ត្រូវបានប្រមូលនៅទីនេះ ដើម្បីកសាងកម្មវិធី និងសៀវភៅសិក្សា ។

នាយកដ្ឋានចាត់តាំងកម្មាភិបាល មានភារកិច្ចយ៉ាងសំខាន់ក្នុងការកសាងជួរមន្ត្រីគ្រប់គ្រងក្នុងដំណាក់កាលប្រវត្តិសាស្ត្រថ្មីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ពិសេសនៅថ្នាក់មជ្ឈិម ដោយឆ្លងគោលការណ៍ទៅគណៈចាត់តាំងមជ្ឈិមរបស់បក្ស ។

យើងអាចកត់សំគាល់បានថា ពេលនោះ ការចាត់តាំងមន្ត្រីគ្រប់គ្រងនៅតាមខេត្តក្រុងរហូតដល់ការជ្រើសរើសផងក៏មាន ត្រូវបានអនុវត្តតាមខ្សែទទឹង ព្រោះខេត្ត-ក្រុងចំណុះផ្ទាល់ក្រុមប្រឹក្សាប្រជាជនបដិវត្ត ហើយមានថវិការបស់ខ្លួន ។

២- ការបង្កើតអង្គភាពផ្សេងៗទៀតរបស់ក្រសួងអប់រំ

នៅដំណាក់កាលទី២ ក្រុមប្រឹក្សារដ្ឋមន្ត្រី ( រដ្ឋាភិបាលសម័យនោះ ) បានចេញអនុក្រឹត្យបង្កើតអង្គភាពថ្នាក់ នាយកដ្ឋាន ចំនួន ៤ ទៀតគឺ ៖

- នាយកដ្ឋានផែនការនិងហិរញ្ញកិច្ច
- វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ
- មជ្ឈមណ្ឌលចែកផ្សាយនិងបណ្ណាល័យ
- គណៈកម្មាធិការត្រួតពិនិត្យ

អនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ១៩៨៤ បានកែប្រែឈ្មោះមជ្ឈមណ្ឌលនិពន្ធកម្មវិធីនិងសៀវភៅសិក្សា ជា គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ។

នាយកដ្ឋានឧត្តមសិក្សា និងមុខជំនាញក៏ដូរឈ្មោះ ជា នាយកដ្ឋានឧត្តមសិក្សានិងសិក្សាឯកទេស ។

និន្នាការបញ្ចូល មជ្ឈមណ្ឌលចែកផ្សាយនិងបណ្ណាល័យ ជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មានតាំងពីឆ្នាំ១៩៩១ ក្នុងលិខិតលេខ ៧៩២ អរ-ចត ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ១៩៩១ របស់រដ្ឋមន្ត្រីក្រសួងអប់រំ ( លោក យស់  សុន ) ។ ជារួម ក្រសួងអប់រំ មាននាយកដ្ឋាននិងអង្គភាពឋានៈ ស្មើនាយកដ្ឋាន ទាំងអស់ចំនួន ១១ ។

៣- ការអនុវត្តក្នុងដំណាក់កាល ១៩៩៣-១៩៩៨ នៃក្រសួងអប់រំ យុវជន និង កីឡា (មុនចេញអនុក្រឹត្យលេខ ២១ អនក្រ-បក) ក្រសួងអប់រំចាស់មាន ១១ អង្គភាព ឋានៈស្មើនាយកដ្ឋាន ។

ពេលបង្កើតក្រសួងឧត្តមសិក្សានិងបច្ចេកទេស នាយកដ្ឋានឧត្តមសិក្សានិងសិក្សាឯកទេសនៃក្រសួងអប់រំ ត្រូវដាច់ចេញពីក្រសួងនេះ ហើយមកធ្វើជាសេនាធិការ អោយក្រសួងថ្មីវិញ ។

ពេលបញ្ចូលក្រសួងអប់រំ ក្រសួងឧត្តមសិក្សានិងបច្ចេកទេសបញ្ចូលការងារយុវជន និងការងារកីឡានៃក្រសួងកិច្ចការនារី យុវជន និង កីឡា មកជាក្រសួងអប់រំ យុវជន និង កីឡាតែមួយចាប់ពីពេល បង្កើតរាជរដ្ឋាភិបាលកម្ពុជា មានការកែប្រែមួយចំនួន ៖

ក- អង្គភាពបញ្ចូលថ្មីៈ នាយកដ្ឋានអប់រំកាយនិងកីឡា
សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា
នាយកដ្ឋានឧត្តមសិក្សានិងសិក្សាឯកទេស
នាយកដ្ឋានយុវជន

នាយកដ្ឋានអប់រំកាយនិងកីឡា សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា ជាអង្គភាពចាស់របស់ក្រសួងវប្បធម៌ ។ នាយកដ្ឋានឧត្តមសិក្សានិងសិក្សាឯកទេស ជាអង្គភាពចាស់របស់ក្រសួងអប់រំ ។ កន្លងមកអង្គភាពទាំង៣នេះមានលិខិតបទដ្ឋានបង្កើតត្រឹមត្រូវអស់ហើយ ។

ដោយឡែក នាយកដ្ឋានយុវជន ជាករណីផ្សេង ។

ក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន ឯកឧត្តមរដ្ឋមន្ត្រី គៀត សុគន្ធ នៃក្រសួងកិច្ចការនារី យុវជន និង កីឡា បានចេញសេចក្តីសំរេចលេខ ០៥០ ស-កនយុវក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ១៩៩៣ តែងតាំងមន្ត្រី ៤ រូបជានាយកយុវជន នាយករងយុវជន នាយករងកាយរិទ្ធ នាយករងទទួលបន្ទុកមជ្ឈមណ្ឌលនិងសមាគម ។ ជាគោលការណ៍ នាយកដ្ឋានយុវជនមិនទាន់ត្រូវបានបង្កើតតាមនីតិវិធីនៅឡើយ ( អនុក្រឹត្យ ) ។ ការងារនាយកដ្ឋាននេះក៏ដំណើការ ពី ពេលបង្កើតក្នុងក្រសួងកិច្ចការនារី យុវជន និង កីឡា រហូតមកក្នុងក្រសួងអប់រំ យុវជន និង កីឡា ។

ខ- អង្គភាពបញ្ចូលភារកិច្ចជាមួយអង្គភាពផ្សេង

គណៈកម្មាធិការត្រួតពិនិត្យ ដែលជាអង្គភាពឋានៈស្មើនាយកដ្ឋាន មានសកម្មភាពជាវិជ្ជមានក្នុងអតីតក្រសួងអប់រំ ។ ពេលដែលក្រសួងអប់រំ យុវជន និង កីឡា ត្រូវបានបង្កើតឡើង ហើយប្តូរទីតាំងមកនៅខាងក្រោយព្រះបរមរាជវាំង គណៈកម្មាធិការត្រួតពិនិត្យមានការប្រែប្រួល២យ៉ាង ÷

* កាលនៅទីតាំងអតីតក្រសួងអប់រំ អង្គភាពនេះមានទីតាំងផ្ទាល់របស់ខ្លួន នៅមុខនាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។ នៅទីតាំងថ្មីរបស់ក្រសួងដែលតូចចង្អៀតផង ការរៀបរយអង្គភាពតាមរចនាសម្ព័ន្ធថ្មីពុំទាន់ល្អផង អង្គភាពត្រួតពិនិត្យក៏ពុំទាន់មានទីតាំងច្បាស់លាស់ដែរ ។

* លោកអ៊ុំ គីមផន ដែលជាប្រធានគណៈកម្មាធិការត្រួតពិនិត្យតាំងពីពេលបង្កើតអង្គភាព អង្គភាពមកក៏ត្រូវចូលនិវត្ត នៅតែលោក ភុំ ភិន តែម្នាក់ឯង ។

ដោយការងារត្រួតពិនិត្យនេះមានពាក់ព័ន្ធច្រើននឹងការងារបុគ្គលិក ជាបណ្តើរៗ លោក ភុំ ភិន ក៏បំពេញភារកិច្ចក្នុងនាយកដ្ឋានបុគ្គលិក ទទួលបន្ទុកការងារត្រួតពិនិត្យ ។ ក្រោយមកទៀតនៅឆ្នាំ១៩៩៦ លោក ឆយ អូន ប្រធានស្តីទីនាយកដ្ឋានបុគ្គលិកក៏បានបង្កើតផ្នែក អគ្គាធិការដ្ឋាន -ជាផ្នែកមួយរបស់នាយកដ្ឋាន មិនចំណុះការិយាល័យណាឡើយ ហើយលោកកាន់ផ្នែកនេះដោយផ្ទាល់ ព្រោះសភាពការណ៍ការងារតំរូវយ៉ាងនេះ. ។ លោកបានកំណត់ភារកិច្ចបណ្តោះអាសន្នរបស់អគ្គាធិការដ្ឋានសំរាប់ការអនុវត្ត ។

អគ្គាធិការដ្ឋានបានបំពេញការងារតាមរយៈនាយកដ្ឋានបុគ្គលិក ។ អគ្គាធិការដ្ឋានដំបូងឡើយពុំត្រូវបានគេទទួលស្គាល់នៅឡើយទេ ព្រោះមិនបានបង្កើតដោយប្រកាសរបស់ក្រសួង ។ ម្យ៉ាង

ទៀត ដំបូងឡើយ មានអ្នកខ្លះយល់ថា ភារកិច្ចរបស់អគ្គាធិការដ្ឋាននេះជាន់នឹងភារកិច្ចរបស់ការិយាល័យអធិការកិច្ចបឋមសិក្សា និង ការិយាល័យអធិការកិច្ចមធ្យមសិក្សាដែលបានបង្កើតដោយប្រកាសក្រសួងនៅនាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។ រយៈពេលប្រហែលមកដល់ដើមឆ្នាំ១៩៩៨ ទើបការងារ របស់អគ្គាធិការដ្ឋាន ត្រូវបានគេទទួលស្គាល់ថាសំខាន់ ហើយមិនជាន់ភារកិច្ចគេដទៃ ។ អគ្គាធិការដ្ឋាន ចែកចេញជា ២ គឺ ជំនាញអប់រំ ( គឺ និយាយដល់អប់រំ យុវជន និង កីឡាទាំងមូល ) និងជំនាញរដ្ឋបាល និងហិរញ្ញវត្ថុ ។

នៅក្នុងអនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ក្រសួងអប់រំ យុវជន និង កីឡា ជាក្រសួងធំត្រូវមាន អគ្គាធិការដ្ឋាន ឋានៈស្មើអគ្គនាយកដ្ឋាន ។ ការរៀបចំអគ្គាធិ-ការដ្ឋាននៅក្នុងនាយកដ្ឋានបុគ្គលិកពេលនោះ គឺដើម្បីគំរូវតាមការងារផង និងបង្កើតលំនាំឈានទៅរកអគ្គាធិការដ្ឋាន ដែលនឹងកំណត់ដោយអនុក្រឹត្យថ្មីផង ។

គ- អង្គភាពថ្មី

* អង្គភាពផែនការ និងសំរបសំរួលជំនួយ

នាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ត្រូវបានបង្កើតឡើងក្នុងដំណាក់កាលទី២ នៃការរៀបចំ អតីតក្រសួងអប់រំ ( ក្រោយ ក្រឹត្យ-ច្បាប់ លេខ ០៤ ក្រច-ក្រប ដែលមានបង្កើតអង្គភាព និង នាយកដ្ឋានចំនួន ៧ អតីតក្រសួងអប់រំ មានអង្គភាព និង នាយកដ្ឋានចំនួន ៤ ទៀត ត្រូវបានបង្កើត ) ។

រវាងឆ្នាំ១៩៩៥ សភាពការណ៍អភិវឌ្ឍន៍របស់ក្រសួងអប់រំ យុវជន និង កីឡា បានទទួលជំនួយបរទេសជាច្រើន ដែលគំរូវអោយមានអង្គភាពមួយទទួលខុសត្រូវ ។ អង្គភាពផែនការ និងសំរបសំរួល ជំនួយ ត្រូវបានបង្កើតឡើង ដោយបំបែកពីនាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ។ លោក ឌុយ ផេង អនុប្រធាននាយកដ្ឋាន ទៅពីនាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ទទួលបន្ទុកអង្គភាពថ្មីនេះ ។ នាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៅបន្តប្រើឈ្មោះនេះដដែល បំពេញភារកិច្ចតែផ្នែកហិរញ្ញកិច្ច ដោយរង់ចាំអនុក្រឹត្យថ្មីរបស់ក្រសួង ដែលរៀបចំក្រសួងជាថ្មី ដែលបំបែកអង្គភាពចាស់នេះជា ២អង្គភាព ស្ថាពរ ឋានៈស្មើនាយកដ្ឋាន ។

* ខុទ្ទកាល័យរដ្ឋមន្ត្រី

ខុទ្ទកាល័យរដ្ឋមន្ត្រី ជាអង្គភាពដោយឡែក ដែលមានបេសកកម្មជាជំនួយរដ្ឋមន្ត្រី ក្នុងឋានៈរបស់លោកជាអ្នកនយោបាយ ផ្អែកលើការងារក្នុងរង្វង់រាជរដ្ឋាភិបាល និងរដ្ឋសភាជាតិ ក៏ដូចជាក្នុងឋានៈលោកជាអ្នកដឹកនាំរដ្ឋបាលក្នុងក្រសួងអប់រំ យុវជន និងកីឡាទាំងមូល ។ អំពីខុទ្ទកាល័យរបស់

ប្រធានស្ថាប័ន អនុក្រឹត្យលេខ ២០ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ បានកំណត់ច្បាស់ ត្រង់ជំពូកទី ៦ មាត្រា១៦ដល់២៣ ។

<u>ដំណាក់កាលទី១</u> - ក្នុងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន ដែលមានក្រសួងអប់រំ និង ក្រសួងឧត្តមសិក្សា និងបច្ចេកទេស ជាក្រសួងដោយឡែកពីគ្នា ក្រសួងអប់រំ មិនទាន់រៀបចំអោយមាន ខុទ្ទកាល័យទេ គឺប្រើភារកិច្ចរបស់មន្ទីរដែលធ្លាប់មានពីមុនដដែល ។ ចំពោះ ក្រសួងឧត្តមសិក្សា និង បច្ចេកទេស ការរៀបចំខុទ្ទកាល័យ ក៏ពុំទាន់ជាក់លាក់ដែរ ។

<u>ដំណាក់កាលទី២</u> - ក្នុងរាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និង កីឡា ប្រើរចនា សម្ព័ន្ធចំរុះ គឺមានមន្ទីរ ដែលផ្ទេរពីអតីតក្រសួងអប់រំផង មានខុទ្ទកាល័យដែលបង្កើតដោយរដ្ឋមន្ត្រី ប្រធានស្ថាប័ន តាមស្មារតីនៃការគ្រប់គ្រងថ្មីផង ។ តាំងពីជំនាន់ ឯកឧត្តមអ៊ឹង ហួត ជារដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា ឆ្នាំ១៩៩៤ លោក តាន់ បៀន កាន់ខុទ្ទកាល័យ និងក្រោយមកទៀត ជំនាន់ ឯកឧត្តម រដ្ឋមន្ត្រី តុល ឡោះ លោក តូ ហ្គារី កាន់ខុទ្ទកាល័យ ។

ជាគោលការណ៍ បើមានមន្ទីរ មិនចាំបាច់មានខុទ្ទកាល័យទេ ព្រោះមន្ទីររ៉ាប់រងការងារ ក្រសួងផង ការងារថ្នាក់ដឹកនាំផង ក្នុងស្មារតីឯកបក្ស ។ បើមានខុទ្ទកាល័យហើយ មន្ទីរ ត្រូវក្លាយជា នាយកដ្ឋានរដ្ឋបាល ដោយទុកភារកិច្ចសំរាប់ថ្នាក់ដឹកនាំ ពិសេសរបស់ប្រធានស្ថាប័នអោយមកខុទ្ទកាល័យ បំពេញ ។ នាយកខុទ្ទកាល័យ ត្រូវផ្លាស់ប្តូរទៅតាមប្រធានស្ថាប័ន ។

ជាក់ស្តែង ក្នុងការអនុវត្តពី ១៩៩៣ ដល់ ១៩៩៨ ( មុនចេញអនុក្រឹត្យលេខ ២១ អនក្រ-បក ) មន្ទីរក៏នៅមានឈ្មោះ ខុទ្ទកាល័យក៏មាន តែមន្ទីរទុកភារកិច្ចសំរាប់ថ្នាក់ដឹកនាំ អោយទៅ ខុទ្ទកាល័យ ។ និយាយខ្លី មន្ទីរ ដែលមានលោក ហ៊ាន ខុន ជាប្រធាន បំពេញភារកិច្ចរដ្ឋបាលរបស់ ក្រសួង តែឈ្មោះជាមន្ទីរ ។ ការងាររវាងអង្គភាពទាំង ២ ក៏បានសំរបសំរួលគ្នារហូតមក ដោយមានការ ខ្វះចន្លោះខ្លះ ដោយខ្វះលិខិតបទដ្ឋានជាមូលដ្ឋាន និង ការខ្វះបទពិសោធ នៃអ្នកកាន់ការងារថ្មី ។

*មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺន ( CNE ) ជាកន្លែងបង្វឹកកីឡាករជំរើសជាតិ សំរាប់ការ ប្រកួតអន្តរជាតិនានា ដែលបង្កើតឡើងរវាងចុងឆ្នាំ ១៩៩៣ ។ ទីតាំងអង្គភាពនេះស្ថិតក្នុងអតីតបូរីកីឡា ( មុន ១៩៧៥ ) ។

*វិទ្យាស្ថានភាសាជាតិ

អង្គភាពនេះ ត្រូវបានបង្កើតឡើងក្រោយឆ្នាំ១៩៩៣ ដោយលោក ឡុង សៀម បណ្ឌិត សាស្ត្រាចារ្យដើមកំណើតខ្មែរ សញ្ជាតិរុស្ស៊ី ហើយមានទីតាំងក្នុងអាគារមួយនៅក្នុង សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញទី ២ ខាង កើតផ្សារពោធិ៍ចិនតុង ។ ក្នុងដំហានកកើតដំបូង ក្របខណ្ឌមន្ត្រីរាជការមាន ប្រហែល១០នាក់ ប៉ុណ្ណោះ ។

# រចនាសម្ព័ន្ធក្រសួងអប់រំ យុវជន និងកីឡា

## ថ្នាក់កណ្តាល

ក្រោយពេលបោះឆ្នោត - 1993



ឧបសម្ព័ន្ធអនុក្រឹត្យលេខៈ ២១ អនក្រ.បក
ចុះថ្ងៃទី ២៣ មិនា ១៩៩៨

# អង្គការលេខរបស់ក្រសួងអប់រំ យុវជន និង កីឡា



# ថ្នាក់ដឹកនាំក្រសួង

( ខែ កុម្ភៈ ១៩៧៩ ដល់ ខែ កក្កដា ឆ្នាំ ១៩៩៨ )

| ដំណាក់កាល | ឈ្មោះក្រសួង | រដ្ឋមន្ត្រី | រយៈពេលកាន់មុខតំណែង |
|---|---|---|---|
| សាធារណរដ្ឋប្រជាមានិតកម្ពុជា និង | ក្រសួង អប់រំ | ចាន់ វ៉ែន | កុម្ភៈ ១៩៧៩ ដល់ មករា ១៩៨២ |
| រដ្ឋកម្ពុជា ( ដល់ពេលបោះ ឆ្នោត | | ប៉ែន ណាវុឌ | មករា ១៩៨២ ដល់ មករា ១៩៩០ |
| ខែឧសភា ឆ្នាំ១៩៩៣ ) | | យស់ សុន | ១៩៩០ ដល់ តុលា ១៩៩២ ? |
| | | អ៊ឹម ឈុនលឹម | តុលា ១៩៩២ ? |
| រដ្ឋាភិបាលបណ្តោះអាសន្ន | ក្រសួង អប់រំ | ម៉ុម ជឹមហ៊ុយ | ២-៧-៩៣ - គុណ គីមតេង អនុរដ្ឋមន្ត្រី |
| ( ពហុបក្ស ) | ក្រសួង ឧត្តមសិក្សានិងបច្ចេកទេស | តុល ឡោះ | ២-៧-៩៣- ហេង វង្សប៊ុនឆាត អនុរដ្ឋមន្ត្រី |
| | ក្រសួង កិច្ចការនារី យុវជននិងកីឡា | គៀត សុគន្ធ | ២-៧-៩៣- ឱម រដ្ឋសាឌី អនុរដ្ឋមន្ត្រី |
| រាជរដ្ឋាភិបាលកម្ពុជា | ក្រសួង អប់រំ យុវជន និង កីឡា | អ៊ឹង ហួត | វិច្ឆិកា ១៩៩៣ ដល់ កក្កដា ១៩៩៤ |
| ( ពហុបក្ស ) | | | ម៉ុម ជឹមហ៊ុយ រដ្ឋលេខាធិការ |
| | | តុល ឡោះ | កក្កដា ១៩៩៤ ដល់ កក្កដា ១៩៩៧ |
| | | | គា សាហាន រដ្ឋលេខាធិការ |

* ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជារហូតមករដ្ឋកម្ពុជាដល់ពេលបោះឆ្នោត១៩៩៣ ក្រៅពីរដ្ឋមន្ត្រីក្រសួងអប់រំ មានអនុរដ្ឋមន្ត្រីច្រើនរូបទៀត ៖ ហង់ ជួន ( ដំបូងជាឧបការី , ក្រោយមកជាអនុរដ្ឋមន្ត្រី ) , ច័ន្ទ មិន ( ដំបូងជាឧបការី , ក្រោយមកជាអនុរដ្ឋមន្ត្រី ) , ស កាពុន , ឯក សំអុល , ម៉ុម ជឹមហ៊ុយ ។

* ក្នុងសម័យរាជរដ្ឋាភិបាលកម្ពុជា ( ពហុបក្ស ) គិតត្រឹមខែកក្កដា ១៩៩៨ មុនបោះឆ្នោត ក្រៅពីរដ្ឋមន្ត្រី តុល ឡោះ ក្រសួងអប់រំយុវជននិងកីឡាមាន រដ្ឋលេខាធិការ ១ រូប-គា សាហាន , អនុរដ្ឋលេខាធិការ ៥ រូប-ពូ ដារ៉ានី , ប៊ុន សុខ , ចាយ តារាវិចិត្រ ( នារី ) , ជ័យ ចាប , សានឌីរ ជឹម៉ុងតៀ ។ ពេលឯកឧត្តម អ៊ឹង ហួត ជារដ្ឋមន្ត្រី ឯកឧត្តម ម៉ុម ជឹមហ៊ុយ ជារដ្ឋលេខាធិការ ។

* ចាប់ពីខែកក្កដា ១៩៩៧ ក្រោយពេលឯកឧត្តមរដ្ឋមន្ត្រី តុល ឡោះ ទៅបំពេញបេសកកម្មនៅបរទេស ( ភ្ជាប់នឹង ព្រឹត្តិការណ៍ កក្កដា ) ឯកឧត្តម គា សាហាន រដ្ឋលេខាធិការទទួលបន្ទុកដឹកនាំការងារក្រសួង រហូតដល់ពេលបោះឆ្នោត កក្កដា ១៩៩៨ ។

ដំណើរការអង្គភាពប្រព្រឹត្តទៅបានដោយសារជំនួយបរទេស ។

ក្នុងការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាព លោក ឡុង សៀម បានរៀបចំពង្រាងអនុក្រឹត្យមួយដោយឡែកតាមរយៈក្រសួង ដើម្បីចេញមុនអនុក្រឹត្យស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។ តាមរយៈពង្រាងអនុក្រឹត្យនោះ អង្គភាពវិទ្យាស្ថានភាសាជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

នៅជំហានទី ២ លោក ឡុង សៀម បានកែពង្រាងអនុក្រឹត្យចាស់របស់លោក ដើម្បីអោយវិទ្យាស្ថាននេះជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយ ។ វិទ្យាស្ថានភាសាជាតិ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និង កីឡា និង ក្រោមអាណាព្យបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ដោយករណីនេះអាចនាំអោយយឺតយ៉ាវដល់ការចេញអនុក្រឹត្យរបស់ក្រសួងអប់រំ យុវជន និង កីឡា ថ្នាក់ដឹកនាំក្រសួងសហការជាមួយទីស្ដីការគណៈរដ្ឋមន្ត្រី សំរេចអោយចេញអនុក្រឹត្យ របស់ក្រសួងអោយបានឆាប់មុនអនុក្រឹត្យរបស់វិទ្យាស្ថាននេះ ព្រោះបញ្ហាក្រសួងមានលក្ខណៈមូលដ្ឋាន និង ចាំបាច់ជាង ។

ឃ- ប្រធានអង្គភាព

ឈ្មោះអង្គភាព និងប្រធានអង្គភាព

( ពី ១៩៧៩ ដល់ មុនពេលចេញ អនុក្រឹត្យលេខ ២១ អនក្រ-បក )

| លរ | អង្គភាព | ឈ្មោះថ្មីរបស់អង្គភាព | ប្រធានអង្គភាព |
|---|---|---|---|
| ១ | លេខាធិការដ្ឋាន | មន្ទីរ | ហង់ ជួន, ម៉ុម ជឹមហ៊ុយ, អ៊ឹម សិទ្ធី, ហ៊ាន ខុន |
| ២ | នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា | គ្មានប្ដូរឈ្មោះ | ឆាយ គីម, លាង ងួនលី ( អនុប្រធានទទួលបន្ទុករួម) |
| ៣ | នាយកដ្ឋានអប់រំ មនុស្សចាស់ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ប៉ែន ណាវុធ, អ.ស ឃុន ង៉ែត, សូ ឈុន |
| ៤ | នាយកដ្ឋានចាត់តាំងកម្មាភិបាល | នាយកដ្ឋានចាត់តាំង<br>នាយកដ្ឋានបុគ្គលិក | ពត ឆន ( ៧៩-៨៤ ), កុយ វ៉ុន ( ៨៤-៩៥ ),<br>ឆយ អួន ( ប្រធានស្ដីទី ចាប់ពី១៩៩៥ ) |
| ៥ | មជ្ឈមណ្ឌលនិពន្ធកម្មវិធី និង សៀវភៅសិក្សា | គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ | ស កាពុន , កញ្ញា ដោម សាណែត , ស៊ុន ងួនហេង , កើ ណៃលាង ( ចាប់ពី ១៩៩៧ ) |
| ៦ | នាយកដ្ឋានហិរញ្ញវត្ថុនិងសុក្រិតការ | . នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រិតការ | ផៃ ផេង , អ៊ុំ គីមផន , គា សាហន, អ.ស ហួរ សីរី ( អនុប្រធានទទួលបន្ទុករួម ) |
| ៧ | នាយកដ្ឋានឧត្តមសិក្សានិងមុខជំនាញ | នាយកដ្ឋានឧត្តមសិក្សា និង សិក្សាឯកទេស | ឯក សំអុល, យ៉ង់ ធី , ពេជ សោភ័ន |

| | | | |
|---|---|---|---|
| ៨ | នាយកដ្ឋានផែនការ និងហិរញ្ញកិច្ច | គ្មានប្តូរឈ្មោះ | អ៊ិន នាង , ហង់ សុវ៉ុន ( អនុប្រធានទទួលបន្ទុករួម ចាប់ពី ១៩៩៤ ) |
| ៩ | វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ | នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ | សូ មុយឃៀង ( ចាប់ពី១៩៨៦ ដែលអង្គភាពនេះត្រូវបានបង្កើត ) |
| ១០ | មជ្ឈមណ្ឌលចែកផ្សាយនិងបណ្ណាល័យ | គ្មានប្តូរឈ្មោះ | យ៉ង់ យ៉ាណូ , សំម សនីរ ( អនុប្រធានទទួលបន្ទុករួម ) |
| ១១ | គណៈកម្មាធិការត្រួតពិនិត្យ | គ្មានប្តូរឈ្មោះ | អ៊ុំ គឹមផន ( ផ្ទេរមកពីនាយកដ្ឋានហិរញ្ញវត្ថុ និងសុក្រឹតការ ) |

* <u>កំណត់សំគាល់</u> - ប្រធានអង្គភាពទាំងនេះកាន់មុខតំណែងបន្តបន្ទាប់គ្នា ។

## ឈ្មោះអង្គភាព និងប្រធានអង្គភាព
## ( រៀបចំជំហានដំបូងពេលចេញអនុក្រឹត្យលេខ ២១ អនក្រ-បក
## តាមលិខិតបង្គាប់ការលេខ ២៧៤ អយក.បុ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ១៩៩៨ )

| ល.រ | អង្គភាព | ប្រធានអង្គភាព | ផ្សេងៗ |
|---|---|---|---|
| ១ | នាយកដ្ឋានរដ្ឋបាល | យស់ អ៊ាង | ពីមុន ជាអនុប្រធានមន្ទីរ |
| ២ | នាយកដ្ឋានបុគ្គលិក | ឆយ អួន | ពីមុន ជាប្រធានស្តីទី នាយកដ្ឋានបុគ្គលិក |
| ៣ | នាយកដ្ឋានហិរញ្ញវត្ថុ | ហង់ សុវ៉ុន | ពីមុន ជាអនុប្រធាននាយកដ្ឋានទទួលបន្ទុករួម |
| ៤ | នាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ | ជា អឿង | ពីមុន ជាអនុប្រធានផែនការ និងហិរញ្ញកិច្ច |
| ៥ | នាយកដ្ឋានផែនការ | ឌុយ ផេង | ពីមុន ជាប្រធាន អង្គភាពផែនការ និងសំរបសំរួលជំនួយ |
| ៦ | នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | យ៉ង់ យ៉ាណូ | ពីមុន ជាអនុប្រធានមន្ទីរ |
| ៧ | នាយកដ្ឋានឧត្តមសិក្សា | ចាន់ ធឿន | ពីមុន ជាអនុប្រធាននាយកដ្ឋានឧត្តមសិក្សា និងសិក្សាឯកទេស |
| ៨ | នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ពេជ សោភ័ន | ពីមុន ជាប្រធាននាយកដ្ឋានឧត្តមសិក្សា និងសិក្សាឯកទេស |
| ៩ | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | អ.ស ហួរ ស៊ី | ពីមុន ជាអនុប្រធានទទួលបន្ទុករួម |
| ១០ | នាយកដ្ឋានអប់រំកាយ និង កីឡា | មាស សារិន | ពីមុន ជាប្រធាននាយកដ្ឋាននេះ |
| ១១ | នាយកដ្ឋានបឋមសិក្សា និងមត្តេយ្យសិក្សា | សៀង ទាក | ពីមុន ជាអនុប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា |
| ១២ | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | លាង ងួនលី | ពីមុន ជាអនុប្រធានទទួលបន្ទុករួម នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា |
| ១៣ | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | កើ ណៃលាង | ពីមុន ជាប្រធានគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ |

| | | | | |
|---|---|---|---|---|
| ១៤ | នាយកដ្ឋានសុខភាពសិក្សា | ស្លាត | ឆាន | ពីមុន ជាប្រធានអង្គភាពអនាម័យសិក្សាចំណុះមន្ទីរ |
| ១៥ | នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ | សូ | មុយឃៀង | ពីមុន ជាប្រធានវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រ |
| ១៦ | នាយកដ្ឋានអប់រំ ក្រៅប្រព័ន្ធ | សូ | ឈុន | ពីមុន ជាប្រធានអង្គភាពនេះ |

* <u>កំណត់សំគាល់</u>

១- នាយកដ្ឋានយុវជន , នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ , វិទ្យាស្ថានជាតិអប់រំកាយ និង កីឡា , អធិការដ្ឋានអប់រំ , អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានរៀបចំអោយមានប្រធានអ្នកទទួលខុសត្រូវនៅឡើយ ក្នុងជំហានដំបូងនេះ ។

២- ពេលចេញអនុក្រឹត្យលេខ ២១ អនក្រ-បក នេះ ការរៀបចំគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាក្រោមឱវាទទីស្តីការគ្មានអ្វីប្រែប្រួលទេ ។

នៅខែ មិថុនា អនុក្រឹត្យលេខ ១៦៦ អនក្រ.តត ចុះថ្ងៃទី ០៨ មិថុនា ឆ្នាំ១៩៩៨ របស់រាជរដ្ឋាភិបាល បានតែងតាំងមន្ត្រីគ្រប់គ្រងថ្នាក់អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋានចំនួន ២៦ នាក់ ដូចខាងក្រោម អោយមានឋានៈស្ថាពរ បន្ទាប់ពីលិខិតបង្គាប់ការលេខ ២៧៤ អយក.បុ ដែលបណ្តោះអាសន្នកន្លងមក ៖

| | |
|---|---|
| ១- លោក ឆយ អូន | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ២- លោក ឧុយ ផេង | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៣- លោក ជា អឿង | ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ៤- លោក យស់ អ៊ាង | ប្រធាននាយកដ្ឋានរដ្ឋបាល |
| ៥- លោក ហង់ សូវុន | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ៦- លោក យ៉ង់ យ៉ាណូ | ប្រធាននាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ |
| ៧- លោក សូ ឈុន | អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ |
| ៨- លោក កើ ណៃលាង | អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ |
| ៩- លោក សៀង ទាក | ប្រធាននាយកដ្ឋាន បឋម និង មត្តេយ្យសិក្សា |
| ១០- លោក លាង ងួនលី | ប្រធាននាយកដ្ឋាន មធ្យមសិក្សា ចំណេះទូទៅ |
| ១១- លោក អ៊ិន ថេរ | ប្រធាននាយកដ្ឋាន អប់រំក្រៅប្រព័ន្ធ |

១២- អ្នកស្រី យិន វ៉ាន់ថា ប្រធាននាយកដ្ឋាន ស្រាវជ្រាវគរុកោសល្យ

១៣- លោក ស្លាត ឆាន ប្រធាននាយកដ្ឋានសុខភាពសិក្សា

១៤- លោក ស៊ុង វ៉ាន់ថន ប្រធានគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ

១៥- អ្នកស្រី ហួរ ស៊ីរី អគ្គនាយករងនៃអគ្គនាយកដ្ឋាន ឧត្តមសិក្សា បច្ចេកទេសនិងវិជ្ជាជីវៈ

១៦- លោក ចាន់ ពន អគ្គនាយករង នៃនាយកដ្ឋានឧត្តមសិក្សា បច្ចេកទេសនិងវិជ្ជាជីវៈ

១៧- លោក ចាន់ ជឿន ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

១៨- លោក ណាត ប៊ុនធឿន ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

១៩- លោក ស៊ិន សំណាង ប្រធាននាយកដ្ឋាន ស្រាវជ្រាវវិទ្យាសាស្ត្រ

២០- លោក ឡាក់ សំអាត អគ្គនាយករង នៃនាយកដ្ឋាន យុវជន និងកីឡា

២១- លោក មាស សារិន អគ្គនាយករង នៃអគ្គនាយកដ្ឋាន យុវជន និង កីឡា

២២- លោក វ៉ាន់ សាមេធ អគ្គនាយករង នៃអគ្គនាយកដ្ឋាន យុវជន និង កីឡា

២៣- លោក ឈឹម សាម៉ាញ់ ប្រធាននាយកដ្ឋាន យុវជន

២៤- លោក លី សុមុនី អគ្គាធិការរង នៃអគ្គាធិការដ្ឋាន

២៥- លោក នាង មុត អគ្គាធិការរង នៃអគ្គាធិការដ្ឋាន

២៦- លោក កែវ សាផន ប្រធានអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

នៅខែជាមួយនេះ ព្រះរាជក្រឹត្យលេខ នស.រកត ០៦៩៨-៣១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៨ តែងតាំងថ្នាក់ អគ្គនាយក ៣រូប របស់ក្រសួងអប់រំ យុវជន និង កីឡាគឺ៖

- ឯកឧត្តម ហ៊ាន ខុន អគ្គនាយក រដ្ឋបាលនិងហិរញ្ញវត្ថុ
- ឯកឧត្តម សូ មុយឃៀង អគ្គនាយក អប់រំ
- ឯកឧត្តម ពេជ សោភ័ន អគ្គនាយកឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ

ជាកំណត់សំគាល់ ក្រសួងពុំមានអគ្គនាយកអប់រំកាយនិងកីឡានិងអគ្គាធិការនៅឡើយ ។

៤- <u>គ្រឹះស្ថានសិក្សា</u>

ចាប់ពីពេលបង្កើតក្រសួងអប់រំ នៅឆ្នាំ១៩៧៩ រហូតមកដល់ស្រួងអប់រំ យុវជន និង កីឡា នៅឆ្នាំ ១៩៩៣ និងបន្តរហូតមកដល់ឆ្នាំ១៩៩៨ ពេលចេញអនុក្រឹត្យលេខ ២១ អនក្រ-បក ថ្នាក់កណ្តាលនៃក្រសួងមានគ្រឹះស្ថានសិក្សាគ្រប់កំរិតស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការ ។

# បញ្ជីរាយនាមប្រធាន-អនុប្រធានអង្គភាព
## ( គិតត្រឹម ខែ សីហា ឆ្នាំ ១៩៩៨ )

**១-នាយកដ្ឋានបុគ្គលិក**

១-លោក ឆយ អូន — អគ្គនាយករង
២-លោក ថោង បូរ៉ាន់ — អនុប្រធាន

**២-នាយកដ្ឋានរដ្ឋបាល**

១-លោក យស់ អ៊ាង — ប្រធាន

**៣-នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង សាលារូបករណ៍**

១-លោក យ៉ង់ យ៉ាណូ — ប្រធាន
២-លោកស្រី កាន្ធ នារី — អនុប្រធាន

**៤-នាយកដ្ឋានផែនការ**

១-លោក ឌុយ ផេង — អគ្គនាយករង
២-លោក អ៊ូ អេង — អនុប្រធាន

**៥-នាយកដ្ឋានហិរញ្ញវត្ថុ**

១-លោក ហង់ សូវ៉ុន — ប្រធាន
២-លោក ខៀវ ជន — អនុប្រធាន
៣-លោកស្រី ម៉ែន ម៉ាលី — អនុប្រធាន

**៦-នាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ**

១-លោក ជា អឿង — ប្រធាន
២-លោក វ័ន្ត សារឹម — អនុប្រធាន
៣-លោក ឡោ ឡាត់ — អនុប្រធាន

**៧-នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា**

១-លោក សៀង ទាក — ប្រធាន
២-លោកស្រី សៀង សុវណ្ណនា — អនុប្រធាន
៣-លោក ជន ឈាងលី — អនុប្រធាន

**៨-នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ**

១-លោក លាង ងួនលី — ប្រធាន
២-លោក សៅ សារ៉េត — អនុប្រធាន
៣-លោក ច្រឹង លឹមស៊្រី — អនុប្រធាន

**៩-នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ**

១-លោក អ៊ិន ថេរ — ប្រធាន
២-លោក ណុម ទឹម — អនុប្រធាន

**១០-នាយកដ្ឋានសុខភាពសិក្សា**

១-លោក ស្វាត ឆាន — ប្រធាន

**១១-នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ**

១-លោកស្រី យិន វ៉ាន់ថា — ប្រធាន

**១២-គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ**

១-លោក ស៊ុង វ៉ាន់ថន — ប្រធាន
២-លោក សម សទីរ — អនុប្រធាន
៣-លោក អ៊ិន គឹមស្រ៊ុន — អនុប្រធាន
៤-លោក គាន គឹមស្រ៊ុន — អនុប្រធាន

**១៣-នាយកដ្ឋានយុវជន**

១-លោក ឈឹម សាម៉ាញ — ប្រធាន
២-លោក ជន សូគីម — អនុប្រធាន

**១៤-នាយកដ្ឋានអប់រំកាយ និង កីឡា**

១-លោក យ៉ែម ឧត្តម — អនុប្រធាន
២-លោក ព្រំ ប៊ុណ្ណយី — អនុប្រធាន
៣-លោក ពៅ ដារ៉ា — អនុប្រធាន

**១៥-វិទ្យាស្ថានជាតិអប់រំកាយ និង កីឡា**

១-លោក ប៊ូ ជុំសើ — អនុប្រធាន (រូម)
២-លោក អ៊ូ សុជាតិ — អនុប្រធាន
៣-លោក កែវ សារិន — អនុប្រធាន

**១៦-នាយកដ្ឋានឧត្តមសិក្សា**

១-លោក រត្ន សុខា — អនុប្រធាន

**១៧-នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ**

១-លោក ណាត ប៊ុនរឿន — ប្រធាន
២-លោក លឹម ប៉េង — អនុប្រធាន

### ១៨-នាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ

១-លោក ចាន់ ជឿន ប្រធាន

២-លោក រត្ន ប៊ុនឡា អនុប្រធាន

### ១៩-នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ

១-លោក ស៊ិន សំណាង ប្រធាន

### ២០-អធិការដ្ឋានអប់រំ

១-លោក. ទេស សំអុន អនុប្រធាន

២-លោកស្រី ញឹម វ៉ាន់ច័ន្ទកន អនុប្រធាន

### ២១-អធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

១-លោក កែវ សាផន ប្រធាន

២-លោកស្រី ឡឹក សាវ៉ាត អនុប្រធាន

### ២២-វិទ្យាស្ថានភាសាជាតិ

១-លោក ឡុង សៀម ប្រធាន

ការអធិប្បាយខាងក្រោមនិយាយអំពីគ្រឹះស្ថានសិក្សាដែលថ្នាក់កណ្ដាលនៃក្រសួងអប់រំ យុវជន និង កីឡា កំពុងមាននៅឆ្នាំ១៩៩៨ ។

ក- គ្រឹះស្ថានសិក្សាក្រោមឱវាទទីស្ដីការ

+ គ្រឹះស្ថានឧត្តមសិក្សា បច្ចេកទេស និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ ÷

សាលកវិទ្យាល័យភ្នំពេញ

* ដំណាក់កាលទី១

- សាកលវិទ្យាល័យភ្នំពេញត្រូវបានបង្កើតឡើងក្នុងទសវត្សឆ្នាំ ៦០ មានឈ្មោះថា សាកលវិទ្យាល័យភូមិន្ទខ្មែរ ។ មហាវិទ្យាល័យសំខាន់ៗស្ថិតក្រោមសាកលវិទ្យាល័យពេលនោះមាន មហាវិទ្យាល័យអក្សរសាស្ត្រ មនុស្សសាស្ត្រ មហាវិទ្យាល័យវិទ្យាសាស្ត្រ មហាវិទ្យាល័យឱសថសាស្ត្រ ។

* ដំណាក់កាលទី២

- នៅឆ្នាំ១៩៨០ សាលាគរុវិជ្ជាជាន់ខ្ពស់ត្រូវបានបង្កើតឡើងដោយក្រឹត្យច្បាប់លេខ ១០២.៨០-ក្រច-ក្រប្រ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា សំរាប់បណ្ដុះបណ្ដាលគ្រូមធ្យមសិក្សា ។ ទីតាំងសាលាគរុវិជ្ជាជាន់ខ្ពស់ដំបូងស្ថិតនៅក្នុងបរិវេណមហាវិទ្យាល័យគរុកោសល្យ១រយៈខ្លី ។

ក្រោយមក ទើបផ្ទេរទៅតាំងនៅអាគារធំ ៤ ជាន់ស្ថិតនៅតាមផ្លូវពោធិចិនតុង ។

សាលាគរុវិជ្ជាជាន់ខ្ពស់ជាគ្រឹះស្ថានឧត្តមសិក្សា មានភារកិច្ចបណ្ដុះបណ្ដាលហ្វឹកហ្វឺន កម្មាភិបាល គ្រូមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ។

* ដំណាក់កាលទី៣

- សាកលវិទ្យាល័យភ្នំពេញ ជាសាកលវិទ្យាល័យរដ្ឋ ដែលបង្កើតឡើងដោយអនុក្រឹត្យ លេខ០៤ អនក្រ ចុះថ្ងៃទី ០៣ កុម្ភៈ ឆ្នាំ១៩៨៨ លើមូលដ្ឋានសាលាគរុវិជ្ជាជាន់ខ្ពស់ និងសាលាភាសា ។ សាកលវិទ្យាល័យភ្នំពេញ ចំណុះផ្ទាល់ក្រសួងអប់រំ មានឋានៈស្មើនាយកដ្ឋាន ។

សាកលវិទ្យាល័យភ្នំពេញ មានតួនាទីជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ។ សាកលវិទ្យាល័យភ្នំពេញ មានភារកិច្ចបណ្ដុះបណ្ដាល និងរៀបចំការក្របខណ្ឌវិទ្យា-សាស្ត្រមូលដ្ឋាន និងក្របខណ្ឌគរុកោសល្យតាមទ្រង់ទ្រាយទូលាយ និងមានឯកទេសកម្មសមស្រប ។

នៅពេលបង្កើត អង្គភាពនេះមាន ១១ មហាវិទ្យាល័យ គឺ ÷

១- មហាវិទ្យាល័យ គណិតវិទ្យា

២- - រូបវិទ្យា

៣-　-　គីមីវិទ្យា

៤-　-　ជីវវិទ្យា

៥-　-　ភូមិវិទ្យា

៦-　-　ប្រវត្តិវិទ្យា

៧-　-　ទស្សនវិជ្ជា

៨-　-　ភាសានិងអក្សរសិល្ប៍ ខ្មែរ

៩-　-　ភាសានិងអក្សរសិល្ប៍ រុស្ស៊ី និងភាសាបស្ចិមប្រទេស

១០-　-　ភាសានិងអក្សរសិល្ប៍ វៀតណាម និងភាសាបូព៌ាប្រទេស

១១-　-　ចិត្ត-គរុកោសល្យ

នៅដំណាក់កាលនេះ សាកលវិទ្យាល័យភ្នំពេញ មានទីតាំងនៅអាគារធំ ៥ ជាន់ ស្ថិតនៅតាមផ្លូវពោធិចិនតុង មានតួនាទីនិងភារកិច្ចរបស់ខ្លួន និងមហាវិទ្យាល័យ ដូចកំណត់ខាងលើ ។

* ដំណាក់កាលទី៤

ដំណាក់កាលនេះ ជាដំណាក់កាលសំខាន់ ដោយមូលហេតុថា ក្រសួងអប់រំ មានគោលបំណងបង្កើតសាកលវិទ្យាល័យភ្នំពេញ អោយដូចកាលសម័យមុន១៩៧៥ ។ ពេលនោះសាកលវិទ្យាល័យភ្នំពេញក្រោមមហាវិទ្យាល័យពេញលក្ខណៈជាច្រើន មិនមែនមហាវិទ្យាល័យតូចៗ ដែលបានបង្កើតកាលពីឆ្នាំ១៩៨៨ ក្នុងដំណាក់កាលទី៣ទេ ។

ក្នុងន័យថ្មី នេះតាមអនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩២ ស្តីពីការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធចាត់តាំងនិងកំណត់តួនាទីសាកលវិទ្យាល័យភ្នំពេញ សាកលវិទ្យាល័យភ្នំពេញ ត្រូវបានបង្កើតឡើងលើមូលដ្ឋានរបស់ ÷

- សាកលវិទ្យាល័យភ្នំពេញចាស់ ដែលត្រូវប្រមូលផ្តុំមហាវិទ្យាល័យ១១ចាស់ជា មហាវិទ្យាល័យ និងវិទ្យាស្ថានចំនួន ៣ គឺ :
    - មហាវិទ្យាល័យវិទ្យាសាស្ត្រ
    - មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ
    - មហាវិទ្យាល័យភាសាបរទេស
- វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលត្រូវក្លាយជាមហាវិទ្យាល័យពាណិជ្ជសាស្ត្រ
- សាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ ដែលត្រូវក្លាយទៅជាមហាវិទ្យាល័យគរុកោសល្យ
- សាលារដ្ឋបាលនីតិសាស្ត្រ ដែលត្រូវក្លាយជាមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជារួមសាលកវិទ្យាល័យភ្នំពេញនៅដំណាក់កាលទី ៤ នេះមាន ÷

- មហាវិទ្យាល័យវិទ្យាសាស្ត្រ
- មហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ
- មហាវិទ្យាល័យគរុកោសល្យ
- មហាវិទ្យាល័យពាណិជ្ជសាស្ត្រ
- មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- វិទ្យាស្ថានភាសាបរទេស

ជាលើកដំបូង ការបង្កើតនេះមានសំគាល់២ ដូចខាងក្រោម ÷

- សាកលវិទ្យាធិការ មានថ្នាក់ស្មើអនុរដ្ឋមន្ត្រី និងសាកលវិទ្យាធិការរង ថ្នាក់ស្មើប្រធាននាយកដ្ឋាន ។

- សាកលវិទ្យាល័យភ្នំពេញ មានថវិកាស្វ័យភាព និងមានគណនេយ្យមូលដ្ឋានថ្នាក់ទី១ ។

អនុក្រឹត្យលេខ ៣៥ អនក្រ ដែលឡាយព្រះហស្ថលេខា ដោយ ព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស អនុប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីនៃរដ្ឋកម្ពុជា មិនត្រូវបានអនុវត្តទេ យោលទៅលើសភាពការណ៍ជិតបោះឆ្នោត ឆ្នាំ១៩៩៣ ។

អ្វីដែលអនុវត្តបានមុនពេលបោះឆ្នោតឆ្នាំ១៩៩៣ គឺ ការប្រើពាក្យសាកលវិទ្យាល័យភ្នំពេញ ដែលក្នុងនោះ មាន÷

- មជ្ឈមណ្ឌលភាសាបរទេស ( វិទ្យាស្ថានភាសាបរទេស )

- សាកលវិទ្យាល័យភ្នំពេញ ដែលមាន ដេប៉ាតឺម៉ង់ ( Départements ) ជាច្រើន មាន ដេប៉ាតឺម៉ង់គណិតវិទ្យា ដេប៉ាតឺម៉ង់រូបវិទ្យា ដេប៉ាតឺម៉ង់គីមី ជាដើម ។ សាកលវិទ្យាល័យនេះពុំទាន់ចែកជាមហាវិទ្យាល័យវិទ្យាសាស្ត្រ មហាវិទ្យាល័យវិទ្យាអក្សរសាស្ត្រ-មនុស្សសាស្ត្រតាមអនុក្រឹត្យលេខ ៣៥ អនក្រ-បក ចេញឆ្នាំ១៩៩២ នៅឡើយទេ ។

ការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យភ្នំពេញ គឺបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ភាសាបរទេស និង អ្នកបរិញ្ញាប័ត្រទូទៅ ។

ចាប់ពីឆ្នាំសិក្សា ១៩៩៥-៩៦ សាកលវិទ្យាល័យភ្នំពេញ ត្រូវបានប្តូរឈ្មោះជា " សាកលវិទ្យាល័យភូមិន្ទភ្នំពេញ " វិញ ( អនុក្រឹត្យលេខ ៣១ អនក្រ-បក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ១៩៩៦ ) ។

* ដំណាក់កាលទី៥

- តាមអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៨ ការរៀបចំសាកលវិទ្យាល័យភូមិន្ទ គឺយកតាមលំនាំ អនុក្រឹត្យលេខ ៣៥ អនក្រ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩២ ដែលសាកលវិទ្យាល័យនេះ មាន ៦ មហាវិទ្យាល័យ និង វិទ្យាស្ថាន ÷

- មហាវិទ្យាល័យ អក្សរសាស្ត្រ-មនុស្សសាស្ត្រ
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ
- មហាវិទ្យាល័យ គរុកោសល្យ
- វិទ្យាស្ថានភាសាបរទេស
- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ
- មហាវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានឋានៈ ស្មើ អគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ការអនុវត្តរចនាសម្ព័ន្ធថ្មីជួបការលំបាក មិនទាន់ដំណើរការបាន ក្នុងនោះមានបញ្ហាបញ្ចូលរចនាសម្ព័ន្ធសាលាក្រោមដំបូលតែមួយ និងសមាសភាពអ្នកគ្រប់គ្រងដែរ ។

<u>សាកលវិទ្យាល័យវេទមហាឫសី</u>

អនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ១៩៩៣ បានបង្កើត " សាកលវិទ្យាល័យមហាឥសីវេទ " ថ្នាក់ស្មើនាយកដ្ឋាន ។ សាកលវិទ្យាល័យមហាឥសីវេទ មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាល និងស្រាវជ្រាវវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ។ ពេលបើក សាកលវិទ្យាល័យមហាឥសីវេទ មាន ៤ មហាវិទ្យាល័យ គឺ ÷

- មហាវិទ្យាល័យ វេជ្ជសាស្ត្រ
- មហាវិទ្យាល័យ កសិកម្ម
- មហាវិទ្យាល័យ ស្ថាបត្យកម្ម
- មហាវិទ្យាល័យ គ្រប់គ្រង

ទីតាំងគ្រឹះស្ថានសិក្សានេះ តាំងនៅកំចាយមារ ខេត្តព្រៃវែង ។ មកដល់ឆ្នាំ១៩៩៧ សាកលវិទ្យាល័យ មានមហាវិទ្យាល័យ ៣ គឺ មហាវិទ្យាល័យ វេជ្ជសាស្ត្រ មហាវិទ្យាល័យ គ្រប់គ្រង និង មហាវិទ្យាល័យ កសិកម្ម ។ នៅឆ្នាំ១៩៩៧ នេះ និស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រ ត្រូវបានមករៀន នៅសាលាមធ្យមសិក្សាពេទ្យខេមរភូមិន្ទ នៅភ្នំពេញ បន្ទាប់ពីមានការតវ៉ាកន្លងមក របស់និស្សិត អំពីការប្រតិបត្តិ កម្មសិក្សា ឯកសារស្រាវជ្រាវ..... រវាងនិស្សិត និងភាគីអង្គការមូលនិធិអូស្ត្រាលី ដើម្បីកម្ពុជា AACF ។

ខែ វិច្ឆិកា ឆ្នាំ១៩៩៤ សាកលវិទ្យាល័យមហាឥសីវេទ ដែលជាឈ្មោះដើមពេលបង្កើតសាលាត្រូវបានប្តូរមកជា សាកលវិទ្យាល័យវេទមហាឥសី ។

ឆ្នាំ១៩៩៧ វគ្គជំនាន់ទី១ នៃសាកលវិទ្យាល័យវេទមហាឥសី បានបញ្ចប់ការសិក្សារបស់ខ្លួន។

<u>មហាវិទ្យាល័យពាណិជ្ជសាស្ត្រ</u>

វិទ្យាស្ថានសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយ សេចក្តីសំរេចលេខ ៦៣ សសរ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ១៩៨៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។ វិទ្យាស្ថាន មានភារកិច្ចបណ្តុះបណ្តាលក្របខ័ណ្ឌសេដ្ឋកិច្ច កំរិតឧត្តម និងមធ្យម ធ្វើវិក្រឹតការបំប៉នអំពីចំណេះដឹង និងអំពីការគ្រប់គ្រងសេដ្ឋកិច្ច ចំពោះកម្មាភិបាល ដែលកាន់ការងារសេដ្ឋកិច្ច ។ ការសិក្សាដំបូងប្រព្រឹត្តទៅជាភាសាវៀតណាមដោយផ្ទាល់ឬតាមការបកប្រែ ។ ទីតាំងវិទ្យាស្ថានសេដ្ឋកិច្ចស្ថិតនៅអាគារខ្លះនៃអតីតវិទ្យាល័យដេកាត ( មុនឆ្នាំ១៩៧៥ ) ។ អាគារមួយចំនួនទៀតត្រូវទុកអោយក្រសួងពាណិជ្ជកម្មបើកថ្នាក់បណ្តុះបណ្តាលរយៈពេលខ្លី បំប៉នជំនាញ ។

អនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី បានកែប្រែវិទ្យាស្ថានសេដ្ឋកិច្ច ទៅជាវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច មានថ្នាក់ស្មើនាយកដ្ឋាន ចំណុះផ្ទាល់ក្រសួង អប់រំ ។ វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច មានតួនាទីជាមជ្ឈមណ្ឌល បណ្តុះបណ្តាលវប្បធម៌ វិទ្យាសាស្ត្រ និង បច្ចេកទេស ដោយផ្សារភ្ជាប់ការអប់រំ និងបណ្តុះបណ្តាលទៅនឹងការ ស្រាវជ្រាវវិទ្យា-សាស្ត្រ ផលិតកម្ម និងជីវភាពសង្គម ។ វិទ្យាស្ថាន មានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹតការក្របខ័ណ្ឌវិទ្យាសាស្ត្រសេដ្ឋកិច្ច តាមទ្រង់ទ្រាយទូលាយ និងមានឯកទេសសមស្រប ។ វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច មានមហា វិទ្យាល័យ ៥ ÷

- មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម
- មហាវិទ្យាល័យសេដ្ឋកិច្ចឧស្សាហកម្មនិងសំណង់មូលដ្ឋាន
- មហាវិទ្យាល័យផែនការ ស្ថិតិ តំលៃ និងបៀវត្សពលកម្ម
- មហាវិទ្យាល័យពាណិជ្ជកម្ម ក្នុងនិងក្រៅប្រទេស និងសំភារៈ
- មហាវិទ្យាល័យហិរញ្ញវត្ថុ គណនេយ្យ និងធនាគារ

ប្រកាសលេខ ២០៣ អយក.ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ របស់ក្រសួងអប់រំ យុវជន និង កីឡា បំបែកវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ចជាពីរផ្នែក ÷

- ផ្នែកពាណិជ្ជសាស្ត្រ ត្រូវបង្កើតជាមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ស្ថិតក្នុងទីតាំងចាស់របស់វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច*

- ផ្នែកសេដ្ឋកិច្ច ត្រូវដាក់អោយស្ថិតក្រោមមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

<u>មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ</u>

- ដំបូងឡើយទីតាំងនេះជាសាលាមួយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ឈ្មោះថា សាលាកម្មាភិបាលរដ្ឋបាលនិងនីតិសាស្ត្រ ។ ក្រោយមកសាលានេះក៏ត្រូវបានផ្ទេរមកក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំវិញ ( សេចក្ដីសំរេចលេខ ៥៦ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ) ។ ចុងក្រោយសាលានេះក៏ក្លាយជាសាលាឧត្ដមសិក្សា មានឈ្មោះថា មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រកាសក្រសួងលេខ ២០៣ អយក-ប្រក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការបំបែកវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្ទេរមន្ត្រីរាជការ បុគ្គលិកសិក្សាមួយចំនួន តាមជំនាញឯកទេស និងភារកិច្ច និងនិស្សិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច អោយស្ថិតក្រោមមហាវិទ្យាល័យនីតិសាស្ត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជាមួយគ្នានេះក្រសួងអប់រំ បានបែងចែកសំភារៈបរិក្ខារសង្ហារិម តាមការចាំបាច់ពីអង្គភាពចាស់ អោយទៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ក្របខ័ណ្ឌ ទីតាំង និងសំភារៈបរិក្ខារមួយផ្នែកទៀត ទទួលពីក្រសួងយុត្តិធម៌ ។

ទីតាំងសាលារៀននេះជាអតីត ទីតាំងរបស់មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ១៩៧៤ ហើយចុងក្រោយឈ្មោះសាលាក៏នៅរក្សាដដែល ។

ក្រោយឆ្នាំ១៩៩៣ សាលារៀននេះបានទទួលជំនួយពីសាធារណរដ្ឋបារាំង ដើម្បីអភិវឌ្ឍជំនាញផង ពង្រីកភាសាបារាំងផងដែលទើបមានលទ្ធភាពក្រោយពេលបោះឆ្នោតខែ ឧសភា ឆ្នាំ១៩៩៣ ។

<u>វិទ្យាស្ថានភាសាបរទេស</u>

- ឆ្នាំ១៩៨០ គណៈចាត់តាំងមជ្ឈិមបានអនុញ្ញាតអោយក្រសួងអប់រំបង្កើតសាលាភាសាមួយដែលមានភារកិច្ចបណ្ដុះបណ្ដាលគ្រូមធ្យមសិក្សាកំរិត១ ភាសាបរទេស និងអ្នកបកប្រែភាសា ។ នៅឆ្នាំសិក្សា១៩៨០-៨១ សាលាបើកបង្រៀនភាសាវៀតណាម រុស្ស៊ី អាឡឺម៉ង់ ។ សាលានេះមានទីតាំងរួមគ្នាជាមួយសាលាគរុវិជ្ជាជាន់ខ្ពស់ ( សាកលវិទ្យាល័យភូមិន្ទសព្វថ្ងៃ ) តែមានក្របខណ្ឌរដ្ឋបាល ក្របខណ្ឌបង្រៀន សំភារៈបរិក្ខា និងថវិកាដោយឡែក ។ ឆ្នាំ១៩៨៤ សេចក្ដីសំរេចលេខ ៥២ អរ.ចត ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ១៩៨៤ របស់ក្រសួងអប់រំ បង្កើតសាលាឧបសម្ព័ន្ធរបស់សាលាភាសា ( ចំណុះសាលាភាសា ) ដើម្បីបង្រៀនភាសាវៀតណាមដល់កម្មាភិបាលមុនទៅសិក្សានយោបាយរយៈពេលវែងនៅ

* សេចក្ដីសំរេចលេខ ២៤ សសរ ចុះថ្ងៃទី ១៤ កក្កដា ១៩៩៨ របស់រាជរដ្ឋាភិបាលប្តូរឈ្មោះមហាវិទ្យាល័យពាណិជ្ជសាស្ត្រទៅជាវិទ្យាស្ថាន ជាតិគ្រប់គ្រង ។

វៀតណាម ។ សាលាឧបសម្ព័ន្ធនេះមានទីតាំងបណ្តោះអាសន្ននៅសាលាភ្នំដូនពេញ ( វិទ្យាល័យព្រះស៊ីសុវត្ថិសព្វថ្ងៃ ) ក្រោយមកប្តូរទៅអនុវិទ្យាល័យបឹងកេងកង និងប្តូរទៅសាកលវិទ្យាល័យភ្នំពេញបច្ចុប្បន្ន ។ សិក្ខាកាមចូលរៀនសាលានេះ គឺគណៈចាត់តាំងមជ្ឈិមជាអ្នកជ្រើសរើសនិងប្រគល់អោយ ។

ឆ្នាំ១៩៨៧ សាលាភាសាមានភារកិច្ចបន្ថែមទៀតគឺបណ្តុះបណ្តាលគ្រូមធ្យមសិក្សាកំរិត ២ ភាសាវៀតណាម ភាសារូស៊ី ។

ខែ កុម្ភៈ ឆ្នាំ១៩៨៨ សាលាគរុវិជ្ជាជាន់ខ្ពស់ និងសាលាភាសាត្រូវបានបញ្ចូលគ្នា បង្កើតជាសាកលវិទ្យាល័យភ្នំពេញ ។

ក្រោយមកទៀត នៅឆ្នាំ១៩៩០ ឧបសម្ព័ន្ធសាលាភាសាត្រូវប្តូរជាមជ្ឈមណ្ឌលភាសាបរទេស ( ថ្នាក់ស្មើការិយាល័យ ) ចំណុះសាកលវិទ្យាល័យភ្នំពេញ មានភារកិច្ចបង្រៀនភាសាបរទេសដល់អ្នកត្រៀមទៅរៀនបរទេស និងបង្រៀនភាសាខ្មែរដល់និស្សិតបរទេស ។

<u>មហាវិទ្យាល័យគរុកោសល្យ</u>

- ក្នុងសម័យអាណានិគមបារាំង សាលារៀនមួយត្រូវបានសាងសង់នៅទីនេះ ឈ្មោះថា សាលាបឋមសិក្សា ហ្វ្រង់ស្វាប៊ូឌាំង ( Francois Boudoin ) ។ នៅឆ្នាំ១៩៤៣ សាលាត្រូវបានប្តូរឈ្មោះជាសាលាគរុវិជ្ជា មានភារកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា ។

នៅឆ្នាំ១៩៥៨ សាលាប្តូរឈ្មោះជា វិទ្យាស្ថានជាតិគរុកោសល្យ មានភារកិច្ចបណ្តុះបណ្តាលសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ ។

ឆ្នាំ១៩៦៥ សាលាប្តូរឈ្មោះជា មហាវិទ្យាល័យគរុកោសល្យ មានភារកិច្ចបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ ។ ការបណ្តុះបណ្តាលអធិការបឋមសិក្សាត្រូវបានចាប់ផ្តើមនៅ ឆ្នាំ១៩៦៨ ។ ចន្លោះ ១៩៧០-៧៥ កន្លែងនេះជាមជ្ឈមណ្ឌលនយោបាយរបស់និស្សិត និងគ្រូបង្រៀនដែលមាននិន្នាការប្រឆាំងរបបសាធារណរដ្ឋខ្មែរ របស់លោកសេនាប្រមុខ លន់ នល់ ។

ចន្លោះ ១៩៧៥-៧៩ សាលានេះត្រូវបោះបង់ចោល និងប្រើប្រាស់ជាឃ្លាំងសំបកដប និងរបស់ផ្សេងៗ ។

នៅឆ្នាំ១៩៧៩ សាលាត្រូវបានបោសសំអាតជួសជុលអោយដំណើរការឡើងវិញ ហើយប្រើប្រាស់ជាសាលានយោបាយក្រសួងអប់រំ ដែលមានភារកិច្ចបំប៉ននយោបាយ និងបច្ចេកទេសដល់កម្មាភិបាល បុគ្គលិកដែលចូលបំរើការក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

សេចក្តីសំរេចលេខ ៣៦៨-៨០ កប ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សា

ប្រជាជនបដិវត្តកម្ពុជា បង្កើតសាលាគរុកោសល្យនិងវិក្រឹតការមជ្ឈិម នៅទីនេះស្ថិតក្រោមក្រសួងអប់រំ ។ សាលាមានភារកិច្ចបណ្តុះបណ្តាល និងវិក្រឹត្យការជំនាញខាងគ្រប់គ្រង ខាងអប់រំ និងជំនាញគរុកោសល្យ អោយកម្មាភិបាលទទួលបន្ទុក មន្ទីរអប់រំខេត្តក្រុង នាយក-រងសាលារៀន និងគ្រូបង្រៀន ។

អនុក្រឹត្យលេខ ៨ អនក្រ ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ១៩៨៦ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី បានកែប្រែសាលាគរុកោសល្យ និងវិក្រឹតការមជ្ឈិម ទៅជាសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ ថ្នាក់ស្មើនាយកដ្ឋាន ស្ថិតក្រោមក្រសួងអប់រំ ។ សាលានេះជាមជ្ឈមណ្ឌលនយោបាយវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេសគ្រប់គ្រង និងមុខជំនាញវិជ្ជាជីវៈកំរិតឧត្តមសិក្សា ដែលមានភារកិច្ចជាក់ស្តែងដូចខាងក្រោម៖

- បណ្តុះបណ្តាលវិក្រឹតការកម្មាភិបាលគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ចាប់ពីនាយកសាលាកំរិតសិក្សាទី ២ និងកម្មាភិបាលការិយាល័យអប់រំស្រុកឡើងទៅ
- បំប៉នមុខជំនាញ
- ស្រាវជ្រាវវិទ្យាសាស្ត្រគ្រប់គ្រងអប់រំ

នៅដំណាក់ចុងក្រោយ សាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ ត្រូវក្លាយជាមហា-វិទ្យាល័យគរុកោសល្យ ក្នុងសំណុំរបស់សាកលវិទ្យាល័យភ្នំពេញ ដែលត្រូវរៀបចំឡើងវិញដោយអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩២ មាន ៥ មហាវិទ្យាល័យ និង១ វិទ្យាស្ថាន ។

ពីឆ្នាំ១៩៩៣ មហាវិទ្យាល័យគរុកោសល្យ ត្រូវបានជួសជុល និងសាងសង់ដោយការជួយឧបត្ថម្ភជាច្រើនប្រភពក្នុងនិងក្រៅប្រទេស ។ ការជួសជុលបានរក្សាស៊ុលដើមជាប្រវត្តិសាស្ត្ររបស់អាគារទីតាំងកណ្តាលដែលពីមុនជាអាគារឈើទ្រុឌទ្រោម បំរើអោយសាលាសហសិក្សា ត្រូវបានសាងសង់ជារោងអំពីគ្រឿងដែកគ្មានជញ្ជាំង សំរាប់ការប្រជុំផ្សេងៗ រួមទាំងថ្ងៃសម្ពោធនិងបើកបិទវគ្គផង ។

ប្រវត្តិការងារធំៗដែលមហាវិទ្យាល័យគរុកោសល្យបានបំពេញ ក្រោយពីដំណាក់កាលទី១ (សាលានយោបាយក្រសួងអប់រំ ) ដំណាក់កាលទី២ ( សាលាគរុកោសល្យ និងវិក្រឹតការមជ្ឈិម ) ដំណាក់កាលទី៣ ( សាលាជាន់ខ្ពស់កម្មាភិបាល គ្រប់គ្រងអប់រំ ) មាន៖

- ការបណ្តុះបណ្តាលអធិការបឋមសិក្សាឡើងវិញ ( ជំនួយសាធារណរដ្ឋបារាំង )
- ការបណ្តុះបណ្តាលអធិការមធ្យមសិក្សា ( ជំនួយសាធារណរដ្ឋបារាំង )
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសបឋមសិក្សា
- ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិឯកទេសទូទៅ បរិញ្ញា + ១ ចាប់ពីឆ្នាំសិក្សា១៩៩៥-៩៦ ( ពេលនោះ សាកលវិទ្យាល័យភ្នំពេញបន្តបណ្តុះបណ្តាល តែគ្រូមធ្យមសិក្សាទុតិយភូមិភាសាបរទេស នៅមជ្ឈមណ្ឌលភាសាបរទេស ) ។

<u>វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា</u>

ក្រោយឆ្នាំ១៩៧៩ វិទ្យាស្ថានបានដំណើរការឡើងវិញដោយសារជំនួយរបស់អតីត ស.ស.ស.ស. ( សហភាព សាធារណរដ្ឋសង្គមនិយមសូវៀត ) ដែលបានកសាងសាលានេះក្នុងទសវត្ស ៦០ (?) ។ ពេលដំណើរការនេះ សាលាមានឈ្មោះដើមជា វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាព កម្ពុជា-សូវៀត ITSAKS សំរាប់បណ្តុះបណ្តាលអ្នកបច្ចេកទេសមធ្យមផង បណ្តុះបណ្តាលវិស្វករផង ។ គ្រឹះស្ថានសិក្សានេះជាទីកន្លែងបណ្តុះបណ្តាលបច្ចេកទេសធំជាងគេ និងទំនើបជាងគេនៅប្រទេសកម្ពុជា* ។

ដំណាក់កាលចុងក្រោយ ពិសេសក្រោយពេលបោះឆ្នោត សាលានេះបានប្តូរឈ្មោះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ITC ( ១៩៩៤ ) ហើយទទួលការឧបត្ថម្ភពីប្រទេសនិយមភាសាបារាំង - Les pays francophones ក្នុងនោះ AUPELF- UREF ជាអ្នកជួយផ្ទាល់ ពិសេសប្រទេសបារាំង បានបញ្ជូនសាស្ត្រាចារ្យមកបង្រៀន និងជួយកសាងជួរសាស្ត្រាចារ្យខ្មែរ ។

<u>មជ្ឈមណ្ឌលបច្ចេកទេស និងវិជ្ជាជីវៈព្រះកុសុមៈ</u>

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ទឹកថ្លាត្រូវបានបង្កើតឡើងដោយ សេចក្តីសំរេចលេខ ៨១ សរច ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ១៩៨១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។ នាយកសាលាមានឋានៈ ស្មើមន្ទីរជុំវិញខេត្ត ។ នៅដំណាក់កាលទី២ សាលាត្រូវបានប្តូរឈ្មោះ ជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមិត្តភាពកម្ពុជា-សូវៀតដែលទទួលការឧបត្ថម្ភថវិកា និងបច្ចេកទេសពីអតីត សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ( សសសស ) ។ ក្រោយបោះឆ្នោតឆ្នាំ១៩៩៣ សាលាប្តូរឈ្មោះជាមជ្ឈមណ្ឌលបច្ចេកទេស និងវិជ្ជាជីវៈ ព្រះកុសុមៈ ។

<u>សាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្ម</u>

ក្រោយឆ្នាំ១៩៧៩ សាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្មស្ថិតក្រោមក្រសួងពាណិជ្ជកម្ម។ ក្រសួងអប់រំ យុវជន និង កីឡាបានស្នើទៅក្រសួងពាណិជ្ជកម្មអោយសាលានេះស្ថិតក្រោមក្រសួងតែមួយវិញ ។ ក្រសួងពាណិជ្ជកម្មបានឯកភាព ហើយអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ១៩៩៤ របស់រាជរដ្ឋាភិបាល បានផ្ទេរសាលាមធ្យមសិក្សាឯកទេសពាណិជ្ជកម្មអោយមកក្រសួងអប់រំ យុវជន និង កីឡា ។

<u>សាលាមធ្យមសិក្សាឯកទេសឧស្សាហកម្ម</u>

មុនឆ្នាំ១៩៧០ សាលានេះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ មានឈ្មោះថា មហាវិទ្យាល័យសិល្បៈ និងមុខរបរ ។ សាលានេះដំណើរការដោយសារជំនួយរបស់សហរដ្ឋអាមេរិច ។

ឆ្នាំ១៩៨០ សាលានេះបើកទ្វារឡើងវិញ ឈ្មោះថាសាលាមធ្យមសិក្សាបច្ចេកទេស

---

* លោក អ៊ុយ វ៉ាន់ថុន ជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ។

ឧស្សាហកម្ម ( គ.ម.លេខ ៦ ) ហើយបើកវគ្គខ្លីៗមិនរៀបរយ ដើម្បីបំរើតំរូវការបណ្តុះបណ្តាលបុគ្គលិក និងអ្នកបច្ចេកទេសអោយក្រសួងឧស្សាហកម្ម ដែលគ្រប់គ្រងសាលានេះ ។ ដល់ឆ្នាំ១៩៨៨ ទើបមានវគ្គវែងរៀបរយ : វគ្គមធ្យមបច្ចេកទេស វគ្គកម្មករជំនាញ ។ នៅឆ្នាំ១៩៩៤ មានបើកវគ្គគ្រូបច្ចេកទេស ( គរុកោសល្យបច្ចេកទេស ) ។ សាលានេះដំណើរការបានដោយសារជំនួយរបស់ OXFAM , APHEDA...... ។

នៅឆ្នាំ១៩៩៤ សាលានេះត្រូវបានផ្ទេរអោយស្ថិតក្រោមក្រសួងអប់រំ យុវជន និង កីឡា ( ប្រកាសលេខ ៦០១ ចត-ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ១៩៩៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ) ។ នៅឆ្នាំ១៩៩៧ សាលានេះមានឈ្មោះថា សាលាមធ្យមសិក្សាឯកទេសឧស្សាហកម្ម ។

<u>សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម</u>

នៅដំណាក់កាលអភិវឌ្ឍមត្តេយ្យសិក្សា ក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជា សាលាមត្តេយ្យក្រុមសាមគ្គី បានរីកចំរើន និងទ្រទ្រង់ដោយក្រុមសាមគ្គីតាមមូលដ្ឋាន ។ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម ត្រូវបានបង្កើតឡើងដោយសេចក្តីសំរេចលេខ ២០៦ សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី មានភារកិច្ច ÷

- បណ្តុះបណ្តាលគ្រូមត្តេយ្យតាមប្រព័ន្ធបណ្តុះបណ្តាលរយៈពេលវែង និងទៀងទាត់
- វិក្រឹតការនយោបាយ និងមុខជំនាញវិជ្ជាជីវៈជូនអ្នកគ្រូមត្តេយ្យដែលបានបណ្តុះបណ្តាលហើយ
- សិក្សាស្រាវជ្រាវអប់រំមត្តេយ្យសិក្សា

ការបណ្តុះបណ្តាលគ្រូមត្តេយ្យបានដំណើរការជាបន្តបន្ទាប់ ហើយឈានដល់រូបមន្ត ១១+២ នៅឆ្នាំសិក្សា១៩៩៣-៩៤ ។ នៅឆ្នាំសិក្សា១៩៩៦-៩៧ មានគ្រូមត្តេយ្យភេទប្រុសចេញបំរើការជាលើកដំបូង ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះប្រភពបណ្តុះបណ្តាលគ្រូមត្តេយ្យជួបការលំបាក ។ នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម មានថ្នាក់ស្មើអនុប្រធានមន្ទីរជុំវិញខេត្ត ។

<u>សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា</u>

ដើមឡើយទីតាំងសាលានេះជាសាលានយោបាយ វប្បធម៌ និងមុខជំនាញ របស់ក្រសួងវប្បធម៌ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ។ ការបណ្តុះបណ្តាលជំនាញសិល្បៈផ្សេងៗ មានសិល្បៈមហាជនជាដើម ត្រូវបានរៀបចំនៅកន្លែងនេះដើម្បីភ្ជាប់ការឃោសនាអប់រំ ជាមួយសិល្បៈ ។ ពេលនោះដែរវិស័យកីឡាស្ថិតនៅក្នុងវប្បធម៌ ។ សាលាមធ្យមសិក្សាអប់រំកាយនិងកីឡា ស្ថិតនៅជាប់ខាងកើតពហុកីឡាដ្ឋានអូឡាំពិច ។ ពេលរៀបចំក្រសួងក្នុងរាជរដ្ឋាភិបាលកម្ពុជា

ឆ្នាំ១៩៩៣ សាលានេះក៏ប្ដូរទីតាំងមកក្នុងសាលានយោបាយ វប្បធម៌ និងមុខជំនាញ ហើយក៏យកឈ្មោះជាសាលាមធ្យមសិក្សាអប់រំកាយនិងកីឡា រហូតដល់ផ្ទេរចូលក្រសួងអប់រំ យុវជន និង កីឡា ។ សាលានយោបាយ វប្បធម៌និងមុខជំនាញ ក៏បាត់ឈ្មោះរហូតមក ។

ទីតាំងរបស់សាលានេះជាអតីតសាលាបឋមសិក្សាតេជោដំឌិន មុនឆ្នាំ១៩៧៥ ។ ចាប់ពី ១៩៧៩ ក្រសួងវប្បធម៌បានប្រើប្រាស់ទីតាំងនេះរហូតមកដល់ ១៩៩៣ ។

ក្រៅពីសាលាមធ្យមសិក្សាបច្ចេកទេសខាងលើ ក្រសួងអប់រំ យុវជន និង កីឡា មានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលផ្សេងៗទៀតក្រោមការគ្រប់គ្រងរបស់ខ្លួន÷

- មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ( រាជធានីភ្នំពេញ, កណ្ដាល , តាកែវ, កំពង់ចាម , ព្រៃវែង , បាត់ដំបង និងស្ទឹងត្រែង )
- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តបាត់ដំបង
- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តសៀមរាប
- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងធនធានបច្ចេកវិជ្ជាខេត្តកណ្ដាល

\+ <u>សាលារៀនចំណេះទូទៅ និងមត្តេយ្យសិក្សា</u>

<u>វិទ្យាល័យព្រះស៊ីសុវត្ថិ</u> - ក្រោយឆ្នាំ១៩៧០ សាលានេះឈ្មោះជា វិទ្យាល័យ ៩ តុលា ( ថ្ងៃប្រកាសរបបសាធារណរដ្ឋខ្មែរ របស់សេនាប្រមុខ លន់ នល់ ) ។ ក្រោយឆ្នាំ១៩៧៩ ដែលសាលានេះបើកទ្វារឡើងវិញ នៅឆ្នាំ១៩៨០ សាលាមានឈ្មោះថា វិទ្យាល័យភ្នំដូនពេញ ដែលមានតែថ្នាក់ទី ៨ - ៩ - ១០ ( ប្រព័ន្ធចំណេះទូទៅពេលនោះមាន ១០ ឆ្នាំ ) ។ ចន្លោះពេលពី ១៩៧៩ ដល់ ១៩៨០ កន្លែងនេះជាសាលាគរុកោសល្យរាជធានី ដែលជាសាលានយោបាយផង បណ្ដុះបណ្ដាលគ្រូបឋមសិក្សាផង ។ ក្រោយពេលបោះឆ្នោតឆ្នាំ១៩៩៣ សាលានេះត្រូវបានប្ដូរឈ្មោះជាវិទ្យាល័យព្រះស៊ីសុវត្ថិដូចដើមវិញ ។ បច្ចុប្បន្ន សាលាបើកទទួលសិស្ស ចាប់ពីថ្នាក់ទី ៧ រហូតដល់ ទី១២ ( ប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ ) ។

<u>វិទ្យាល័យអនុវត្ត</u> - វិទ្យាល័យនេះត្រូវបានបង្កើតឡើង តាមប្រកាសលេខ ៧០៥ អយក.ប្រក ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៦ នៅក្នុងបរិវេណមហាវិទ្យាល័យគរុកោសល្យ ( ចាប់ពីឆ្នាំសិក្សា ១៩៩៦-៩៧ ) ហើយស្ថិតក្រោមការគ្រប់គ្រងរបស់មហាវិទ្យាល័យ និងនាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

ក្នុងជំហានដំបូងនៃការបើកវិទ្យាល័យនេះ សិស្សមួយចំនួនត្រូវបានផ្ទេរពីបេក្ខជនដែលប្រលងជាប់ចូលវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយគ្មានកន្លែងរៀន ។ ការបើកវិទ្យាល័យនេះជួយសំរួលការ

ស្រូបសិស្សដែលនៅកណ្តាលរាជធានីអោយមានលទ្ធភាពចូលរៀនបានមួយចំនួនថែមទៀត ។

<u>សាលាបឋមសិក្សាអនុវត្ត</u> - សាលារៀននេះតាំងនៅក្នុងបរិវេណមហាវិទ្យាល័យគរុកោសល្យ ហើយស្ថិតក្រោមការគ្រប់គ្រងរបស់មហាវិទ្យាល័យ ។ ដំបូងសាលានេះជាបឋមសិក្សាវត្តលង្កា តាំងនៅក្នុងវត្តលង្កា បង្កើតដោយសេចក្តីសំរេចលេខ ៩២ សសរ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៨៨ ។ ក្រោយពេលដែលវត្តលង្កាត្រូវការទីតាំងសាលារៀននោះធ្វើជាកន្លែងសិក្សាសំរាប់ព្រះសង្ឃ សាលាបឋមសិក្សាវត្តលង្កាត្រូវបានផ្ទេរជាសាលាអនុវត្តរបស់មហាវិទ្យាល័យគរុកោសល្យតាមប្រកាសលេខ ១៤ អយក.ប្រក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ១៩៩៥ ។

<u>សាលាមត្តេយ្យ៧មករា</u> - សាលានេះភ្ជាប់ឈ្មោះនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ៧មករា ១៩៧៩ ដែលជាថ្ងៃរំដោះប្រទេសកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ។ សាលាមត្តេយ្យនេះត្រូវបានបង្កើត ឡើងដោយសេចក្តីសំចេលេខ៨១៧ អរ-ចត ចុះថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៨០ ដើម្បីទទួលកូនកម្មាភិបាល បុគ្គលិក កម្មករ របស់ក្រសួងអប់រំ ពេលនោះមកអបរំដើម្បីទុកលទ្ធភាព អោយឳពុកម្តាយបានបំរើការងារ រដ្ឋ ។ ក្រៅពីនេះក៏មានទទួលកុមារពីមជ្ឈដ្ឋានឯទៀតដែរ ។
សាលាមត្តេយ្យនេះគ្មានត្រូវបានប្តូរទី តាំង និងប្តូរឈ្មោះទេគឺតាំងនៅខាងលិចអតីតក្រសួងអប់រំ ។

<u>វិទ្យាល័យព្រះយុគន្ធរ</u> - ឈ្មោះវិទ្យាល័យព្រះយុគន្ធរ ត្រូវបានប្រើរហូតដល់ឆ្នាំ១៩៧០ ។ នៅឆ្នាំដដែលនេះ វិទ្យាល័យព្រះយុគន្ធរប្តូរឈ្មោះជាវិទ្យាល័យ ១៨ មិនា ( ថ្ងៃដែលសេនាប្រមុខលន់ នល់ ធ្វើរដ្ឋប្រហារទំលាក់សម្តេចសីហនុ ឆ្នាំ១៩៧០ ) ហើយប្រើរហូតដល់១៩៧៥ ។ គឺជាវិទ្យាល័យដ៏ធំមួយនៅភ្នំពេញសម័យនោះ ។

ឆ្នាំ១៩៨០ ក្រឹត្យច្បាប់លេខ ១៣០-៨០ ក្រច-ក្រប្រ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា បានបើកគ្រឹះស្ថានសិក្សាមួយ ឈ្មោះថា " សាលាបំពេញវិជ្ជាមជ្ឈិម " នៅត្រង់ទីតាំងអតីតវិទ្យាល័យព្រះយុគន្ធរនេះ ។ សាលានេះអោយមានថ្នាក់ស្មើនាយកដ្ឋាន ហើយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ ។ សាលានេះមានភារកិច្ចបំប៉ន និងលើកកំពស់កំរិតវប្បធម៌ ជូនកម្មាភិបាល និងយុវជនដែលជាបុគ្គលិក កម្មករ កសិករឈានមុខ យុវជនជាកូនកម្មាភិបាល រឺ យុវជនដែលបានពលីជីវិតជូនបដិវត្តន៍ ។ ក្រសួងអប់រំ សហការជាមួយ គណៈចាត់តាំងមជ្ឈិមដើម្បីប្រមូលសិក្ខាកាមអោយចូលរៀន ។ ឆ្នាំក្រោយៗមកទៀត ប្រភពសិក្ខាកាមកាន់តែចុះតិចហេតុនាំអោយសល់បន្ទប់រៀនគុកៅអី ។ វគ្គបំពេញវិជ្ជានេះមានដល់ចប់កំរិតសិក្សាទី៣ ( ចប់កំរិតវិទ្យាល័យ ) ។

ដំណោះស្រាយពេលនោះ គឺបន្តដំណើរការវគ្គបំពេញវិជ្ជាចុងក្រោយអោយចប់ និងបើក

វិទ្យាល័យចំណេះទូទៅ មួយបន្ថែមក្នុងបរិវេណសាលានេះចាប់ពីឆ្នាំសិក្សា១៩៩២-៩៣ ដើម្បីប្រើប្រាស់បន្ទប់ សិក្សារ ដែលអាចទទួល សិស្សបាន ៥២០នាក់ ។ សាលាចាប់ទទួលសិស្សចំណេះទូទៅ ( មធ្យមសិក្សាបឋមភូមិ ចាប់ពីឆ្នាំសិក្សា ១៩៩២-៩៣ ) ។

ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ក្រុមប្រឹក្សារដ្ឋមន្ត្រីសំរេចអោយប្រើឈ្មោះ វិទ្យាល័យព្រះយុគន្ធរ ដល់វិទ្យាល័យដែលបើកថ្មីនេះ ។

<u>អនុវិទ្យាល័យ ចតុមុខ</u>

សេចក្តីសំរេចលេខ ៣៨៣ អរ.ចត ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ១៩៨០ បានបង្កើតគ្រឹះស្ថានបឋមសិក្សា មួយឈ្មោះថា " សាលាបឋមសិក្សាក្រុងភ្នំពេញ " ស្ថិតក្រោមឱវាទផ្ទាល់របស់ក្រសួងអប់រំ ។ ឆ្នាំ ១៩៨១ ក្រសួងបានចេញសេចក្តីសំរេច បង្កើតកំរិតសិក្សាទី២ នៅក្នុងបរិវេណសាលាបឋមសិក្សាក្រុងភ្នំពេញនេះ ។

ក្រោយមកទៀត នៅឆ្នាំ ១៩៨២ សេចក្តីសំរេចថ្មីរបស់ក្រសួងបានបង្កើត " សាលាចតុមុខ " ជាគ្រឹះស្ថានកំរិតសិក្សា ទី១-ទី២ ( បឋមសិក្សា , មធ្យមសិក្សាបឋមភូមិ ) ។ សាលានេះជាសាលាអនុវត្តរបស់សាលា គរុកោសល្យនិងវិក្រឹតការ មជ្ឈិម ( បច្ចុប្បន្នមហាវិទ្យាល័យគរុកោសល្យ ) និងមានភារកិច្ចអប់រំកុមារនៅរាជធានីភ្នំពេញ ខាងកំរិតសិក្សាទី១ និង ទី២ ។

ដោយការសិក្សានេះចេះតែមានការរីកចំរើន ក្រសួងបានចេញសេចក្តីសំរេចអោយបើកសាលាបឋមសិក្សាមួយ កន្លែងថ្មីទៀត ចាប់ពីបវេសនកាល ១៩៩០-៩១ ដែលមានទីតាំងស្ថិតក្នុងវត្តបុទុមវត្តី ជាឧបសម្ព័ន្ធសាលាចតុមុខនិង មានឈ្មោះថា " សាលាបឋមសិក្សាវត្តបុទុមវត្តី " ។ ក្របខ័ណ្ឌបំរើការសាលានេះជាក្របខ័ណ្ឌរួមរបស់សាលារៀន ចតុមុខ ។

ចុងក្រោយសាលានេះមានឈ្មោះថា អនុវិទ្យាល័យចតុមុខ ដែលមានមធ្យមសិក្សាបឋមភូមិផង បឋមសិក្សាផង ( សាលា បឋមសិក្សាវត្តបុទុមវត្តី ជាឧបសម្ព័ន្ធរបស់អនុវិទ្យាល័យចតុមុខ ) ។

ខ- <u>នាយកគ្រឹះស្ថានសិក្សា</u>

<u>ឈ្មោះគ្រឹះស្ថានសិក្សា និង នាយក</u>

( ពីឆ្នាំ ១៩៧៩ ដល់ មុនពេលចេញអនុក្រឹត្យ លេខ ២១ អនក្រ.បក )

| ល.រ | គ្រឹះស្ថានសិក្សា | ឈ្មោះថ្មីរបស់គ្រឹះស្ថានសិក្សា | នាយក |
|---|---|---|---|
| 1. | សាលាគរុវិជ្ជាជាន់ខ្ពស់ | ១-សាកលវិទ្យាល័យភ្នំពេញ<br>២-សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ធិត ផន្ទរ ( សាលាគរុវិជ្ជាជាន់ខ្ពស់) , វ៉ា ស៊ីមសិទ្ធ |
| 2. | វិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ មិត្តភាពកម្ពុជា-សូវៀត ( ITSAKS ) | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ( ITC) | ឱម ញាណសារៈ , ដូ កុងងួន<br>ទេព ធន ( នាយករដ្ឋបាល ITC ) |
| 3. | សាកលវិទ្យាល័យមហាឥសីវេទ | សាកលវិទ្យាល័យវេទមហាឫសី | សំ សុក្ខុន , ជា សាវ៉ាន , សូម៉េ ហស្សេជា |
| 4. | វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច | មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ | អ៊ីវ ចុង |
| 5. | សាលារដ្ឋបាលនីតិសាស្ត្រ | មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | លឿង នៃ ,<br>យក់ ង៉ុយ ( នាយករងទទួលបន្ទុករួម ) |

| | | | |
|---|---|---|---|
| 6. | ឧបសម្ព័ន្ធសាលាភាសា | មជ្ឈមណ្ឌលភាសាបរទេស | ស៊ីវ ផា ( ឧបសម្ព័ន្ធសាលាភាសា ) |
| 7. | សាលាភាសា | វិទ្យាស្ថានភាសាបរទេស | ពិត ចំណាន . ម៉ៅ សុក្កុន |
| 8. | សាលាគរុកោសល្យ និង វិក្រឹតការមធ្យម | ១-សាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ<br>២-មហាវិទ្យាល័យគរុកោសល្យ | សោម កុយ . អ៊ុំ គីមផន . សំ ព្រហ្មនា . នាង មុត ( នាយកស្តីទី ) |
| 9. | មជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈទឹកថ្លា | មជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រះកុសុមៈ | ខៀវ កូឡា . ប៉េង ស៊ីមហុង |
| 10. | សាលាមធ្យមសិក្សា ឯកទេសពាណិជ្ជកម្ម | | ម៉ក់ យ៉ុន . អៀង សុផល |
| 11. | សាលាមធ្យមសិក្សា បច្ចេកទេសឧស្សាហកម្ម | សាលាមធ្យមសិក្សាឯកទេស ឧស្សាហកម្ម | សោម ថាន . ម៉ុក សារុត |
| 12. | សាលាមធ្យមសិក្សា គរុកោសល្យមត្តេយ្យមធ្យម | | អ.ស ប៉ែន ណារុណ . អ.ស ប្រាក់ សូលីដា |
| 13. | សាលាមធ្យមសិក្សា អប់រំកាយនិងកីឡា | | សរ សួន ( ដល់ឆ្នាំ ១៩៩៥ ) |
| 14. | វិទ្យាល័យភ្នំជូនពេញ | វិទ្យាល័យ ព្រះស៊ីសុវត្ថិ | ហ៊ូ ស្រ៊ី . សេង លីម |
| 15. | សាលាបំពេញវិជ្ជាមធ្យម | វិទ្យាល័យព្រះយុគន្ធរ | អ.ស យុន ង៉ែត . ស៊ិន ងួនហេង . កែវ យ៉ារ. គួច ស៊ាងគ្រុយ |
| 16. | សាលាបឋមសិក្សាក្រុង ភ្នំពេញ | ១-សាលាចតុមុខ<br>២-អនុវិទ្យាល័យចតុមុខ | សាលាបឋមសិក្សាក្រុងភ្នំពេញ : ង៉ោ ខាយ<br>: អ.សមូល មៀចសាវ៉ាក់<br>សាលាចតុមុខ : ទី គ្រី ( នាយករួម )<br>អនុវិទ្យាល័យចតុមុច ( រួមទាំងបឋមសិក្សា ) :<br>រ័ត្ន សាគរ . ដាំ សឿន . |
| 17. | វិទ្យាល័យ អនុវត្ត | | រ័ត្ន ហួត |
| 18. | សាលាបឋមសិក្សាវត្តលង្កា | សាលាបឋមសិក្សាអនុវត្ត | អ.ស សេង ឆែម . តាំង គុយសាន . ជា ប៊ុនហោ |
| 19. | សាលាមត្តេយ្យ៧មករា | | អ.ស ប៉ក់ សាម័យម៉ង់សាណា . អ.ស ស៊ី អេងលី |

III- <u>ការអនុវត្តអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃ ទី ២៣ មីនា ១៩៩៨</u> :

អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងអប់រំយុវជននិងកីឡា ត្រូវបានរៀបចំពង្រាងតាំងពី ឆ្នាំ ១៩៩៣ ។ ការយឺតយ៉ាវចេញអនុក្រឹត្យនេះមានមូលហេតុធំ ពីរ :

- ការរង់ចាំអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្យទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ដែលជាអនុក្រឹត្យស្តង់ដាចេញជាមុនសិន ទើបគំរូវអនុក្រឹត្យក្រសួងនីមួយៗទៅតាមស្តង់ដានោះ ។ ការយកស្តង់ដានេះជាមូលដ្ឋាន ដោយហេតុថារចនាសម្ព័ន្ធក្រសួងក្រោយបោះឆ្នោតឆ្នាំ១៩៩៣ ខុសពីរចនាសម្ព័ន្ធសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សម័យរដ្ឋកម្ពុជា ។

- ខ្លឹមសារនៃអនុក្រឹត្យរបស់ក្រសួងអប់រំយុវជននិងកីឡាមានពាក់ព័ន្ធដល់ក្រសួងជាច្រើន ពិសេសបញ្ហា ឧត្តមសិក្សា ។ ក្រៅពីនេះ COMEX និង អន្តរក្រសួង បានផ្តល់យោបល់ល្អជាច្រើនក្នុងខ្លឹមសារ ដូចជាការបណ្តុះ បណ្តាលបច្ចេកទេសវិជ្ជាជីវៈ វិស័យកីឡា ការអប់រំក្រៅប្រព័ន្ធ . ការសិក្សាអប់រំ ... ដែលទាមទារពេលវេលា កែលំអច្រើនសាមួយរយៈវែង ពន្យារដល់ថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៩៨ គឺជិតដល់ពេលបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រ ដែលនឹងកំណត់នៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។

១-<u>រចនាសម្ព័ន្ធថ្មីរបស់ក្រសួងអប់រំ យុវជននិងកីឡា</u> ( ក្នុងឧបសម្ព័ន្ធ )

ក/អគ្គនាយកដ្ឋាន និង អគ្គាធិការដ្ឋាន គឺ ជាឋានានុក្រមមួយថ្មីក្នុងរចនាសម្ព័ន្ធក្រសួងអប់រំ យុវជន និង កីឡា ។ អគ្គនាយក និង អគ្គាធិការ ត្រូវតែងតាំងដោយក្រឹត្យ ។ អគ្គនាយករង និង អគ្គាធិការរង ត្រូវតែងតាំងដោយអនុក្រឹត្យដូចប្រធាននាយកដ្ឋានដែរ ។

ក្រសួងអប់រំយុវជននិងកីឡា ជាក្រសួងធំជាងគេបង្អស់ក្នុងចំណោមក្រសួង និង រដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល ។ រចនាសម្ព័ន្ធថ្មីត្រូវបានអនុញ្ញាតអោយមានអគ្គនាយកដ្ឋាន ៤ និង អគ្គាធិការដ្ឋាន ១ ។

-អគ្គនាយកដ្ឋានអប់រំ មាន :

- នាយកដ្ឋាន បឋម និង មត្តេយ្យសិក្សា
- នាយកដ្ឋាន មធ្យមសិក្សាចំណេះទូទៅ
- នាយកដ្ឋាន អប់រំក្រៅប្រព័ន្ធ
- នាយកដ្ឋាន សុខភាពសិក្សា
- នាយកដ្ឋាន ស្រាវជ្រាវគរុកោសល្យ
- គ្រឹស្ថានបោះពុម្ព និង ចែកផ្សាយ

-អគ្គនាយកដ្ឋាន យុវជន និង កីឡា

- នាយកដ្ឋានយុវជន
- នាយកដ្ឋានអប់រំកាយ និង កីឡា
- វិទ្យាស្ថានជាតិអប់រំកាយ និង កីឡា

-អគ្គនាយកដ្ឋាន ឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ

- នាយកដ្ឋាន ឧត្តមសិក្សា
- នាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ
- នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ
- នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ

-អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

-នាយកដ្ឋានរដ្ឋបាល

-នាយកដ្ឋានបុគ្គលិក

-នាយកដ្ឋានហិរញ្ញវត្ថុ

-នាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ

-នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍

-នាយកដ្ឋានផែនការ

-អគ្គាធិការដ្ឋាន ចែកជា អធិការដ្ឋានអប់រំ និង អធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដែលឋានៈស្មើនាយកដ្ឋានដែរ ។ អធិការដ្ឋានអប់រំមានភារកិច្ចរួមលើការអប់រំ យុវជន និង កីឡា ។

ជារួមក្រសួងអប់រំ យុវជន និង កីឡា មាន ២២ អង្គភាព* មានឋានៈស្មើនាយកដ្ឋានដែលបានមកពីរៀបចំ រចនាសម្ពន្ធ័ដែលមានពីមុនពេលចេញអនុក្រឹត្យនេះ :

-ការបញ្ចូលអង្គភាព :

គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំត្រូវបានបញ្ចូលជាមួយមជ្ឈមណ្ឌលចែកផ្សាយនិងបណ្ណាល័យ ជាអង្គភាពតែមួយគឺ គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ ។ ការបញ្ចូលនេះត្រូវបានផ្តើមគំនិតតាំងពី ឆ្នាំ ១៩៩១តែមិនទាន់បានអនុវត្ត ។

វិទ្យាស្ថានជាតិ អប់រំកាយ និង កីឡា ត្រូវបានបង្កើតឡើងដោយបញ្ចូលមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺន និង សាលាមធ្យមសិក្សា អប់រំកាយ និង កីឡា អោយស្ថិតក្រោមការគ្រប់គ្រងតែមួយ និង បង្កើតបន្ថែមអង្គភាពថ្មីមួយទៀត ក្នុងនេះ ។

-ការបំបែកអង្គភាព :

នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សាត្រូវបានបំបែកជា ២ នាយកដ្ឋាន គឺ នាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ។

នាយកដ្ឋានឧត្តមសិក្សា និង សិក្សាឯកទេសត្រូវបានបំបែកជា ២នាយកដ្ឋាន គឺ នាយកដ្ឋាន ឧត្តមសិក្សា នាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

មន្ទីរត្រូវបានបំបែកជានាយកដ្ឋានរដ្ឋបាល និង នាយកដ្ឋានទំនាក់នងវប្បធម៌និងអាហារូបករណ៍ ( ការិយាល័យអាហារូបករណ៍ត្រូវបានផ្ទេរពីនាយកដ្ឋានឧត្តមសិក្សា និង សិក្សាឯកទេសមកក្នុងនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អារហារូបករណ៍ ) ។

នាយកដ្ឋានផែនការនិងហិរញ្ញវត្ថុត្រូវបានបំបែកជា ២ នាយកដ្ឋានគឺ នាយកដ្ឋាន ហិរញ្ញវត្ថុ នាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ ។ មុនចេញអនុក្រឹត្យលេខ ២១ អរក្រ.បក ក្រសួងមានបង្កើតអង្គភាពផែនការ និង សំរបសំរួលជំនួយតែមិនស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ និង ហិរញ្ញកិច្ចទេ ។

* ការប្តូរឈ្មោះអង្គភាព :

-នាយកដ្ឋានចាត់តាំងប្តូរឈ្មោះជានាយកដ្ឋានបុគ្គលិក

-វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្រ្ត ប្តូរឈ្មោះជា នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

* អង្គភាពបង្កើតថ្មី ( ថ្នាក់ស្មើនាយកដ្ឋាន )

-នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្រ្ត

---

* អង្គភាពចំនួន ២២ នេះរាប់ទាំងវិទ្យាស្ថានភាសាជាតិ ។ គ្រឹះស្ថានសិក្សារាប់ដោយឡែកពីនេះ ។

-នាយកដ្ឋានសុខភាពសិក្សា ( ពីមុនជាអង្គភាពអនាម័យសិក្សា ជាការិយាល័យចំណុះមន្ទីរ )

-នាយកដ្ឋានផែនការ ( ពីមុនជាអង្គភាពផែនការ និង សំរបសំរួលជំនួយ ).

-អធិការដ្ឋានអប់រំ និង អធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ( អធិការដ្ឋានត្រូវបានបង្កើតនៅគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋានក្នុងរចនាសម្ពន្ធ័ថ្មី ) ។

កំណត់សំគាល់សំខាន់មួយគឺក្នុងរចនាសម្ពន្ធ័ចាស់របស់ក្រសួងមានសាលាចំណេះទូទៅ និង មត្តេយ្យសិក្សា (វិទ្យាល័យ៣ អនុវិទ្យាល័យ ១ , បឋមសិក្សា ២ , មត្តេយ្យសិក្សា ១ ) ស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការ ។ ក្នុងរចនាសម្ពន្ធ័ថ្មី សាលារៀនចំណេះទូទៅ និង មត្តេយ្យសិក្សា មិនស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការទេ នឹង ត្រូវផ្ទេរទៅអោយមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញគ្រប់គ្រងវិញ ( សាលាអនុវត្តមានវិទ្យាល័យ ១ , បឋមសិក្សា ១ ជាករណីដោយឡែក ) ។

និន្នាការផ្ទេរសាលារៀនចំណេះទូទៅ និង មត្តេយ្យសិក្សាទៅអោយមន្ទីររាជធានីភ្នំពេញគ្រប់គ្រងមានកើតម្តងកាលពីឆ្នាំ១៩៩៤ តែអនុវត្តពុំទាន់បានដោយមានទំនាស់មួយចំនួន ( មន្ត្រីរាជការមានបំណងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការដដែល ) ។

២-<u>ការរៀបចំនានាជាជំហានដំបូង</u>

ក-ការរៀបចំថ្នាក់នាយកដ្ឋាន-លិខិតបង្គាប់ការលេខ ២៧៤ អយក-បុ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ១៩៩៨ ចុះហត្ថលេខាដោយ ឯកឧត្តម គា សាហាន រដ្ឋលេខាធិការ ជាការងារដំបូងបង្អស់ក្នុងការអនុវត្តអនុក្រឹត្យ លេខ ២១ អនក្រ-បក ។ ការតែងតាំងនេះធ្វើមុនចេញអនុក្រឹត្យ មួយរយៈខ្លី ។

នាយកដ្ឋាន វិទ្យាស្ថាន គ្រឹះស្ថាន ត្រូវបានចាត់តាំងដោយមានអ្នកទទួលខុសត្រូវគ្រប់គ្រងបណ្តោះអាសន្ន ក្នុងពេលរង់ចាំការតែងតាំងដោយលិខិតបទដ្ឋានខ្ពស់ជាង ( អនុក្រឹត្យ ) ។ ការចាត់តាំងនេះលើកលែងតែ អគ្គនាយក , អគ្គនាយករង អគ្គាធិការ , អគ្គាធិការរង , នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ , នាយកដ្ឋានយុវជន , នាយកដ្ឋានអប់រំកាយ និង កីឡា ,វិទ្យាស្ថានជាតិអប់រំកាយ និង កីឡា , អធិការដ្ឋានអប់រំ , អធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដែលរកមនុស្សមិនទាន់បាន រឺ មានបញ្ហាស្មុគ្រ ស្មាញមួយចំនួនពុំទាន់ដោះស្រាយរួច ។

មុននេះ ជាការត្រៀមបំបែក-បញ្ចូលអង្គភាព រឺ ការប្រគល់ភារកិច្ចថ្មីដល់អង្គភាព ក្រសួងបានចេញប្រកាសតែងតាំងថ្នាក់អនុប្រធាននាយកដ្ឋានមួយចំនួននៅនាយកដ្ឋានបុគ្គលិក នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ( ត្រូវបំបែកជាពីរ ) នាយកដ្ឋានឧត្តមសិក្សា និង សិក្សាឯកទេស ( ត្រូវបំបែកជាពីរ ) នាយកដ្ឋាផែនការ និង ហិរញ្ញកិច្ច ( ត្រូវបំបែកជាពីរ ) គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ និង មជ្ឈមណ្ឌលចែកផ្សាយ-បណ្ណាល័យ ( ត្រូវបញ្ចូលតែមួយ ) ។ល ។

ខ-ការរៀបចំការិយាល័យរបស់អង្គភាព_ នៅក្នុងអនុក្រឹត្យរបស់រាជរដ្ឋាភិបាលមានតែការបង្កើតនាយកដ្ឋាន អធិការដ្ឋាន និង អគ្គនាយកដ្ឋានប៉ុណ្ណោះ ។ ផ្អែកតាមភារកិច្ចរបស់នាយកដ្ឋាន និង អង្គភាពនីមួយ ៗ ក្រសួងបានចេញប្រកាសរៀបចំការិយាល័យរបស់បន្ទាប់ ដោយឈរលើគោលការណ៍ស្តីពីការបង្កើតរចនាសម្ពន្ធ័ :

-ការបង្កើតការិយាល័យនីមួយៗត្រូវអោយមានប្រយោជន៍សំខាន់បំរើដល់ការអភិវឌ្ឍ របស់អង្គភាព រឺ ក្រសួង

-ការិយាល័យទាំងអស់នៅក្នុងអង្គភាពមួយជាសំណុំជំនាញរឺបច្ចេកទេសដែលបំពេញអោយគ្នា ។ ដូចនេះចំនួនការិយាល័យត្រូវមានចំនួនសមស្រប មិនអោយតិចពេកជាហេតុនាំអោយយឺតយ៉ាវការងាររឺមិនរីកការងារ មិនអោយច្រើនពេកជាហេតុនាំអោយប្រទាំងប្រទើសគ្នា ដណ្តើមការងារគ្នា ។

-ការិយាល័យនីមួយៗត្រូវមាននិរន្តភាពការងារប្រចាំថ្ងៃ មានទំហំការងារសមស្រប មានចំនួនមន្ត្រីរាជការសមស្រប ។ ចៀសវាងការបង្កើតការិយាល័យដើម្បីផ្តល់ឋានៈអោយនរណាម្នាក់ ចៀសវាងការបង្កើតការិយាល័យដែលមានតែប្រធាន តែគ្មានអ្នកអនុវត្តជាកូនចៅ ។

តាមគោលការណ៍នេះ យើងរៀបចំការិយាល័យនៅតាមអង្គភាពជាបន្តបន្ទាប់ ( ក្នុងឧបសម្ព័ន្ធ ) ការិយាល័យខ្លះត្រូវលុបចោល ត្រូវផ្ទេរចេញ-ចូល បង្កើតថ្មីបញ្ចូនគ្នា រឺ ប្តូរឈ្មោះ ។

គ-ការផ្ទេរមន្ត្រីរាជការ-នៅជំហានទី ៣ នេះ ក្រសួងចេញប្រកាសផ្ទេរ (បែងចែក ) មន្ត្រីរាជការតាមនាយកដ្ឋាន រឺ អង្គភាពចាស់អោយសមស្របតាមរចនាសម្ព័ន្ធថ្មី ដើម្បីអោយឆ្លើយតបនឹងការបំបែក រឺ ការបញ្ចូលអង្គភាព ។ ការផ្ទេរមន្ត្រីរាជការនេះគឺលំនាំឈានទៅរៀបចំតារាងបៀវត្សដែលនឹងត្រូវរៀបចំទៅតាមអង្គភាពនីមួយៗ ។ អតីតនាយកដ្ឋានផែនការនិងហិរញ្ញកិច្ចបានអនុវត្តការងារនេះមុនគេ ដែលត្រូវចែកមន្ត្រីរាជការជា ៣ អង្គភាព ។

ឃ- ការតែងតាំងមន្ត្រីគ្រប់គ្រង- ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៨ ថ្នាក់ដឹកនាំក្រសួងបានធ្វើការប្រជុំគ្នាជាលើកដំបូង (ឯកឧត្តមរដ្ឋលេខាធិការ , អនុរដ្ឋលេខាធិការ ពូ ដារ៉ានី , ប៊ុន សុខ , ជ័យ ចាប , ប្រធានមន្ទីរ ហ៊ិន ខុន , ប្រធានស្តីទី ឆយ អួន ) ដើម្បីពិនិត្យពង្រាងសមាសភាពថ្នាក់ អគ្គនាយក-អគ្គនាយករង , អគ្គាធិការ-អគ្គាធិការរង , ប្រធាន-អនុប្រធាននាយកដ្ឋាន ។ ការងារនេះគឺបន្តរៀបចំពីលិខិតបង្គាប់ការ លេខ ២៧៤ អនក-ប្ញ ដែលប្រគល់ភារកិច្ចជាបណ្តោះអាសន្ន ដល់អ្នកគ្រប់គ្រងម្នាក់នៅឡើយ ។ ត្រូវមានការប្រជុំពិនិត្យបន្តទៀត ។

អង្គភាពផ្សេងៗ ក៏មានស្នើតែងតាំងថ្នាក់អនុប្រធាននាយកដ្ឋាន ថ្នាក់ការិយាល័យបន្ថែមទៀត អោយសមស្របតាមភារកិច្ចថ្មី។ គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ អនុវត្តការងារនេះមុនគេ ព្រោះជាអង្គភាពដែលកើតដោយអង្គភាព២បញ្ចូលគ្នា ។

ង-ការរៀបចំទីតាំង និង បែងចែកសំភារៈបរិក្ខារ - ការងារនេះត្រូវធ្វើជាបន្តទៀតសំរាប់អង្គភាពដែលពាក់ព័ន្ធ ។

បញ្ហាសំខាន់មួយ គឺ បញ្ហាទីតាំងរបស់អង្គភាព ។ ជារួមក្រសួងអប់រំ យុវជន និង កីឡាខ្វះកន្លែងសំរាប់ធ្វើការ ទាំងអាគារ ទាំងបន្ទប់ ។

នាយកដ្ឋានទំនាក់ទំនងវប្បធម៌ និង អាហារូបករណ៍ នាយកដ្ឋានសុខភាពសិក្សាមានទីតាំងតូចចង្អៀត ។ នាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋត្រូវរំលែកទីតាំងពីគេ។ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រត្រូវរកទីតាំងថ្មី ព្រោះអង្គភាពបង្កើតថ្មី ។

ច-ការការកសាងលិខិតបទដ្ឋាននានា - ក្នុងជំហានបន្ទាន់មួយដែលត្រូវដោះស្រាយបន្ទាប់ពីពេលរង់ចាំដ៏យូរមកនោះ គឺការចេញសារាចរណែនាំលេខ ០៣ សរណន. ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំរចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និងការិយាល័យអប់រំ យុវជន និង កីឡា ស្រុកខ័ណ្ឌ ( ក្នុងឧបសម្ព័ន្ធ ) ។ មុននេះ សារាចរណែនាំ ៥៨ អវ.ចត ចុះថ្ងៃ ទី ០៥ ខែ ឧសភា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និង ការចាត់តាំងមន្ទីរអប់រំ ខេត្ត-ក្រុង និង ការិយាល័យអប់រំស្រុក-ទីរួមខេត្ត ត្រូវបានអនុវត្តដោយមានការកែលំអការងារមួយចំនួន ដូចជា រៀបចំភារកិច្ច ( ភារកិច្ចផ្ទេរចូលពី យុវជន ពីវប្បធម៌ ) ការរៀបចំអ្នកទទួលខុសត្រូវ និង ការិយាល័យនៅមន្ទីរជាដើម អោយសមស្របតាមការជាក់ស្តែងរហូតដល់ពេលចេញសារាចរលេខ ០៣ សរណន. ជាផ្លូវការ ។

ជាមួយនេះ នៅថ្នាក់កណ្តាល មានចេញប្រកាសស្តីពីភារកិច្ចការិយាល័យនៅតាមអង្គភាពនីមួយៗ ប្រកាសស្តីពីការអនុញ្ញាតអោយប្រើប្រាស់ត្រាមូល និង លិខិតណែនាំខ្លះៗទៀត ដូចជាណែនាំអំពីការប្រើប្រាស់អក្សរសំគាល់អង្គភាព សំគាល់អគ្គនាយកដ្ឋាន និង អគ្គា ធិការដ្ឋាន អំពីការចុះហត្ថលេខា ។ល។

# ថ្នាក់ខេត្ត-ក្រុង

## I-រចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង

នៅឆ្នាំ ១៩៧៩ រចនាសម្ព័ន្ធខ្សែបណ្តោយរបស់ក្រសួងអប់រំមាន ៥ ថ្នាក់គឺ : ថ្នាក់មជ្ឈិម រឺ ថ្នាក់កណ្តាល ( ទីស្តីការក្រសួង ) ថ្នាក់ខេត្ត-ក្រុង គឺ មន្ទីរអប់រំ ថ្នាក់ស្រុក-ខ័ណ្ឌ គឺ ការិយាល័យអប់រំ និង ថ្នាក់ឃុំគឺ គណៈកម្មការអប់រំឃុំ និង ថ្នាក់សាលារៀន ។

អំពីគណៈកម្មការអប់រំឃុំទទួលបន្ទុកការអប់រំចំណេះទូទៅនៅតាមឃុំ ។ ចំណែកការអប់រំមនុស្សចាស់មានគ្រូបង្គោលម្នាក់សំរាប់ជំរុញការងារនេះនៅតាមឃុំ ។ ពេលនោះការងារអប់រំមនុស្សចាស់មានផែនការការងារថ្នាក់ជាតិ មានសកម្មភាពយ៉ាងខ្លាំងក្លាតាមរយៈក្រុមសាមគ្គីបង្កបង្កើនផល ។ នៅរវាងឆ្នាំ ១៩៨១ អប់រំឃុំក៏ចាត់ ។ គ្រូបង្គោលនៅបន្តការងារតែចុះថយបន្តិចម្តង ៗ ពេលដែលក្រុមសាមគ្គីត្រូវថយឥទ្ធិពល ដោយមូលហេតុនៅតាមមូលដ្ឋានគេឈានទៅរករបបសេដ្ឋកិច្ចឯកជន សេដ្ឋកិច្ចទីផ្សារសេរី ។ នៅទីបំផុតខ្សែបណ្តោយរបស់ក្រសួងអប់រំនៅសល់តែ ៤ ថ្នាក់ គឺថ្នាក់កណ្តាល (ទីស្តីការ ) ថ្នាក់ខេត្ត-ក្រុង ថ្នាក់ស្រុក-ខ័ណ្ឌ និង សាលារៀន ។ ដោយឡែក ការបង្កើតកំរងសាលារៀន ( Cluster Schools )* ដែល ឧបត្ថម្ភឡើងដោយ UNICEF ជាការចងក្រងដើម្បីពង្រឹងបច្ចេកទេស ។ ក្នុងកំរងនីមួយៗ មានសាលារៀន បឋមសិក្សា ១ ក្រុម ( មានដល់ ៥ សាលារៀន ) ក្នុងនេះមានសាលារៀនមួយជាប្រធានកំរងមានលទ្ធភាព និង សមត្ថភាពគរុកោសល្យបច្ចេកទេស មូលដ្ឋានសំភារៈ.. ល្អជាងគេអាចជួយដល់សមាជិកកំរងដែលមាន លទ្ធភាព និង សមត្ថភាពតិចជាង ។ កំរងមានលទ្ធភាពក្តាប់កុមារនិងសិស្សបានងាយស្រួល ។ កំរងសាលា រៀនបឋមសិក្សាមិនមែនជាលំដាប់ថ្នាក់ណាមួយនៃរចនាសម្ព័ន្ធខ្សែបណ្តោយរបស់ក្រសួងអប់រំទេ ។

<u>កំណត់សំគាល់ :</u> - ក្នុងការរៀបចំមន្ទីរនានាដំបូង នៅខេត្ត-ក្រុងតូច ៗ ការងារអប់រំនិងការងារវប្បធម៌ត្រូវបញ្ចូលជាមន្ទីរតែមួយឈ្មោះថា" មន្ទីរអប់រំវប្បធម៌ " ដូចជាក្រុងព្រះសីហនុជាដើម ។ នៅស្រុក ការិយាល័យអប់រំ និង វប្បធម៌ក៏រួមគ្នាដែរ ។

ក្រោយមក មន្ទីរដែលរួមគ្នាត្រូវបានបំបែកគ្នាបណ្តើរ ៗ ទៅជាមន្ទីរអប់រំមួយដោយឡែកដាច់ចេញពីវប្បធម៌ ។ នៅស្រុកក៏មានបំបែកជាការិយាល័យអប់រំស្រុកដោយឡែកដែរ ។

មកដល់ឆ្នាំ១៩៨៥ មន្ទីរដែលរួមគ្នាបានបំបែកចេញពីគ្នាអស់ហើយ នៅតាមស្រុកនៅមានការិយាល័យអប់រំ និង វប្បធម៌រួមគ្នានៅឡើយ ដោយពុំទាន់មានលទ្ធភាពផ្តាច់ចេញពីគ្នា ។

---

* កំរងសាលារៀន គឺជាការប្រមូលផ្តុំសាលាបឋមសិក្សាពី ៤ ទៅ ៧ សំរាប់ជួយគ្នាទៅវិញទៅមក លើការងាររដ្ឋបាល ការងារគ្រប់គ្រង ការងារបច្ចេកទេស និងគោលដៅអប់រំ ។

## ១_និនាក់និនខរចនាសម្ព័ន្ធថ្នាក់កណ្តាលនិងថ្នាក់ខេត្ត_ក្រុង

ក/_ និន្នាការបំបែកមន្ទីរអប់រំ _ ចាប់ពីឆ្នាំ ១៩៧៩ នៅថ្នាក់កណ្តាលមាន នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា (ន.ចទម ) រួមតែមួយទទួលបន្ទុកការសិក្សាបឋមសិក្សា _មធ្យមសិក្សាបឋមភូមិ _មធ្យមសិក្សាទុតិយភូមិនិងមត្តេយ្យសិក្សា គឺចែកជាការិយាល័យបឋមសិក្សា ការិយាល័យមត្តេយ្យសិក្សា ការិយាល័យមធ្យមសិក្សា ។ រវាងឆ្នាំ ១៩៩១ មាននិន្នាការបំបែកនាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សានៅថ្នាក់កណ្តាលអោយទៅជានាយកដ្ឋាន២ ដោយឡែកពីគ្នាដូចជាមុនឆ្នាំ ១៩៧៥ គឺនាយកដ្ឋានបឋមសិក្សា ( DEP ) និង នាយកដ្ឋានមធ្យមសិក្សា ( DESec ) ។ និន្នាការនេះត្រូវបានរក្សាទុកហើយការអនុវត្តក៏មានដំណើរការបន្តិចម្តងៗរហូតដល់ពេលចេញអនុក្រឹត្យលេខ ២១ អនក្រ.បក តែម្តង ។ នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សាក៏ត្រូវបំបែកជា ២ ស្ថាពរគឺ :

នាយកដ្ឋាន បឋមសិក្សា និង មត្តេយ្យសិក្សា

នាយកដ្ឋាន មធ្យមសិក្សាចំណេះទូទៅ

ដោយឡែក មុនឆ្នាំ ១៩៧៥ នៅថ្នាក់ខេត្ត-ក្រុង មានខ្សែបណ្តោយនៃនាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានមធ្យមសិក្សាដោយឡែកពីគ្នា ។ នៅខេត្តមាននាយកនៃមធ្យមសិក្សា និង អធិការដ្ឋានបឋមសិក្សា ។ ពេលមាននិន្នាការបំបែកនាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សានៅថ្នាក់កណ្តាល ខេត្ត-ក្រុង ក៏មាននិន្នាការបំបែកមន្ទីរអប់រំជា ២ ដោយឡែកពីគ្នា គឺមានស្ថាប័នអប់រំ ២ នៅ ខេត្ត-ក្រុង ស្ថាប័នអប់រំមួយទទួលបន្ទុកបឋមសិក្សា ស្ថាប័នមួយទៀតទទួលបន្ទុកមធ្យមសិក្សា ។

### រចនាសម្ព័ន្ធខ្សែបណ្តោយ បឋមសិក្សា និង មធ្យមសិក្សា មុនឆ្នាំ ១៩៧៥



និន្នាការនេះមិនត្រូវអនុវត្តបានទេ ដោយមូលហេតុធំ ៗ ៣ គឺ :

-មុនឆ្នាំ១៩៧៥ ដែលកំពុងអនុវត្តការបំបែកការងារគ្រប់គ្រងបឋមសិក្សានិងមធ្យមសិក្សាដោយឡែក នេះក៏មាននិន្នាការបញ្ចូលការគ្រប់គ្រងតែមួយរួមគ្នាវិញដែរ បន្ទាប់មកពីឆ្លងកាត់បទពិសោធន៍លំបាកមួយចំនួន ។

-មន្ត្រីគ្រប់គ្រងសំរាប់រ៉ាប់រងការងារក៏មានការខ្វះខាត ។ អាគារសំរាប់ទីតាំងធ្វើការក៏មិនគ្រប់ចំនួន ។ រហូតមកដល់ឆ្នាំ ១៩៩៨ នេះ ខេត្ត-ក្រុងខ្លះពុំទាន់មានទីតាំងមន្ទីរ អាគារសមរម្យនៅឡើយដូចជាក្រុងព្រះសីហនុ ក្រុងកែប ។ល។

-ការងារមួយចំនួនខុសពីមុនឆ្នាំ ១៩៧៥ គឺបច្ចុប្បន្នមានមត្តេយ្យសិក្សា យុវជន និង កីឡា អប់រំក្រៅប្រព័ន្ធដែលទាមទារអោយមានការរៀបចំលំបាកមួយ បើសិនជាបំបែកមន្ទីរនៅខេត្ត-ក្រុង ។ ពីមុននោះការងារធំមានតែបឋមសិក្សា និង មធ្យមសិក្សា ។

ខ/-ការអនុវត្តដំណាក់កាលឆ្នាំ ១៩៧៩-៩៨ (មុនចេញអនុក្រឹត្យលេខ ២១ អនក្រ-បក)

-សារាចរណែនាំលេខ ៥៨ អរ-ចត ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៨៤ បានកំណត់តួនាទី ភារកិច្ច និងការចាត់តាំងនៃមន្ទីរអប់រំខេត្ត-ក្រុង និង ការិយាល័យអប់រំស្រុក-ទីរួមខេត្ត (សូមមើលក្នុងឧបសម្ព័ន្ធ) ។

នៅដំណាក់កាលនេះខេត្ត-ក្រុងមានចំនួន ២០ (ខេត្តបន្ទាយមានជ័យ ជាខេត្តទី ២១ បង្កើតក្រោយឆ្នាំ ១៩៨៤) ។ ដោយយោលទៅតាមក្របខ័ណ្ឌបុគ្គលិក ចំនួនសាលារៀន សិស្ស ភូមិសាស្ត្រ និង ទំហំការងារខេត្តទាំង២០នោះ ត្រូវបានចាត់ថ្នាក់ជា៣ប្រភេទ និងកំណត់អោយមានការិយាល័យដូចខាងក្រោម :

*-ប្រភេទទី ១ :

ខេត្ត-ក្រុងចំនួន ៩ គឺ កំពង់ចាម,កណ្ដាល,បាត់ដំបង,តាកែវ,ភ្នំពេញ,ព្រៃវែង,សៀមរាប, កំពត និង ស្វាយរៀង, មាន៥ ការិយាល័យ :

-ការិយាល័យរដ្ឋបាល និង បូកសរុប

-ការិយាល័យផែនការ ស្ថិតិ-គណនេយ្យ និង សំភារៈបរិក្ខារ

-ការិយាល័យចំណេះទូទៅ និង មត្តេយ្យសិក្សា

-ការិយាល័យអប់រំមនុស្សចាស់

-ការិយាល័យចាត់តាំង និង បណ្ដុះបណ្ដាលវិក្រឹតការ

*-ប្រភេទទី ២ :

ខេត្តចំនួន ៥ គឺ កំពង់ធំ,កំពង់ស្ពឺ,ពោធិសាត់,កំពង់ឆ្នាំង, និង ក្រចេះ មាន ៤ ការិយាល័យ :

-ការិយាល័យរដ្ឋបាលផែនការស្ថិតិ និង គណនេយ្យ សំភារៈបរិក្ខារ

-ការិយាល័យចំនេះទូទៅ និង មត្តេយ្យសិក្សា

-ការិយាល័យអប់រំមនុស្សចាស់

-ការិយាល័យចាត់តាំង និង បណ្តុះបណ្តាលវិក្រឹតការ

*-ប្រភេទទី ៣ :

ខេត្ត-ក្រុងចំនួន ៦ គឺព្រះវិហារ,ស្ទឹងត្រែង,កោះកុង,ក្រុងកំពង់សោម ( បច្ចុប្បន្នក្រុងព្រះសីហនុ ) រតនគិរី និង មណ្ឌលគិរី មាន ៣ ការិយាល័យ :

-ការិយាល័យរដ្ឋបាល ចាត់តាំង និង បណ្តុះបណ្តាលវិក្រឹតការ

-ការិយាល័យចំណេះទូទៅ និង មត្តេយ្យសិក្សា និង អប់រំមនុស្សចាស់

-ការិយាល័យផែនការ ស្ថិតិ គណនេយ្យ និង សំភារៈបរិក្ខារ

ការអនុវត្តសារាចរនេះរបស់មន្ទីរអប់រំមានលំនាំព្រមគ្នា នឹងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ តាមក្រឹត្យច្បាប់ លេខ ៤ ក្រច-ក្រប ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨០ (សូមមើល ១ និង ២ ត្រង់ II នៃថ្នាក់កណ្តាល ក្នុងផ្នែកទី ២ នេះ ) ។

- ការផ្ទេរភារកិច្ចថ្មីចូលមន្ទីរអប់រំ នៅថ្នាក់ខេត្ត-ក្រុងមានការផ្ទេរភារកិច្ច ២ ថ្មីចូលមន្ទីរ គឺ ភារកិច្ចយុវជន និង ភារកិច្ចកីឡា ។ ភារកិច្ចយុវជន ផ្ទេរមកពីមន្ទីរយុវជន (មុនបោះឆ្នោត ) និង ភារកិច្ចកីឡាផ្ទេរមកពីមន្ទីរវប្បធម៌ខេត្ត-ក្រុង (ក្រោយបោះឆ្នោត ) ។ ការផ្ទេរទាំងនេះមិនសាំញ៉ាំដូចនៅថ្នាក់កណ្តាលដែលពាក់ពន្ធ័នឹងការបំបែកក្រសួង បង្កើតក្រសួង បញ្ចូលក្រសួងនោះទេ ។

នៅថ្នាក់ខេត្ត ការផ្ទេរនេះមាននៅថ្នាក់ខេត្តផង ស្រុកផង ។ មន្ត្រីគ្រប់គ្រងខាងយុវជន ( គណៈកម្មការ សម្ពន្ធ័យុវជនខេត្ត ) ក្នុងនោះមានមន្ត្រីគ្រប់គ្រង ថ្នាក់ប្រធាន-អនុប្រធានយុវជន បានផ្ទេរចូលមន្ទីរអប់រំ ហើយបន្តឋានៈរហូតមក ។ មន្ទីរអប់រំក៏រៀបចំអោយទទួលឋានៈថ្មី និង ភារកិច្ចយុវជន ។ មន្ត្រីរាជការ យុវជនមួយចំនួនធំបានផ្ទេរចូលមន្ទីរអប់រំ រឺនៅការិយាល័យអប់រំស្រុក ។ ខ្សែទទឹងបានធ្វើការងារនេះមុនពេលបោះឆ្នោត ព្រោះកាលនោះការគ្រប់គ្រងយ៉ាងនេះ ។ ថ្នាក់កណ្តាលក៏ទទួលបន្តរាប់ជាមន្ត្រីរាជការរបស់ក្រសួង ។

មន្ត្រីរាជការខាងវប្បធម៌ដែលទទួលបន្ទុកកីឡាមិនផ្ទេរមកទាំងអស់ទេព្រោះគេនៅមានមន្ទីរវប្បធម៌របស់គេ ។ ក្រសួងធ្វើប្រកាសទទួលមន្ត្រីរាជការមកពីមន្ទីរវប្បធម៌ ។

ការផ្ទេរនេះគឺផ្ទេរភារកិច្ចនិងមនុស្ស ហើយមន្ទីរមានឈ្មោះជា មន្ទីរអប់រំ យុវជន និង កីឡារហូតមក ។ មន្ទីរបានបង្កើតអោយមានការិយាល័យយុវជន ការិយាល័យកីឡាតាមជាក់ស្តែងខេត្ត-ក្រុងធំតូចតាមការណែនាំរបស់ក្រសួងក្នុងឱកាសសន្និបាតអប់រំប្រចាំឆ្នាំ កាលនោះនៅក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ (១៩៩៣) ។ ការណែនាំនេះមិនមានជាលាយលក្ខណ៍អក្សរទេ ដោយរង់ចាំការបង្កើតរចនាសម្ព័ន្ធក្រសួង ។

តែការអនុវត្តចេះតែបន្តរហូតមកបានដល់ដើមឆ្នាំ ១៩៩៨ ។

ការផ្ទេរនេះមានគ្រប់ខេត្ត-ក្រុង ។ កំណត់សំគាល់មួយ គឺ សំភារៈបរិក្ខារ អាគារ-ដីធ្លី មិនត្រូវបានផ្ទេរអោយមកជាប្រយោជន៍ដល់មន្ទីរអប់រំយុវជននិងកីឡាទេ ដោយបញ្ហាគ្រប់គ្រងស្មុគ្រស្មាញពេលនោះ ។ ក្រសួងអប់រំយុវជន និង កីឡា បានទទួលតែភារកិច្ច និង មនុស្សប៉ុននោះ ។

**២-ការបង្កើតមន្ទីរអប់រំ យុវជន និង កីឡា ថ្មី**

ក/-មន្ទីរអប់រំយុវជន និងកីឡាក្រុងកែប-អនុក្រឹត្យលេខ៥៩ អនក្រ ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ១៩៩៤ របស់រាជរដ្ឋាភិបាលកម្ពុជាបានប្តូរឋានៈសម្ពន្ធ័រដ្ឋបាលក្រុងកែប ពីថ្នាក់ស្រុកចំណុះរដ្ឋបាលខេត្តកំពតមកជាថ្នាក់ក្រុង ។ យោងអនុក្រឹត្យនេះ ក្រសួងបានចេញប្រកាសលេខ ២៤ អយក.ប្រក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥ ប្តូរឋានៈសម្ពន្ធ័ថ្នាក់ការិយាល័យអប់រំ យុវជន និង កីឡាក្រុងកែបចំណុះមន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពតមកជាថ្នាក់មន្ទីរអប់រំយុវជននិងកីឡា ក្រុងកែប ចំណុះផ្ទាល់ក្រសួងអប់រំ យុវជន និង កីឡា ។

មន្ទីរអប់រំ យុវជន និង កីឡាក្រុងកែបជាមន្ទីរទី ២២ របស់ក្រសួង មានការិយាល័យខ័ណ្ឌចំនួន ២ ថ្នាក់ស្មើការិយាល័យអប់រំ យុវជននិងកីឡាស្រុកនានា គឺ ការិយាល័យអប់រំ យុវជន និង កីឡាខ័ណ្ឌ កែប និង ការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌដំណាក់ចង្អើរ ។

ខ/-មន្ទីរអប់រំ យុវជន និង កីឡាក្រុងប៉ៃលិន-ព្រះរាជក្រឹត្យ ជស.រកត.០៧៩៧-១៤៤ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៧ បានបង្កើតក្រុងប៉ៃលិន ។ អាជ្ញាធរដែលមានសមត្ថកិច្ចគ្រប់គ្រងក្រុងនេះត្រូវស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ ។ ក្រុងប៉ៃលិនមានខ័ណ្ឌចំនួន ២ គឺ ខ័ណ្ឌប៉ៃលិន និង ខ័ណ្ឌសាលាក្រៅ ។ យោងព្រះរាជក្រឹត្យនេះ ក្រសួងបានចេញប្រកាសលេខ ៧៩៣ អយក.ប្រក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ បង្កើតមន្ទីរអប់រំ យុវជន និង កីឡាក្រុងប៉ៃលិន ចំណុះផ្ទាល់ក្រសួងអប់រំ យុវជន និង កីឡា ។

មន្ទីរអប់រំ យុវជន និង កីឡាក្រុងប៉ៃលិនជាមន្ទីរទី ២៣ របស់ក្រសួងមានការិយាល័យខ័ណ្ឌចំនួន ២ ថ្នាក់ស្មើការិយាល័យអប់រំ យុវជននិងកីឡា ស្រុកនានាគឺ ការិយាល័យអប់រំ យុវជននិងកីឡា ខ័ណ្ឌប៉ៃលិន និង ការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌសាលាក្រៅ ។

កំណត់សំគាល់ដ៏សំខាន់មួយពាក់ពន្ធ័ការបង្កើតមន្ទីរថ្មីនេះ គឺ ព្រឹត្តិការណ៍ប្រវត្តិសាស្រ្តមួយដែលកើតមានក្នុងរយៈពេលឆ្លងកាត់ជិត ២០ ឆ្នាំ (ពី ១៩៧៩ ដល់ ១៩៩៧) ។ ខ្មែរក្រហមដែលដឹកនាំដោយលោក អៀង សារី (ពីមុនជាក្រុម ប៉ុល ពត -អៀង សារី - ខៀវ សំផន) បានផ្តាច់ខ្លួនពីក្រុមខ្មែរក្រហមក្បាលរឹង ប៉ុល ពត , ខៀវ សំផន , តា ម៉ុក ចូលមករួបរួមជាមួយរាជរដ្ឋាភិបាល ដោយរក្សាការគ្រប់គ្រងនៅអតីតតំបន់របស់ខ្លួន ។ ក្រុងប៉ៃលិនក៏ត្រូវបានបង្កើតឡើងគ្រប់គ្រងដោយអតីតខ្មែរក្រហមផ្តាច់ខ្លួន ស្ថិតនៅក្រោមការដឹកនាំរបស់ ក្រសួងមហាផ្ទៃ ។

## ៧/-ការអនុវត្តសារាចរណែនាំលេខ ០៣ អយក.សរណន ( ក្នុងឆ្នាំ )

ក/-រចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង - ក្រោយសារាចរណែនាំលេខ ៥៨ អវ.ចត ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៨៤ ពុំមានសារាចរ រឺ លិខិតបទដ្ឋានណែនាំការអនុវត្តនោះនៅមន្ទីរទេ ក្រៅពីការណែនាំក្នុងសន្និបាតអប់រំ ( ១៩៩៣ ) ដែលពាក់ព័ន្ធដល់បញ្ហា ៣ គឺ : ការបំបែកការិយាល័យចំណេះទូទៅនិងមត្តេយ្យសិក្សាពីមុនជាការិយាល័យបឋមនិងមត្តេយ្យ ការិយាល័យមធ្យមសិក្សា ការបង្កើតអោយមានការិយាល័យយុវជន ការិយាល័យកីឡា ។ មូលហេតុដែលនាំមិនអោយចេញជាលិខិតបទដ្ឋានអ្វីនោះ គឺរង់ចាំរចនាសម្ព័ន្ធរបស់ក្រសួងចេញជាមុន (អនុក្រឹត្យលេខ ២១ អនក្រ.បក ) ។

ពេលចេញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ការិយាល័យនីតិកម្មនៃនាយកដ្ឋានបុគ្គលិកបានរៀបចំសារាចរណែនាំ លេខ ០៣ អយក.សរណនចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំរចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុង និង ការិយាល័យអប់រំ យុវជន និង កីឡាស្រុក-ខ័ណ្ឌ ។

មន្ទីរអប់រំ យុវជន និង កីឡាខេត្ត-ក្រុងជាអង្គភាពជំនាញខ្សែរយៈបណ្តោយ ចំណុះក្រសួង អប់រំ យុវជន និង កីឡាមានភារកិច្ចគ្រប់គ្រងវិស័យអប់រំ យុវជន និង កីឡា នៅតាមខេត្ត-ក្រុង ។

ដោយយោលទៅតាមក្របខ័ណ្ឌមន្ត្រីរាជការ ចំនួនសាលានិងសិស្ស ភូមិសាស្ត្រ និង ទំហំការងាររចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុងទាំង ២៣ ត្រូវកំណត់ដូចខាងក្រោម :

-ខេត្ត-ក្រុង ចំនួន ៦ គឺ ខេត្តកំពង់ចាម,កណ្តាល,តាកែវ, បាត់ដំបង,ព្រៃវែងនិង រាជធានីភ្នំពេញ មាន ១១ ការិយាល័យ :

១-ការិយាល័យ រដ្ឋបាល

២-ការិយាល័យ បុគ្គលិក និង បណ្តុះបណ្តាល

៣-ការិយាល័យ ផែនការ និង គ្រប់គ្រងជំនួយ

៤-ការិយាល័យ គណៈនេយ្យ សំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ

៥-ការយាល័យ បឋម និង មត្តេយ្យសិក្សា

៦-ការិយាល័យ មធ្យមសិក្សាចំណេះទូទៅ

៧-ការយាល័យ អប់រំក្រៅប្រពន្ធ័ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

៨-ការិយាល័យ ប្រលង

៩-ការិយាល័យ យុវជន

១០-ការិយាល័យ កីឡា

១១-ការិយាល័យ អធិការកិច្ច

ការងារសំណង់អាគារសិក្សានៅក្នុងការិយាល័យគណនេយ្យសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ ។

-ខេត្តចំនួន ៩ គឺ ខេត្តកំពង់ស្ពឺ , កំពង់ឆ្នាំង, កំពត , កំពង់ធំ , ស្វាយរៀង , ក្រចេះ , ពោធិសាត់ , បន្ទាយមានជ័យ , សៀមរាប មាន ៩ ការិយាល័យ :

១-ការិយាល័យ រដ្ឋបាល

២-ការិយាល័យ បុគ្គលិក និង បណ្តុះបណ្តាល

៣-ការិយាល័យ ផែនការ គណនេយ្យ និង សំភារៈ

៤- ការិយាល័យ បឋម និង មត្តេយ្យសិក្សា

៥- ការិយាល័យ មធ្យមសិក្សាចំណេះទូទៅ

៦- ការិយាល័យ អប់រំក្រៅប្រពន្ធ័ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

៧- ការិយាល័យ យុវជន

៨-ការិយាល័យ កីឡា

៩- ការិយាល័យ អធិការកិច្ច

ចំពោះខេត្តទាំងនេះ ការគ្រប់គ្រងជំនួយ សំណង់អាគារសិក្សា និង ទ្រព្យសម្បត្តិរដ្ឋ នៅក្នុងការិយាល័យផែនការ គណនេយ្យ និង សំភារៈ ។ ការងារប្រលងនៅក្នុងការិយាល័យមធ្យមសិក្សា ចំណេះទូទៅ ។

-ខេត្ត-ក្រុង ចំនួន ៨ គឺ ក្រុងព្រះសីហនុ , ក្រុងកែប , ក្រុងប៉ៃលិន , ខេត្តកោះកុង , ស្ទឹងត្រែង , មណ្ឌលគីរី , រតនគីរី , ព្រះវិហារ , មាន ៧ ការិយាល័យ :

១-ការិយាល័យ រដ្ឋបាល បុគ្គលិក និង បណ្តុះបណ្តាល

២-ការិយាល័យ ផែនការ គណនេយ្យ និង សំភារៈ

៣-ការិយាល័យ បឋម និង មត្តេយ្យសិក្សា

៤- ការិយាល័យ មធ្យមសិក្សាចំណេះទូទៅ

៥- ការិយាល័យ អប់រំក្រៅប្រពន្ធ័ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

៦- ការិយាល័យ យុវជន និង កីឡា

៧- ការិយាល័យ អធិការកិច្ច

ចំពោះខេត្ត-ក្រុង ទាំងនេះ ការគ្រប់គ្រងជំនួយ សំណង់អាគារសិក្សា និង ទ្រព្យសម្បត្តិរដ្ឋ នៅក្នុងការិយាល័យផែនការ គណៈនេយ្យ និង សំភារៈ ។ ការប្រលងនៅក្នុងការិយាល័យមធ្យមសិក្សាចំណេះទូទៅ ការងារយុវជន និង កីឡា ត្រូវបានបញ្ចូលគ្នាជាការិយាល័យតែមួយ ។

## ឃ/-រចនាសម្ព័ន្ធការិយាល័យអប់រំ យុវជន និង កីឡាស្រុក-ខ័ណ្ឌ

-រចនាសម្ព័ន្ធការិយាល័យអប់រំ យុវជននិងកីឡាស្រុក-ខ័ណ្ឌ ត្រូវបានរៀបចំរចនាសម្ព័ន្ធតែមួយដូចគ្នាសំរាប់គ្រប់ស្រុក-ខ័ណ្ឌ គឺ :

-ផ្នែកចំណេះទូទៅ និង មត្តេយ្យសិក្សា

-ផ្នែកអប់រំក្រៅប្រព័ន្ធ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-ផ្នែកយុវជន និង កីឡា

-ផ្នែករដ្ឋបាល បុគ្គលិក និង គណនេយ្យ

ផ្នែករដ្ឋបាល បុគ្គលិក និង គណនេយ្យមានភារកិច្ចជួយសំរបសំរួលការងាររដ្ឋបាលរបស់គ្រឹះស្ថានមធ្យមសិក្សាទាំងអស់នៅក្នុងស្រុក-ខណ្ឌ ជាមួយមន្ទីរ ។

កន្លងមក មន្ទីរមួយចំនួនបានផ្តាច់ការងារមធ្យមសិក្សា ( វិទ្យាល័យ និង អនុវិទ្យាល័យ ) នៅតាមស្រុកជាមួយការិយាល័យអប់រំយុវជន និង កីឡាស្រុក-ខ័ណ្ឌរួចហើយ ពិតមែនតែពុំមានលិខិតបទដ្ឋានណែនាំជាផ្លូវការរបស់ក្រសួង ។ ការផ្តាច់ការងារនេះគឺយកលំនាំតាមមុនឆ្នាំ ១៩៧៥ ។

សភាពការណ៍ថ្មីកម្ពុជាតំរូវអោយការិយាល័យស្រុក - ខណ្ឌជួយសំរបសំរួលការងាររដ្ឋបាលរបស់គ្រឹះស្ថានមធ្យមសិក្សាជាមួយមន្ទីរដូចជាការបញ្ជូនលិខិត , ការផ្តល់ស្ថិតិសិស្ស-គ្រូ ( គ្រូ សិស្ស ជាពលរដ្ឋក្នុងស្រុក-ខ័ណ្ឌ ) ការងារ សណ្តាប់ធ្នាប់សង្គម ។ល។

## គ/-ការដឹកនាំមន្ទីរអប់រំ យុវជន និង កីឡា

ការបែងចែកភារកិច្ចគណៈមន្ទីរកន្លងមកផ្អែកលើសារាចរ ណែនាំលេខ៥៨ អរ.ចតត្រង់ចំណុច II :

" ប្រធានមន្ទីរអប់រំខេត្ត - ក្រុង ទទួលខុសត្រូវរួមចំពោះគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង និងក្រសួងអប់រំអំពីការងារអប់រំ ហើយទទួលបន្ទុកដោយឡែកបណ្តាភារកិច្ចដូចជាកិច្ចការនយោបាយ សតិអារម្មណ៍ ផែនការ និង ចាត់តាំងកម្មាភិបាល ។ ឯបណ្តាភារកិច្ចឯទៀត ៗ ត្រូវបែងចែកជូនបណ្តាអនុប្រធាន អោយបានសមស្របតាមសមត្ថភាព និង ទេពកោសល្យ " ។

នៅខែមេសា ឆ្នាំ ១៩៩៨ សារាចរណែនាំលេខ ០៣ អយក.សរណន កំណត់ភារកិច្ចគណៈមន្ទីរដូចខាងក្រោម :

ប្រធានមន្ទីរអប់រំ យុវជននិងកីឡា ខេត្ត-ក្រុង ទទួលខុសត្រូវរួមចំពោះក្រសួង អំពីការងារអប់រំ យុវជន និង កីឡា ទទួលខុសត្រូវផ្ទាល់ការិយាល័យអធិការកិច្ច ហើយអាចទទួលបន្ទុកដោយឡែកភារកិច្ចសំខាន់ៗដូចជាការងារ បុគ្គលិក និង បណ្តុះបណ្តាល ការងារផែនការ និង គ្រប់គ្រងជំនួយ ។ ឯភារកិច្ចផ្សេងៗទៀត ប្រធានត្រូវបែងចែក ជូនអនុប្រធានមន្ទីរអោយសមស្របតាមសមត្ថភាពជំនាញនិងសមត្ថភាពគ្រប់គ្រង ។ អនុប្រធានមន្ទីរម្នាក់អាចទទួលបន្ទុកការងារ រឺ ការិយាល័យមួយ រឺ ច្រើនតាមការជាក់ស្តែង

ដែលប្រធានមន្ទីរប្រគល់ជូន ។

សារាចរនេះកំណត់អោយប្រធានមន្ទីរទទួលខុសត្រូវរួមចំពោះក្រសួង ខុសពីមុនដែលត្រូវទទួលខុសត្រូវចំពោះ " គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង " និង ក្រសួងអប់រំ ។ ពេលនោះត្រូវទទួលខុសត្រូវចំពោះគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងមុនក្រសួង ព្រោះជាការគ្រប់គ្រងខ្សែទទឹង ។

ចំនួនអនុប្រធានមន្ទីរមិនត្រូវបានកំណត់ច្រើនតិចតាមខេត្ត-ក្រុង តូចធំទេ គឺអាស្រ័យទៅតាមការជាក់ស្តែងនីមួយៗ ។ កំណត់សំគាល់មួយ គឺ ប្រធាន-អនុប្រធានមន្ទីរយុវជនដែលផ្ទេរចូលមន្ទីរអប់រំ ( ទូទៅ ១ នាក់ ក្នុង ១ ខេត្ត ) សមត្ថភាពជួយការងារអប់រំរបស់គេនៅមានកំរិត ក្រៅពីជំនាញរបស់គេធ្លាប់ពីមុន ។ ដូចនេះមន្ទីរ ត្រូវមានអ្នកដទៃទៀត ២-៣ នាក់ ជួយរ៉ាប់រងការងារអប់រំ ។

ជាគោលការណ៍ ក្រសួងណែនាំអោយប្រធានមន្ទីរទទួលបន្ទុកការងារធំៗជាយុទ្ធសាស្ត្រ ពិសេសការងារអធិការកិច្ច។ ប៉ុន្តែអនុវត្តមានពីររូបភាព គឺតាមការជាក់ស្តែងក៏មាន តាមប្រយោជន៍បុគ្គលក៏មាន ។ ឧទាហរណ៍- ការបែងចែកភារកិច្ចគណៈមន្ទីរអ យ ក ភ្នំពេញ ខែមេសា ឆ្នាំ១៩៩៨ បានឆ្លុះបញ្ចាំងអោយឃើញការងារមួយចំនួន ដែលមនុស្សចង់បានផ្ទាល់ខ្លួន ។

**ឃ-ភារកិច្ចរបស់មន្ទីរអប់រំ យុវជននិងកីឡា**

ភារកិច្ចរបស់ក្រសួងនៅថ្នាក់កណ្តាល ក៏ដូចជានៅ ខេត្ត-ក្រុង មាន២ ផ្នែក គឺ ផ្នែកជំនាញ និង ផ្នែកទ្រទ្រង់ ។

ផ្នែកជំនាញមានការប្រែប្រួល ៤ ដំណាក់កាល :

- ដំណាក់កាលទី១ ពីឆ្នាំ ១៩៧៩ ដល់ ១៩៩២ ( ? ) : មានមត្តេយ្យសិក្សា ចំណេះទូទៅ ( បឋមសិក្សា មធ្យមសិក្សា ) អប់រំក្រៅប្រព័ន្ធ .

-ដំណាក់កាលទី២ ( ១៩៩២ ? ) :មានមត្តេយ្យសិក្សា ចំណេះទូទៅ ( បឋមសិក្សា មធ្យមសិក្សា ) អប់រំក្រៅប្រព័ន្ធ បន្ថែមថ្មីការងារយុវជន .

-ដំណាក់កាលទី៣ ( ១៩៩៣ ) : មានមត្តេយ្យសិក្សា ចំណេះទូទៅ ( បឋមសិក្សា , មធ្យមសិក្សា ) អប់រំក្រៅប្រព័ន្ធ ការងារយុវជន និង បន្ថែមថ្មីការងារកីឡា.

-ដំណាក់កាលទី៤ ដូចដំណាក់កាលទី៣ ដោយបន្ថែមការងារអធិការកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ( នៅក្នុងការិយាល័យអប់រំក្រៅប្រព័ន្ធ តែគ្រប់គ្រងជំនាញស្ថិតក្រោមនាយកដ្ឋានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈ )។ អធិការបឋមសិក្សាត្រូវបានបណ្តុះបណ្តាលឡើងវិញនៅឆ្នាំ១៩៩៤ ដោយមានជំនួយពីសាធារណរដ្ឋបារាំង ។ គោលបំណងនៃការបណ្តុះបណ្តាលគឺអោយមានអធិការបឋមសិក្សានៅគ្រប់ការិយាល័យ អប់រំយុវជនកីឡាស្រុក ដើម្បីលើកកំពស់គុណភាពបឋមសិក្សា ។ ការអនុវត្ត

ជួបការលំបាកដោយអធិការដែលបានទទួលការបណ្តុះបណ្តាលមួយចំនួនសុំទៅខេត្ត-ក្រុងដើមវិញ ( ខុសនឹងកិច្ចសន្យាពេលចូលរៀន ) ដោយមូល ហេតុផ្សេងៗ នាំអោយមានការគរ-ខ្វះអធិការនៅតាម ខេត្ត-ក្រុងខ្លះ។ ម្យ៉ាងទៀតមកដល់ខែមេសា ឆ្នាំ១៩៩៨ ការកំណត់ភារកិច្ចនិងការប្រើប្រាស់អធិការបឋមសិក្សា ទាំងនេះនៅខេត្ត-ក្រុង មិនទាន់មានអ្វីជាគោលការណ៍ច្បាស់លាស់នៅឡើយ ។

ចំពោះការងារប្រលងមានតាំងពីដំណាក់កាលទី១។ ក្រោយមកការងារនេះកាន់តែមានទំហំធំក្រសួងក៏បង្កើតអោយមានការិយាល័យប្រលងដោយឡែកសំរាប់ខេត្ត-ក្រុងធំ អោយទទួលបន្ទុកការប្រលងមធ្យមសិក្សា (ការប្រលងវិញ្ញាបនប័ត្របឋមសិក្សាត្រូវលុបបំបាត់ចោលនៅឆ្នាំសិក្សា ១៩៩៦-៩៧ ) ។

## II - ពីការគ្រប់គ្រងខ្សែរយៈឧនឹង មក ការគ្រប់គ្រងខ្សែរយៈបណ្តោយ

មុនឆ្នាំ១៩៩៣ ខេត្ត-ក្រុងជាស្ថាប័ន រឺ ជារដ្ឋអំណាចមូលដ្ឋានចំណុះរាជរដ្ឋាភិបាល ( ក្រុមប្រឹក្សារដ្ឋមន្ត្រី ) មិនចំណុះក្រសួងមហាផ្ទៃទេ ។ ពេលនោះក្រសួងមហាផ្ទៃមានភារកិច្ចគ្រប់គ្រងកិច្ចការនគរបាល មិនគ្រប់គ្រងខេត្ត-ក្រុង ដូចក្រសួងមហាផ្ទៃក្រោយបោះឆ្នោត ១៩៩៣ ទេ ។

ការរៀបចំភារកិច្ចរបស់មន្ទីរអប់រំនៅខេត្ត-ក្រុងផ្អែកលើគោលការណ៍នេះ ។

សារាចរណែនាំលេខ ៥៨ អរ.ចត ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ១៩៨៤ បានកំណត់តួនាទីនិងភារកិច្ចមន្ទីរអប់រំខេត្ត-ក្រុង។ មន្ទីរអប់រំខេត្ត-ក្រុងជាអង្គភាពជំនាញ ហើយមានតួនាទីដូចតទៅ :

- ទទួលការដឹកនាំ និង គ្រប់គ្រង ពីគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង .
- ទទួលខាងផ្នែកជំនាញពីក្រសួងអប់រំនូវអធិការកិច្ច ការបណ្តុះបណ្តាលកម្មាភិបាល និង បុគ្គលិកសិក្សា

តាមតួនាទីទាំង ២ នេះ យើងសិក្សាលើខ្សែរយៈគ្រប់គ្រង ៣ យ៉ាង :

### ១-ការងារជំនាញ

ការងារនេះបានស្ថិតនៅជាខ្សែរយៈបណ្តោយតែមួយគត់រហូតមករបស់ក្រសួង។

មន្ទីរទទួលកម្មវិធីសិក្សា សៀវភៅសិក្សា ឯកសារគរុកោសល្យ សំភារៈឧបទេស ការណែនាំអនុវត្តកម្មវិធីអធិការកិច្ចពីក្រសួងដែលចុះទៅតាមលំដាប់ខ្សែបណ្តោយដល់សាលារៀន ។ មន្ទីរផលិតបន្ថែមឯកសារ និងសំភារៈបង្រៀន ផ្អែកលើមូលដ្ឋានរបស់ក្រសួង ។

នៅដំណាក់កាលដំបូងក្រោយ១៩៧៩ ការងារជំនាញទាំងនេះជារបស់ក្រសួង ។ នៅរវាងឆ្នាំ១៩៨០ ( ? ) ដែលចាប់ផ្តើមការចាយលុយឡើងវិញ សៀវភៅសិក្សាឯកជនច្រើនរូបភាព ( រ៉ូណេអូ . បោះពុម្ពដៃ ) និង ច្រើន មុខវិជ្ជាបានចេញលក់នៅទីផ្សារ ពិសេសសំរាប់ការប្រលង និង សំរាប់សិស្សមធ្យមសិក្សា ដោយផ្អែកលើ កម្មវិធីសិក្សារបស់ក្រសួង ។

ក្រសួងជាអ្នកទទួលខុសត្រូវលើការប្រលងគ្រប់កំរិត ។ ខេត្ត-ក្រុងរៀបចំការប្រលងវិញ្ញាបនប័ត្រ

បឋមសិក្សាតាមការណែនាំរបស់ក្រសួង : ខេត្តនីមួយៗរៀបចំវិញ្ញាសាប្រលងរបស់ខ្លួន ការកំណត់ភាគរយជាប់ដើម្បី ចូលរៀនមធ្យមសិក្សាក្នុងខេត្ត ។ ការប្រលងវិញ្ញាបនប័ត្រនេះត្រូវលុបចោលនៅឆ្នាំសិក្សា ១៩៩៦-៩៧ ដោយមូលហេតុត្រូវអនុវត្តការអប់រំជាមូលដ្ឋាន៩ឆ្នាំចំណេះទូទៅ ( ការអោយសិស្សតូចៗធ្លាក់ពេលដែលគេមិនអាច បំពេញការងាររកស៊ីអ្វីបាននាំអោយមានការខាតបង់យ៉ាងច្រើន ) ។ សិស្សភាគច្រើនត្រូវឡើងទៅមធ្យមសិក្សា។

ចំពោះមធ្យមសិក្សា ការប្រលងនៅមធ្យមសិក្សាទាំង២កំរិត ក្រសួងជាអ្នករៀបចំដោយផ្ទាល់ គណៈមេប្រយោគទូទាំងប្រទេស គណៈមេប្រយោគតាមមណ្ឌល ( ប្រធាន-អនុប្រធានមណ្ឌល -អនុរក្ស .... ) វិញ្ញាសាប្រលង ការផ្លាស់ប្តូរគណៈមេប្រយោគ ... ។

ដោយទំហំការងារប្រលងឌីប្លូមកាន់តែធំមិនអាចរ៉ាប់ផ្ទាល់បាន នៅឆ្នាំសិក្សា១៩៩៧-៩៨ ក្រសួងប្រគល់ភារកិច្ចអោយខេត្ត-ក្រុងរៀបចំការប្រលងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ( ឌីប្លូម ) ដោយខ្លួនឯងតាមការ ណែនាំរបស់ក្រសួង ។ ក្រសួងចេញវិញ្ញាសាអោយទៅខេត្ត-ក្រុង ( វិញ្ញសាតែ ១ សំរាប់ទូទាំងប្រទេស ) ។

ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងនៅទទួលខុសត្រូវទាំងស្រុង ។

**២- ការងារបុគ្គលិក**

តាមខ្លឹមសារសារាចរលេខ ៥៨ អវ.ចត យើងអាចស្រង់បានភារកិច្ច សំខាន់ ៧ របស់មន្ទីរអប់រំខេត្ត-ក្រុង ។

" ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនតាមរាល់សេចក្តីសំរេច សារាចររបស់មជ្ឈិម និង សេចក្តីណែនាំរបស់ក្រសួងស្តីពី ការចាត់តាំងកម្មាភិបាល។ ដំណើរការប្រលងជ្រើសរើស បែងចែកភារកិច្ច តែងតាំងបុគ្គលិកសិក្សាក្រោមការដឹកនាំ ផ្ទាល់របស់គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ។ អនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍នៃរបបជីវភាពរបស់ កម្មាភិបាលបុគ្គលិកសិក្សា " ។

**ក- ការជ្រើសរើសបណ្តុះបណ្តាល ការតែងតាំងបំរុង និង តែងតាំងស៊ប់**

ចាប់ពី ១៩៧៩ ដល់ ១៩៩៣ ការងារនេះអនុវត្តតាមខ្សែរយៈទទឹង ចំពោះគ្រូបឋមសិក្សា គ្រូមធ្យមសិក្សាបឋមភូមិ លើកលែង តែគ្រូមធ្យម សិក្សាទុតិយភូមិ ។ ខេត្ត-ក្រុងទទួលបានកូតាជ្រើសរើសគ្រូបឋមសិក្សាពីក្រសួងយកទៅធ្វើការជ្រើសរើស បណ្តុះបណ្តាល បែងចែកតែងតាំងបំរុង និង តែងតាំងស៊ប់ ។ មុននេះ ពេលបើកសាលា រៀននៅឆ្នាំ១៩៧៩ ខេត្ត-ក្រុងបានចាត់តាំងអ្នកចេះអក្សរជាច្រើនអោយបង្រៀននៅតាមមូលដ្ឋាន ដើម្បី បំពេញតំរូវការជាក់ស្តែង ។ គ្រូទាំងនេះហៅថា " គ្រូចាត់តាំង " មានបៀវត្ស ខ IV ។ ក្រោយមកក្រសួងបានបើកវគ្គបំពេញវប្បធម៌គ្រូចាត់តាំងដែលមានឌីប្លូមអោយទៅជាគ្រូបឋមសិក្សាមានបៀវត្ស ខ III វិញ ។ ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិត្រូវបានប្រមូលផ្តុំ

ដំបូងនៅសាលាគរុវិជ្ជាជាន់ខ្ពស់ ក្រោយមកនៅមហាវិទ្យាល័យគរុកោសល្យ ហើយនៅឆ្នាំ១៩៨៧នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។ ខេត្ត - ក្រុង មានកូតាប្រលងរបស់ខ្លួនមករៀនប្រមូលផ្តុំនៅទីនោះ ហើយទៅបំរើការនៅកន្លែងដើមរបស់ខ្លួន វិញ ។ ការតែងតាំងបំរុង ការតែងតាំស៊ប់ត្រូវអនុវត្តនៅតាមខេត្ត-ក្រុង ។

ដោយឡែកអតីតបុគ្គលិកសិក្សាដែលប្រលងជាប់ទៅក្របខ័ណ្ឌខ្ពស់ជាគ្រូមធ្យមសិក្សាបឋមភូមិ ក្រសួងចេញប្រកាសតែងតាំង ។

ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សាទុតិយភូមិ ត្រូវបានអនុវត្តតាមខ្សែបណ្តោយរហូតចាប់ពីមានការបណ្តុះបណ្តាល ។ ការបណ្តុះបណ្តាលធ្វើនៅសាលាគរុវិជ្ជាជាន់ខ្ពស់ ( ក្រោយមកដូរឈ្មោះជាសាកលវិទ្យាល័យភ្នំពេញ ) រហូតដល់ឆ្នាំសិក្សា១៩៩៤-៩៥ ។ ចាប់ពីឆ្នាំសិក្សា១៩៩៥-៩៦ ការបណ្តុះបណ្តាលត្រូវធ្វើនៅមហាវិទ្យាល័យគរុកោសល្យវិញ តាមរូបមន្ត បរិញ្ញា + ១ ។

ចាប់ពីឆ្នាំ១៩៩៣ ជាឆ្នាំផ្ទេរពីការគ្រប់គ្រងខ្សែទទឹងអំពីការបណ្តុះបណ្តាល ការតែងតាំងបំរុង តែងតាំងស៊ប់ គ្រូគ្រប់កំរិតមកខ្សែបណ្តោយ ។ គឺក្រសួងរៀបចំការប្រលងជ្រើសរើស ប្រកាសលទ្ធផលប្រលង ត្រួតពិនិត្យការបណ្តុះបណ្តាល និង តែងតាំង ( គ្រូបឋមសិក្សាយកប្រភពតាមខេត្ត , គ្រូមធ្យមសិក្សាបឋមភូមិយកប្រភពតាម ភូមិភាគ ហើយត្រូវចេញទៅបំរើការតាមប្រភពទាំងនោះវិញ ) ។

**ខ/ការតែងតាំងមន្ត្រីគ្រប់គ្រង**

សារាចរ លេខ ៥៨ អរ.ចត បានបញ្ជាក់អំពីភារកិច្ចរបស់ប្រធានមន្ទីរថា " ប្រធានមន្ទីរអប់រំខេត្ត-ក្រុង ទទួលខុសត្រូវរួមចំពោះគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង និង ក្រសួងអប់រំ អំពីការងារអប់រំ ... " ។

ដោយភារកិច្ច " ទទួលខុសត្រូវរួម " នេះ គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត - ក្រុងជាខ្សែទទឹងដែលមានភារកិច្ចតែងតាំងមន្ត្រីគ្រប់គ្រងគ្រប់លំដាប់ថ្នាក់នៅក្នុងខេត្ត-ក្រុង ពី ប្រធានមន្ទីររហូតដល់នាយកសាលា រៀន ។

ក្រោយពេលបោះឆ្នោតក្នុងការផ្ទេរការគ្រប់គ្រងខ្សែទទឹងមកខ្សែបណ្តោយ ក្រសួងបានចេញសេចក្តីណែនាំលេខ ៧៣៧ អយក.សណន ចុះថ្ងៃទី ៩ ខែឧសភា ឆ្នាំ១៩៩៤ ចុះហត្ថលេខាដោយរដ្ឋមន្ត្រី អ៊ឹង ហួត ស្តីពីការតែងតាំងតំលើងឋានៈ និង ផ្លាស់ប្តូរមន្ត្រីគ្រប់គ្រង ។

- ចំពោះការតែងតាំង និង តំលើងឋានៈនាទីថ្នាក់ណាមួយនៅខេត្ត-ក្រុង ថ្នាក់លើបន្ទាប់ធ្វើសំណើដោយមានការឯកភាពតាម ឋានានុក្រមក្រសួងអប់រំយុវជននិងកីឡា និង រដ្ឋអំណាចមូលដ្ឋាន ។
- ចំពោះការផ្លាស់ប្តូរ និង ដកហូតឋានៈនាទីថ្នាក់ណាមួយនៅខេត្ត-ក្រុង ថ្នាក់លើបន្ទាប់ធ្វើសំណើដោយមានការឯកភាពតាមឋានានុក្រមក្រសួងអប់រំយុវជននិងកីឡា និង រដ្ឋអំណាចមូលដ្ឋាន ។

ទំនាស់នៃការតែងតាំងមន្ត្រីគ្រប់គ្រងកើតឡើងនៅឆ្នាំ១៩៩៥ រវាង រដ្ឋមន្ត្រី តុល ឡោះ និងអភិបាលរងទី១ក្រុងភ្នំពេញ ជា សុផារ៉ា ។ ពេលនោះមានចេញប្រកាសតែងតាំងនាយក-នាយករងសាលាបឋមសិក្សាជាច្រើន នាយក-នាយករងសាលាមធ្យមសិក្សា ( បាក់ទូក , សន្ធរម៉ុក , ឥន្ទ្រទេវី ... ) ដែលមាន នាយក-នាយករងចូលនិវត្ត ។ ប្រកាសតែងតាំងនាយក-នាយករងសាលាបឋមសិក្សាអនុវត្តបាន ។ ប្រកាសតែងតាំងនាយក-នាយករង មធ្យមសិក្សាអនុវត្តមិនបាន ដោយមានការជំទាស់របស់អភិបាលរង ជា សុផារ៉ា ។ មានការដោះស្រាយទំនាស់នេះដល់អគ្គាធិការកិច្ចរាជរដ្ឋាភិបាល ។ ទំនាស់នេះមានមូលហេតុជ្រៅជ្រះ រួមទាំងមូលហេតុនយោបាយផង មិនត្រឹមតែមូលហេតុគោលការណ៍នៃ សេចក្តីណែនាំលេខ ៧៣៧ អយក.សណននេះទេ ។

## ៣- ការងារ ហិរញ្ញវត្ថុ

ការងារនេះមាន ២ ដំណាក់កាល ។ មុន ១៩៩៣ ថវិការបស់មន្ទីរទាំងអស់ជុំវិញខេត្តជាថវិការបស់ខេត្តនោះ ។ មន្ទីរធ្វើផែនការថវិកាជូនគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត និង អនុវត្តផែនការនេះ ។ ការបើកបៀវត្សអាស្រ័យដោយថវិកាខេត្ត ក្រសួងមិនគ្រប់គ្រងថវិកាមន្ទីរអប់រំយុវជននិងកីឡានៅខេត្តទេ ។ ខេត្តមានសិទ្ធិចាត់ចែងប្រើប្រាស់ថវិកាទាំងអស់នៅក្នុងខេត្ត : បន្ថែម ផ្ទេរ កាត់ ផ្អាក បន្ថយ... ផ្នែកថវិកាណាមួយក៏បាន ។

ការអនុវត្តថវិកាខ្សែបណ្តោយជំហានដំបូងក្រោយឆ្នាំ១៩៩៣មកដល់១៩៩៨ ត្រូវបានកត់សំគាល់ថា :

-ថ្នាក់កណ្តាលធ្វើគំរោងថវិកាប្រចាំឆ្នាំរបស់ខ្លួនសំរាប់ទីស្តីការ

-មន្ទីរអប់រំយុវជននិងកីឡា ធ្វើគំរោងថវិការបស់ខ្លួនអោយមន្ទីរហិរញ្ញវត្ថុខេត្ត ។ ខេត្ត-ក្រុង លើកសំណើថវិការបស់បណ្តាមន្ទីរជុំវិញខេត្ត-ក្រុងរបស់ខ្លួនមកក្រសួងហិរញ្ញវត្ថុ ( ដោយមិនចាំបាច់ឆ្លងក្រសួងសាមីជាអ្នកគ្រប់គ្រងខ្សែបណ្តោយ ។

ប្រធានស្ថាប័ន ( ក្រសួង រឺ រដ្ឋលេខាធិការដ្ឋាន ) ជាអាណាប័កដើមខ្សែ ។ អភិបាលខេត្តជាអាណាប័កទី ២ ។ ថវិការបស់មន្ទីរអប់រំ យុវជននិងកីឡានៅខេត្ត-ក្រុងនីមួយៗ មិនអាចដកយកទៅប្រើប្រាស់សំរាប់ការងារផ្សេងៗក្រៅពីការងារអប់រំយុវជននិងកីឡាបានឡើយ ។

កំណត់សំគាល់សំខាន់មួយ គឺ ពីខ្សែទទឹង ១៩៧៩ មកខ្សែបណ្តោយ យើងមិនទាន់អនុវត្តការផ្លាស់ប្តូរមន្ត្រីគ្រប់គ្រង ប្រធាន រឺ អនុប្រធានមន្ទីរ ពីខេត្តមួយទៅខេត្តមួយទេ ដោយមូលហេតុជាច្រើន ។ អ្នកខ្លះបានកាន់មុខដំណែងជាប្រធានមន្ទីរពីដើមទីរហូតមក មានលោក អ៊ុំ ហៀង , លោក នុត សែម , លោក ជៀម លីមអៀង ។

## III -ប្រធានមន្ទីរ អប់រំ យុវជននិងកីឡា ខេត្ត- ក្រុង

### ឈ្មោះ ខេត្ត-ក្រុង និងប្រធានមន្ទីរ ( ពី ឆ្នាំ ១៩៧៩ -១៩៩៨ )

| ល.រ | ខេត្ត - ក្រុង | ប្រធានមន្ទីរ |
|---|---|---|
| 1. | ភ្នំពេញ | អ៊ុំ ហឿង |
| 2. | កណ្តាល | សំ ណាំ , តុប សន |
| 3. | បាត់ដំបង | ស្រ៊ុន , ស៊ុន ញ៉ឹក , យូន ឈឿត |
| 4. | តាកែវ | អ៊ិន សំអុល , ហាក់ សឹងលី |
| 5. | កំពង់ចាម | ឡាយ សុខា , ហួត នន់ |
| 6. | ព្រៃវែង | ម៉ម ហេង , ឯម អុន , ឈូន សឿន |
| 7. | ស្វាយរៀង | ថាច់ ចូវ , សៅ ឡេង |
| 8. | កំពង់ធំ | ជា ជឿន , ជិន វ៉ាន់ថន |
| 9. | ពោធិសាត់ | ធាម លឹម អៀង |
| 10. | កំពត | ងួន ហឿង ( ដល់ឆ្នាំ ១៩៩៨ ), ភូ តីកុក (អនុប្រធានទទួលបន្ទុករួម ) |
| 11. | កំពង់ឆ្នាំង | នុត សែម |
| 12. | ក្រុងព្រះសីហនុ | ចេង គីមសេង , ជិន ម៉េង |
| 13. | សៀមរាប | ? តោ គីមស៊ាន |
| 14. | កំពង់ស្ពឺ | ? ស៊ុន សម្បាន |
| 15. | ស្ទឹងត្រែង | ? ណយ សុខ័ន |
| 16. | ព្រះវិហារ | ពេជ្រ សាអ៊ុំ , រស់ ស៊ីផន |
| 17. | រតនគីរី | ? ផាន់ ភិរុណ , ច័ន្ទ ខាំយៀ (អនុប្រធានទទួលបន្ទុករួម ) |
| 18. | មណ្ឌលគីរី | ? ជុំ វ៉ាលី |
| 19. | បន្ទាយមានជ័យ | ? ពិន ឧកញ៉ា |
| 20. | កោះកុង | តាំង សារិន, ឯវ សំអឿន , មាស សាម៉េត (អនុប្រធានទទួលបន្ទុករួម ), យូន នួន |
| 21. | ក្រចេះ | ឡៀ សុផល , តាន់ ហុងលឹម , ម៉ៅ ចុង (អនុប្រធានទទួលបន្ទុករួម ) |
| 22. | ក្រុងកែប | ងួន បៀន |
| 23. | ក្រុងប៉ៃលិន | នួន នឹម |

<u>កំណត់សំគាល់</u> : ១- ប្រធានមន្ទីរទាំងនេះកាន់មុខតំណែងបន្តបន្ទាប់គ្នា ។

២- ប្រធាន-អនុប្រធានមន្ទីរដែលផ្ទេរមកពីយុវជននៅខេត្ត-ក្រុង មានចំនួន១៩ នាក់ កាន់មុខតំណែងជាអនុប្រធានមន្ទីរ អប់រំយុវជននិងកីឡា ។

## បញ្ជីរាយនាមប្រធាន និង អនុប្រធានមន្ទីរ ខេត្ត-ក្រុង
## ( គិតត្រឹម ខែ សីហា ឆ្នាំ ១៩៩៨ )

**១-រាជធានីភ្នំពេញ**

១-លោក អ៊ុំ ហឿង ប្រធាន
២-លោក មាស ង៉ិក អនុប្រធាន
៣-លោក ពត វន អនុប្រធាន
៤-លោក សួស មុត អនុប្រធាន
៥-លោក ជា ជាតិ អនុប្រធាន

**២-ខេត្តកណ្ដាល**

១-លោក គុប សន ប្រធាន
២-លោក ស៊ិន ស៊ីម អនុប្រធាន
៣-លោក ថោង ស៊ិនតូ អនុប្រធាន
៤-លោក ទូច សំអឿន អនុប្រធាន
៥-លោក ទុយ ចន្ទ័ផល្លីន អនុប្រធាន
៦-លោកស្រី គង់ ចាន់បុស្សិបា អនុប្រធាន

**៣-ខេត្តបាត់ដំបង**

១-លោក យូន ឈឿត ប្រធាន
២-លោក វៃ ប៉ូ អនុប្រធាន
៣-លោក ម៉ៅ ម៉ើ អនុប្រធាន
៤-អ្នកស្រី នាង ឡានី អនុប្រធាន

**៤-ខេត្តតាកែវ**

១-លោក ហាក់ សឹងលី ប្រធាន
២-លោក អ៊ីវ សារឹក អនុប្រធាន
៣-លោក នុត ខុន អនុប្រធាន
៤-លោក ឥម មេន អនុប្រធាន

**៥-ខេត្តកំពង់ចាម**

១-លោក ហួត នន់ ប្រធាន
២-លោក អ៊ុក រ៉ុង អនុប្រធាន
៣-លោក ចែម ផាន អនុប្រធាន
៤-លោក ស្វាយ ផល្លា អនុប្រធាន

**៦-ខេត្តព្រៃវែង**

១-លោក ឈួន ឃឿន ប្រធាន
២-លោក ហ៊ឹម សុផល អនុប្រធាន
៣-លោក ទេស សូ អនុប្រធាន
៤-លោក ប៉ាវ សុត អនុប្រធាន
៥-លោក សុខ យាត អនុប្រធាន
៦-លោក ខៀវ ជុំ អនុប្រធាន

**៧-ខេត្តស្វាយរៀង**

១-លោក សៅ ឡេង ប្រធាន
២-លោក នាង រី អនុប្រធាន
៣-លោក ភិន ឆាំ អនុប្រធាន
៤-លោក យ៉ស់ សាវ៉ាត អនុប្រធាន

**៨-ខេត្តកំពង់ធំ**

១-លោក ជិន វ៉ាន់ថន ប្រធាន
២-លោក ស៊ូ គីមទ្រី អនុប្រធាន
៣-លោក យិន គុងហ៊ី អនុប្រធាន

**៩-ខេត្តពោធិសាត់**

១-លោក ជាម លឹមអៀង ប្រធាន
២-លោក ម៉ោល អាន អនុប្រធាន
៣-លោក កែវ យ៉ុង អនុប្រធាន
៤-លោក សួង សុភី អនុប្រធាន

**១០-ខេត្តកំពត**

១-លោក ភូ គីកុក អនុប្រធាន ( រូម )
២-លោក ច្នាន់ សុំ អនុប្រធាន
៣-លោក យុយ យិ អនុប្រធាន
៤-លោក យូរ ឈុយ អនុប្រធាន
៥-លោក កៅ រិទ្ធ អនុប្រធាន

**១១-ខេត្តកំពង់ឆ្នាំង**

១-លោក នុត សែម ប្រធាន

២-លោកស្រី ផាត់ ធនី អនុប្រធាន

៣-លោក ញ៉ែម សាវ៉ាត អនុប្រធាន

៤-លោក នុត ឆាន អនុប្រធាន

**១២-ក្រុងព្រះសីហនុ**

១-លោក ងិន ម៉េង ប្រធាន

២-លោកស្រី សឿ ទេពី អនុប្រធាន

៣-លោក កែវ ឡាយ អនុប្រធាន

៤-លោក វ៉ាន់ ឈួន អនុប្រធាន

៥-លោក ប៉ែន ដាវ៉ាយុត អនុប្រធាន

**១៣-ខេត្តសៀមរាប**

១-លោក តោ គីមស៊ាន ប្រធាន

២-លោក ណាំ ថោងស៊ុ អនុប្រធាន

៣-លោក ទុំ ព្រឿង អនុប្រធាន

៤-លោក សោម សារ៉ូ អនុប្រធាន

**១៤-ខេត្តកំពង់ស្ពឺ**

១-លោក ស៊ុន សម្បាន ប្រធាន

២-លោក ឈឹម នៅ អនុប្រធាន

៣-លោក ចាន់ ឃន អនុប្រធាន

៤-លោក ព្រុំ គីមថៃ អនុប្រធាន

៥-លោក អ៊ុម សុផល អនុប្រធាន

**១៥-ខេត្តស្ទឹងត្រែង**

១-លោក ណយ សុខន័ ប្រធាន

២-លោក ឯម ប៊ុនឿ អនុប្រធាន

៣-លោក ពុយ ចាន់ថាឡាក់ អនុប្រធាន

៤-លោក ស៊ុប ប៊ុនយ៉ន អនុប្រធាន

**១៦-ខេត្តព្រះវិហារ**

១-លោក រស់ ស៊ុ ផន ប្រធាន

២-លោក ហាន ឆន អនុប្រធាន

៣-លោក នង ចន អនុប្រធាន

៤-លោក អ៊ុក បូរីរុណ អនុប្រធាន

**១៧-ខេត្តរតនគិរី**

១-លោក ផាន់ ភិរុណ ប្រធាន

២-លោកស្រី ចន្ទ័ ខាំឿ អនុប្រធាន

៣-លោក ហៃ ប៊ុនស៊ុំ អនុប្រធាន

**១៨-ខេត្តមណ្ឌលគិរី**

១-លោក ជុំ វ៉ាលី ប្រធាន

២-លោក ណយ ស្រួន អនុប្រធាន

៣-លោក ស្រ៊ំ ង៉ាត អនុប្រធាន

៤-លោក អួម ចាន់វុឌ្ឍា អនុប្រធាន

**១៩-ខេត្តបន្ទាយមានជ័យ**

១-លោក ពិន ឧកញ៉ា ប្រធាន

២-លោក អែម សុខុម អនុប្រធាន

៣-លោក ឱក ទិន អនុប្រធាន

៤-លោក ហ៉ៅ ស៊ីទិន អនុប្រធាន

៥-លោក សួង សារ៉ុន អនុប្រធាន

**២០-ខេត្តកោះកុង**

១-លោក ឃួន នួន ប្រធាន

៣-លោក មាស សាម៉េត អនុប្រធាន

៤-លោក សួន សីហា អនុប្រធាន

**២១-ខេត្តក្រចេះ**

១-លោក ម៉ៅ ផុង អនុប្រធាន (រួម

២-លោក អ៊ីវ សុផានី អនុប្រធាន

**២២-ក្រុងកែប**

១-លោក ងួន ហ៊ៀន ប្រធាន

២-លោក ងួន ហៀន អនុប្រធាន

៣-លោក ឆាយ ម៉េង អនុប្រធាន

**២៣-ក្រុងប៉ៃលិន**

១-លោក នួន នឹម ប្រធាន

២-លោក ខាត់ រីម អនុប្រធាន

៣-លោក ឡាច ឆុន អនុប្រធាន